**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**


## សារណាបញ្ចប់ការសិក្សា

# សិទ្ធិ និងភាតព្វកិច្ចរបស់សារការី

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **សែម រចនា**

លោក **លេខ សីឡា**

សាស្ត្រាចារ្យណែនាំ

លោក **ញឹក ឌុឌ្ឌី**


ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ១៧

ឆ្នាំចូលរៀន ២០១៣

ឆ្នាំសរសេរសារណា ២០១៧

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# សិទ្ធិ និងភាតព្វកិច្ចរបស់សារការី

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧

ស្រាវជ្រាវដោយ                                        សាស្ត្រាចារ្យណែនាំ
និស្សិតឈ្មោះ៖ លោក **សែម រចនា**                     លោក **ញឹក ខុឌ្ឍី**
លោក **លេខ សីឡា**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ          ឆ្នាំចូលរៀន          ២០១៣
ជំនាន់ទី ១៧                         ឆ្នាំសរសេរសារណា    ២០១៧

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **សែម រចនា** និងឈ្មោះ **លេខ សីឡា** ជានិស្សិតឆ្នាំទី ៤ ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី ១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

លោកអ្នកមានគុណទាំងទ្វេ លោកបានផ្តល់កំណើតដល់កូន និងបានខិតខំអស់ទាំងកម្លាំងកាយចិត្ត ដោយពុំខ្លាចនឿយហត់ក្នុងការចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅឲ្យកូនខិតខំសិក្សា រៀនសូត្រ ក្រេបជញ្ជក់ ចំណេះដឹង តាំងពីកម្រិតមូលដ្ឋាន រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនាពេលដ៏ខ្លីខាងមុខនេះ។

**ឯកឧត្តមបណ្ឌិត លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់ឱកាសឲ្យយើងខ្ញុំពង្រីកចំណេះដឹងតាមរយៈការសរសេរសារណាបញ្ចប់ការសិក្សានេះឡើង។

ជាពិសេស លោកសាស្ត្រាចារ្យណែនាំ **ញឹក ឧុធី** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការប្រឹងប្រែង ដោយមិនខ្លាចហត់នឿយសម្រាប់ការចង្អុលបង្ហាញផ្លូវណែនាំ និងកែប្រែរាល់កំហុសឆ្គងរបស់យើងខ្ញុំ ដើម្បីធានាបានសមិទ្ធិផលមួយដែលប្រកបដោយគុណភាព។

**លោក និងលោកស្រី សាស្ត្រាចារ្យ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានបង្ហាត់បង្រៀន ដល់រូបយើងខ្ញុំតាំងពីថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន រហូតដល់ពេលបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។

**សិស្សច្បង មិត្តនិស្សិត និងរៀមច្បងរួមការងារ** ដែលបានជួយរកឯកសារដល់យើងខ្ញុំទាំងពីរនាក់ ព្រមទាំងជួយពិនិត្យអក្ខរាវិរុទ្ធ កែសម្រួលកំហុសឆ្គងថែមទៀតដែលជាកម្លាំងចិត្តជម្រុញឲ្យយើងខ្ញុំខិតខំបន្តការសិក្សាស្រាវជ្រាវនេះរហូតបានសម្រេច។

យើងខ្ញុំសូមគោរពជូនពរ និងសូមលើកហត្ថទាំងទ្វេបួងសួងដល់ទេវតា ឲ្យតាមថែរក្សាព្រះរាជាណាចក្រកម្ពុជាទាំងមូល សូមជួយថែរក្សាលោកអ្នកមានគុណទាំងទ្វេ ឯកឧត្តម លោក លោកស្រីសាស្ត្រាចារ្យ និងអ្នកបានជួយទំនុកបម្រុងក្នុងកិច្ចការសារណានេះ សូមឲ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ និងសូមឲ្យទទួលបានជោគជ័យគ្រប់ភារកិច្ច។

# អារម្ភកថា

សារណានេះ បានតាក់តែងឡើងនៅក្នុងឱកាសបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ហើយក៏ជាឧបករណ៍មួយសម្រាប់បង្ហាញសមត្ថភាព និងចំណេះដឹង ដែលបានមកពីការខិតខំប្រឹងប្រែង និងសិក្សាស្រាវជ្រាវអស់រយៈពេល៤ឆ្នាំនៅ **សាកលវិទ្យាល័យភូមិន្ទ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**។ សារណាដែលបានតាក់តែងឡើងមកនេះ គឺជាស្នាដៃថ្មីមួយសម្រាប់ជាគុណប្រយោជន៍ដល់ការសិក្សាសម្រាប់ និស្សិតផ្នែកនីតិសាស្ត្រជំនាន់ក្រោយៗខាងមុខទៀត។

សារការី នៃព្រះរាជាណាចក្រកម្ពុជាត្រូវបានបង្កើតនៅឆ្នាំ១៩៥៤ តែត្រូវបានផ្អាកទៅវិញដោយសារវិបត្តិសង្គ្រាម ស្ថាប័នមួយនេះ គឺចំណុះទៅឲ្យអំណាចសាធារណៈក្នុងការផ្ដល់យថាភូតភាព លើលិខិតទាំងឡាយដែលមានការពាក់ព័ន្ធទៅនឹងវិស័យគ្រួសារ ចលនវត្ថុ និងអចលនវត្ថុ ដោយធ្វើការបញ្ជាក់ និងប្រថាប់ត្រា ទទួលតម្កល់ទុកឯកសារ និងចេញនូវសេចក្ដីដើម ឬចម្លងនៃលិខិតស្នាមគតិយុត្តិ ឬកិច្ចសន្យាទាំងឡាយ ដែលយថាភូតភាពដែលធ្វើដោយសារការីអាចបញ្ចៀសការប្ដឹងផ្ដល់ទៅស្ថាប័នតុលាការ។

ហេតុដូចនេះ ទើបយើងខ្ញុំបានខិតខំស្វែងរកឯកសារ និងចុះកម្មសិក្សាមន្ទីសាការីអង្គរជាគោលបំណង គឺចង់យល់ដឹងអំពីលក្ខណៈពិសេសក្នុងការធ្វើកិច្ចសន្យា លក្ខន្តិកៈក្រុមហ៊ុន និងមានជាច្រើនទៀតដែលធ្វើដោយសាការី វាមានសារៈសំខាន់ណាស់ តួយ៉ាងប្រធានបទនេះនឹងបង្ហាញអំពីការវិវត្តន៍នៃវិស័យច្បាប់ ទាក់ទងទៅជាមួយសារការីក្នុងប្រទេសកម្ពុជា ថាបានអភិវឌ្ឍន៍យ៉ាងណាខ្លះបន្ទាប់ពីសង្គ្រាមរួមមក។ ប្រធានបទស្ដីពី "**សិទ្ធិ និងភាតព្វកិច្ចសារការី**" នឹងក្លាយជាឧបករណ៍មួយសម្រាប់ធ្វើការពង្រីកនូវចំណេះដឹងបន្ថែម ទាក់ទងទៅនឹងសារការីនាពេលបច្ចុប្បន្ន ក៏ដូចជាអំពីសិទ្ធិ និងកាតព្វ-កិច្ច ក្នុងការផ្ដល់យថាភូតដល់លិខិតផ្សេងៗនៅប្រទេសកម្ពុជាសម្រាប់ស្វែងយល់។

ទោះបីជាសារណាមួយនេះបានបង្កើតឡើងដោយការខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់អស់ពីសមត្ថភាពយ៉ាងណាក្ដី កំហុសខុសឆ្គងដោយអចេតនាក៏ដូចជាការបកប្រែខ្លឹមសារពីភាសាបរទេសមកជាភាសាខ្មែរ ការប្រើប្រាស់ពាក្យពេចន៍ ឃ្លាឃ្លោង និងប្រយោគជាដើម រមែងតែងតែកើតមានឡើងជាក់ជាមិនខាន។ អាស្រ័យហេតុនេះហើយ រាល់មតិរិះគន់ក្នុងន័យស្ថាបនាពីសំណាក់លោក លោកស្រីសាស្ត្រាចារ្យ មិត្តនិស្សិតអ្នកអានទាំងអស់ គឺជាចំណែកដែលមិនអាចខ្វះបាន ដើម្បីជាការចូលរួមកែលម្អ និងដើម្បីទុកជាមេរៀនសម្រាប់អភិវឌ្ឍន៍ចំណេះដឹងក្នុងការស្រាវជ្រាវបន្តទៅមុខទៀត។

# មាតិកា


**ទំព័រ**

**សេចក្តីផ្តើម** ........................................ ១

## ជំពូកទី១

## សញ្ញាណទូទៅនៃសារការី

**១.១. ប្រវត្តនៃសារការី** ........................................ ៤

១.១.១. និយមន័យនៃពាក្យថាសារការី ........................................ ៨

១.១.២. កំណើតនៃវិជ្ជាជីវៈសារកា........................................ ៨

**១.២. លក្ខខណ្ឌដើម្បីទទួលបានមុខងារជាសារការី** ........................................ ១៥

១.២.១. សារការីតាមរយៈការប្រឡងជ្រើសរើស........................................ ១៧

១.២.១.១. លក្ខខណ្ឌនៃការប្រលង........................................ ១៧

១.២.១.២. ការបណ្តុះបណ្តាលបឋម........................................ ១៨

១.២.១.៣. កម្មសិក្សា និងការជួបជុំផ្លោះប្តូបទពិសោធន៍ ........................................ ២០

១.២.១.៤. ការតែងតាំងនូវមុខងារសារការីដល់សិស្សដែល បានបញ្ចប់ការសិក្សា ........................................ ២០

១.២.២. ការទទួលបានមុខងារជាសារការីតាមរយៈការតែងតាំង........................................ ២១

## ជំពូកទី ២

## សិទ្ធិ និងភាតព្វកិច្ចរបស់សារការី

**២.១. សិទ្ធិរបស់សារការី** ........................................ ២៣

២.១.១. ផ្តល់ប្រឹក្សាយោបល់........................................ ២៣

២.១.២. ការតាក់តែង និងផ្តល់យថាភូតរាល់លិខិតគតិយុត្ត ឬកិច្ចសន្យានានា ........................................ ២៣

២.១.២.១. វិស័យអចលនទ្រព្យ........................................ ២៤

២.១.២.២. វិស័យនីតិគ្រួសារ........................................ ២៥

២.១.៣. ផ្តល់យថាភូតរាល់លិខិតគតិយុត្ត ឬកិច្ចសន្យានានា........................................ ២៨

២.១.៤. ចេញច្បាប់ចម្លងនៃលិខិតយថាភូត ........................................ ២៨

២.១.៥.ផ្តល់ការបញ្ជាក់សុពលភាពចំពោះការបង្កើត ឬកែប្រែលក្ខន្តិកៈក្រុមហ៊ុន........................................ ២៩

២.១.៦. បញ្ជាក់ហត្ថលេខា និងកាលបរិច្ឆេទនៃលិខិតគតិយុត្ត ឬកិច្ចសន្យានានា........................................ ៣០

២.១.៧. តម្កល់ និងរក្សាទុកច្បាប់ដើមនៃលិខិតស្នាមគ្រប់ប្រភេទ ........................................ ៣០

២.១.៨. ចេញនូវរូបមន្តអនុវត្ត និងការអនុវត្តដោយបង្ខំ ............................................ ៣១
**២.២. ភាតព្វកិច្ចរបស់សារការី** ................................................................ ៣២
២.២.១. ប្រឹក្សាយោបល់ដល់គូភាគី ................................................................ ៣២
២.២.២. ការជូនដំណឹងដល់គូភាគីករណីមានការកែប្រែ ឬបញ្ហាផ្សេងៗ ...................... ៣៣
២.២.៣. ពិនិត្យ និងផ្ទៀងផ្ទាត់អត្តសញ្ញាណ ......................................................... ៣៣
ក. អត្តសញ្ញាណគូភាគី ................................................................ ៣៣
ខ. អត្តសញ្ញាណនៃទ្រព្យ ................................................................ ៣៤
គ. ពិតិន្យ និងផ្ទៀងផ្ទាត់លើច្បាប់ ......................................................... ៣៤
២.២.៤. ការទទួលខុសត្រូវក្នុងការបំពេញមុខងាររបស់ខ្លួន ........................................ ៣៤
ក. ការរក្សាការសម្ងាត់ ................................................................ ៣៥
ខ. ការផ្តល់សមភាព ................................................................ ៣៥
គ. ព្យសនកម្ម ................................................................ ៣៥
**២.៣. ដែនសមត្ថកិច្ចរបស់សារការី** ................................................................ ៣៦
២.៣.១.ការអនុវត្តសិទ្ធ កាតព្វកិច្ចសារការី ......................................................... ៣៦
២.៣.២.ការមិនអាចអនុវត្តបាននៃសិទ្ធិសារការី ......................................................... ៣៦
**សេចក្តីសន្និដ្ឋាន** ................................................................ ៣៩
**អនុសាសន៍** ................................................................ ៤០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហា៖

សារការី ជាវិជ្ជាជីវៈសេរីមួយដែលបានចាប់កំណើតឡើងជាថ្មីម្តងទៀតនៅក្នុងប្រទេសកម្ពុជា យើងក្នុងនីតិរដ្ឋថ្មីនេះ ក្រោយពីវិជ្ជាជីវៈនេះបានបាត់បង់ទៅអស់រយៈជាច្រើនឆ្នាំមកហើយ។ មុខងារសារការី ត្រូវបានប្រសូត្រឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៥៤ តាមរយៈព្រះរាជក្រមលេខ ៩១០ ន.ស ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ ប៉ុន្តែព្រះរាជក្រមនេះត្រូវបានផ្អាកនៅក្នុងយុគ្គសម័យរបបខ្មែរក្រហម។ ក្នុងពេលបច្ចុប្បន្ននេះ សារការីកំពុងមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់មេធាវី អ្នកច្បាប់ជាច្រើនផងដែរ។ តើសារការីមានសមត្ថកិច្ចក្នុងកិច្ចការអ្វីខ្លះ បានជាមានការចាប់អារម្មណ៍ខ្លាំងពីសំណាក់មេធាវី?

បើយើងងាកទៅមើលបញ្ញត្តិនានា ដែលបានចែងទាក់ទងទៅនឹងសមត្ថកិច្ចក្នុងការតាក់តែងលិខិត និងផ្តល់យថាភូតលើលិខិតស្នាមនានា ពោលគឺរាជរដ្ឋាភិបាល បានប្រតិភូកម្មអំណាចទៅឲ្យសារការី។ តាមរយៈព្រះរាជក្រមលេខ៩១០ ន.ស ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ បានចែងយ៉ាងលម្អិត និងពិណ៌នាយ៉ាងច្បាស់លាស់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់សារការី។ យោងតាមមាត្រា១ នៃរាជក្រមលេខ៩១០ ន.ស ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ បានបញ្ញត្តិថា **សារការី** ជាមន្ត្រីសាធារណៈដែលតាំងឡើងតាមព្រះរាជក្រឹត្យនៃរដ្ឋាភិបាល ហើយតាមរយៈព្រះរាជក្រមនេះយើងអាចនិយាយរួមបានថា សារការីមានសមត្ថកិច្ចក្នុងការធ្វើលិខិតយថាភូត បញ្ជាក់ពីភាពត្រឹមត្រូវនៃលិខិត តម្កល់រក្សាទុក ចេញសេចក្តីចម្លងទាំងឡាយឲ្យមានយថាភូត និងបំពេញនូវមុខងាររបស់ខ្លួនក្នុងការផ្តល់ចារឹកលក្ខណៈតាមផ្លូវច្បាប់ដល់លិខិត ឬកិច្ចសន្យាទាំងឡាយដែលបានកំណត់ដោយច្បាប់។ ដោយឡែកបើយោងតាមអត្ថន័យនៃសន្ទានុក្រមនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ សារការី ជាមន្ត្រីសាធារណៈដែលមានមុខងារធ្វើលិខិតយថាភូតបញ្ជាក់អំពីលក្ខណៈពិតប្រាកដត្រឹមត្រូវ ធានារ៉ាប់រងអំពីកាលបរិច្ឆេទតម្កល់ រក្សាទុក និងចេញសេចក្តីចម្លងយថាភូតនៃលិខិតទាំងឡាយដែលត្រូវតែឲ្យមានការបញ្ជាក់។

ទោះបីជាព្រះរាជក្រមលេខ៩១០ ន.ស ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ និងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មានចែងអំពីសមត្ថកិច្ច សិទ្ធិ និងកាតព្វកិច្ចរបស់សារការីបានក្បោះក្បាយយ៉ាងណាក្តីក៏នៅមានបញ្ញត្តិផ្សេងៗមួយចំនួនទៀត បានលើកឡើងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់សារការីនេះដែរ។ ជាក់ស្តែងអនុក្រឹត្យស្តីពី ការផ្តល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវី នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាអនុក្រឹត្យស្តីពីការបង្កើតមន្ទីរសារការីផ្សេងៗជាដើម។ លំនាំបញ្ហាដែលបានរៀបរាប់ខាងលើត្រូវបានបញ្ចប់ ឈានចូលដល់ចំណោទបញ្ហាជាបន្ត។

## ២.ចំណោទបញ្ហា៖

នៅក្នុងបញ្ញត្តិជាច្រើនបានចែងទាក់ទងនឹងសិទ្ធិ និងកាតព្វកិច្ចរបស់សារការី ក្នុងនោះក៏បាននិយាយទាក់ទងនឹងប្រត្តិបត្តិការរបស់សារការីលើលិខិតស្នាមផងដែរ ប៉ុន្តែបើយើងងាកទៅមើលមុនពេលមានវត្តមានវិជ្ជាជីវៈសារការី ការផ្តល់យោបល់ និងតាក់តែងលិខិតស្នាមផ្សេងៗក្នុងវិស័យគតិយុត្តត្រូវបានធ្វើឡើងដោយមេធាវី។

- តើប្រវត្តិនៃកំណើតរបស់សារការីចាប់ផ្តើមបែបណា?
- តើសិទ្ធិរបស់សារការីមានអ្វីខ្លះ?
- តើកាតព្វកិច្ចរបស់សារការីមានអ្វីខ្លះ?
- តើដែនសមត្ថកិច្ចរបស់សារការី មានការកំណត់យ៉ាងដូចម្តេច?

ចំណោទបញ្ហាដែលបានរៀបរាប់ខាងលើត្រូវបានបញ្ចប់ ឈានចូលដល់គោលបំណងនៃការសិក្សាស្រាវជ្រាវជាបន្ត។

## ៣.គោលបំណង៖

ការសិក្សាស្រាវជ្រាវនេះ គឺមានគោលបំណងនៅក្នុងការចូលរួមចំណែកបង្កើននូវចំណេះដឹងដល់ក្រុមយើងខ្ញុំដែលបានធ្វើការសិក្សាស្រាវជ្រាវទាំងអស់គ្នា ព្រមទាំងបានយល់ដឹងកាន់តែច្បាស់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់សារការីផងដែរ។ វាក៏ជាឯកសារមួយសម្រាប់តម្កល់ទុកក្នុងសាលកវិទ្យាល័យ ដើម្បីឲ្យនិស្សិតជំនាន់ក្រោយបានធ្វើការសិក្សាបន្ទាប់បន្សំ។ គោលបំណងចម្បងនៃការសិក្សាស្រាវជ្រាវនេះ គឺផ្តោតទៅលើចំណុចសំខាន់ៗដូចជា៖

- សិក្សាទៅលើសញ្ញាណទូទៅរបស់សារការី
- សិក្សាទៅលើការសិទ្ធិរបស់សារការី
- សិក្សាទៅលើកាតព្វកិច្ចរបស់សារការី
- សិក្សាទៅលើការធ្វើកិច្ចសន្យា ឬលិខិតគតិយុត្តិ
- សិក្សាទៅលើផ្តល់យថាភូតភាពដល់លិខិតគតិយុត្តិ ឬកិច្ចសន្យា ឬឯកសារបកប្រែ
- សិក្សាទៅលើការអនុវត្តដោយបង្ខំនូវលិខិតគតិយុត្តិ

គោលបំណងនៃការសិក្សាស្រាវជ្រាវដែលបានរៀបរាប់ខាងលើត្រូវបានបញ្ចប់ ឈានចូលដល់ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវជាបន្ត។

## ៤.ដែនកំណត់ និងវិសាលភាព៖

ការសិក្សារបស់ក្រុមយើងខ្ញុំ ផ្តោតសំខាន់ទៅលើសិទ្ធិ និងកាតព្វកិច្ចរបស់សារការីនៃព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។ កាលដែលកំណត់អំពីដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវនេះ ធ្វើឲ្យយើងកាន់តែមានភាពងាយស្រួលក្នុងការស្រាវជ្រាវ។

ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវដែលបានរៀបរាប់ខាងលើត្រូវបានបញ្ចប់ ឈានចូលដល់សារសំខាន់នៃកាសរសិក្សាស្រាវជ្រាវជាបន្ត។

## ៥.សារសំខាន់នៃការសិក្សា៖

សារៈសំខាន់ គឺដើម្បីឲ្យយើងយល់ដឹងអំពីសញ្ញាណទូទៅ សិទ្ធិ និងកាតព្វកិច្ចរបស់វិជ្ជាជីវៈសារការីនៃព្រះរាជាណាចក្រកម្ពុជា។ ម៉្យាងទៀតដើម្បីបំពេញបន្ថែមនូវចំណុចខ្វះខាតដែលកើតមាននៅក្នុងការអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់មុខងារសារការី រួមទាំងបានផ្តល់សារសំខាន់ដល់ក្រុមយើងខ្ញុំ ក្នុងការពង្រឹងនៅចំណេះដឹងដែលបានសិក្សាកន្លងមក ហើយធ្វើឲ្យក្រុមយើងខ្ញុំបាទបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រផ្នែកនីតិសាស្ត្របានដោយជោគជ័យ រួមទាំងបានដកស្រង់នូវបទពិសោធន៍ថ្មីៗនៃផ្នែកទ្រឹស្តីជាមួយនឹងការអនុវត្តជាក់ស្តែង ដើម្បីបង្កើនសមត្ថភាពឲ្យបានសមស្រប នូវតម្រូវការរបស់សង្គមជាតិនាពេលបច្ចុប្បន្ន។ ម្យ៉ាងទៀត សម្រាប់ទុកជាឯកសារដល់មិត្តសិក្សាជំនាន់ក្រោយៗធ្វើជាជំនួយនៃការសិក្សាស្រាវជ្រាវ និងស្វែងយល់បន្ថែមពីសារការី។

សារសំខាន់នៃការសិក្សាស្រាវជ្រាវដែលបានរៀបរាប់ខាងលើត្រូវបានបញ្ចប់ ឈានចូលដល់រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវជាបន្ត។

## ៦.រចនាសម្ព័ន្ធ៖

ការសិក្សាស្រាវជ្រាវនេះ បានបែងចែកជាបីជំពូកមានដូចខាងក្រោម៖

ជំពូកទី១ សញ្ញាណទូទៅនៃសារការី

ជំពូកទី២ សិទ្ធិ និងកាតព្វកិច្ចរបស់សារការី

# ជំពូកទី១

## សញ្ញាណទូទៅសារពើ

# ជំពូកទី១

# សញ្ញាណទូទៅសារការី

## ១.១. ប្រវត្តនៃសារការី

សារការី គឺជាវិជ្ជាជីវៈមួយដែលមានជាយូរយារណាស់មក ហើយមិនត្រឹមតែកម្ពុជាដែលបានទទួលស្គាល់វិជ្ជាជីវៈនេះ ប៉ុន្តែក៏មានប្រទេសជាច្រើនទៀតដែលបានយកវិជ្ជាជីវៈសារការីនេះយកទៅអនុវត្ត ដើម្បីថែរក្សាស្ថានភាពគតិយុត្តរបស់ប្រទេសពួកគេឲ្យមានស្ថេរភាព ។

ប្រវត្តសាស្ត្រនៃស្ថាប័នសារការី បានបញ្ចូលលាយឡំជាមួយនឹងសង្គមមនុស្សជាតិតាំងពីយូរយារណាស់មកហើយ។ ហើយយើងទាំងអស់គ្នាសុទ្ធតែបានដឹងថា ប្រសិនបើគ្មានភស្តុតាងមកបញ្ជាក់នោះទេ យើងនឹងមានការលំបាកក្នុងការការពារនូវផលប្រយោជន៍ស្របច្បាប់។ ដូច្នេះនៅក្នុងស្រទាប់ប្រជាជនគ្រប់ជាតិសាសន៍កាលពីសម័យបុរាណមានអ្នកចម្លងលិខិត និងកិច្ចសន្យា ហើយបំពេញមុខនាទីជាមន្ត្រីសារធារណៈដែលទទួលបន្ទុកកិច្ចព្រមព្រៀង ឬកិច្ចសន្យាទាំងឡាយរបស់បុគ្គលឯកជន ហើយនឹងបំពេញតួនាទីជាមន្ត្រីសាធារណៈនៃភស្តុតាង[១]។

ជាពិសេសនៅក្នុងទីក្រុងរ៉ូម មន្ត្រីសាធារណៈខាងសារការីបានកាន់កាប់កិច្ចសន្យាដែលត្រូវបានធ្វើឡើងនៅចំពោះមុខសាក្សីមួយចំនួន ។

កាលពីមជ្ឈឹមសម័យ នាចន្លោះសតវត្សទី៥ និងទី១៥ ដោយមានការវិវត្តន៍វិស័យពាណិជ្ជកម្ម និងជំនួយជីវភាព គតិយុត្តិកាន់តែមានភាពចាំបាច់ខ្លាំងឡើងជាលំដាប់ ដែលត្រូវរៀបចំឡើងឲ្យស្ថិតនៅលើមូលដ្ឋានមួយដ៏ជឿជាក់ ហើយជាធម្មតាសារការីបានក្លាយជាសកម្មជនសម្រាប់ការអភិឌ្ឍនីតិ និងសម្រាប់ការរៀបចំជីវភាពសង្គម នៅលើសកម្មភាពទាំងនោះ ។

នៅពេលមានការចាប់កំណើតជាថ្មីកាលពីឆ្នាំ១៥៣៩ ហ្វ្រង់ស្វ័ទី១បានប្រកាសឲ្យប្រើបញ្ញត្តិមួយ ដែលដាក់ជាភាសាបារាំងឲ្យប្រើប្រាស់ជាផ្លូវការនៅក្នុងរាល់លិខិតទាំងអស់។ លិខិតនោះត្រូវតែអានចំពោះមុខភាគីនៅមុនពេលដែលភាគីទាំងឡាយចុះហត្ថលេខា ហើយសារការីក៏ចុះហត្ថលេខាខ្លួនឯងផងដែរ ព្រមទាំងបញ្ជាក់លិខិតនេះ ដើម្បីឲ្យមានលក្ខណៈត្រឹមត្រូវតាមច្បាប់។ សារការី មានតួនាទីត្រូវការពារផលប្រយោជន៍ស្របច្បាប់របស់ភាគីទាំងអស់នៃលិខិតរួមទាំងរដ្ឋផង ដោយឈរលើគោលការណ៍ឯករាជ្យ និងស្មោះត្រង់ មិនលំអៀង គោរពច្បាប់ និងក្រមសីលធម៌វិជ្ជាជីវៈខ្ពស់ ហេតុនេះហើយទើបរាល់លិខិត និងកិច្ចសន្យាធ្វើឡើយដោយសារការី ត្រូវបានផ្តល់នូវច្បាប់នៃសារសំខាន់ជាយថាភូតដែលមានតម្លៃជាភស្តុតាងខ្ពស់ និងមានកាលបរិច្ឆេទស្ពាពរ។ នៅសម័យកាល

[១] សៀវភៅ ស្តីពីសន្និសិទស្តីពីមុខងារសារការីតាមបែបប្រទេសបារាំង ថ្ងៃទី ១៧-១៨ ខែកុម្ភៈ ឆ្នាំ២០០៤ ទំព័រទី៧

ដ៏ចលាចល នៃបដិវិត្តន៍ស្ថាប័នសារការីបានពុះពារជំនះរយៈកាលដ៏សែនឈឺចាប់ខ្លោចផ្សាបំផុតនៃប្រវត្តិសាស្ត្ររបស់ខ្លួន។

បើយើងក្រឡេកមើល ប្រវត្តិនៃវិជ្ជាជីវៈសារការីនៃព្រះរាជាណាចក្រកម្ពុជាយើងវិញ វិជ្ជាជីវៈសារការីបានចាប់ផ្តើមអនុវត្តតាំងពីដើមសតវត្សទី២០មកម្លេះ។ វិជ្ជាជីវៈនេះកាលដំបូងបានប្រព្រឹត្តទៅក្រោមឥទ្ធិពលនៃច្បាប់បារាំង ពីព្រោះនាពេលនោះប្រទេសកម្ពុជាបានស្ថិតនៅក្រោយ អាណានិគមបារាំង។ តែនៅពេលនោះព្រះរាជាណាចក្រកម្ពុជាមានសារការីមិនច្រើនទេ ប្រហែលជាពីរ បីនាក់ប៉ុណ្ណោះ ពីព្រោះនៅសម័យនោះការងារសារការី ពុំទាន់ជ្រួតជ្រាបដល់ប្រជាពលរដ្ឋភាគច្រើននោះទេ ដោយហេតុថាការយល់ដឹងផ្នែកច្បាប់របស់ប្រជាពលរដ្ឋនៅមានកម្រិតទាបនៅឡើយ ហើយពួកគេក៏មិនសូវជាយកចិត្តទុកដាក់ទៅលើបញ្ហានេះដែរ ហើយភាគច្រើនអ្នកដែលស្គាល់មុខងារ និងការងាររបស់សារការីនេះមានតែអ្នកជំនួញ និងអ្នកនៅទីផ្សារមួយចំនួនតូចប៉ុណ្ណោះ។ កន្លែងដែលសារការីធ្វើការគេប្រែជាភាសាខ្មែរយើងថា **មន្ទីរ**។ នៅសម័យនោះសារការីខ្មែរយើងដំបូងគេបង្អស់ គឺលោកសារការី **អ៊ឹង អ៊ី**ដែលមានមន្ទីរសារការីនៅភ្នំពេញ។ រាល់កិច្ចការដែលគាត់បានធ្វើ គឺធ្វើជាភាសាបារាំងលាយនឹងភាសាខ្មែរ។ បន្ទាប់មក គឺលោកសារការី **ចេង ហេង** ក្រោយមកទៀតគឺលោកសារការី **ប៉ុក ធូន**។ ប៉ុន្តែ នៅមុខក្រសួងសារការីនៅតែអាចយកបទប្បញ្ញត្តិនៃដេក្រេចុះថ្ងៃទី២៤ ខែសីហា គ.ស១៩២១ និងអត្ថបទនៃច្បាប់បារាំងទាំងអស់ ដែលមុនបានប្រកាសឲ្យប្រើជាត្រឹមត្រូវនៅឥណ្ឌូចិនមកប្រើដដែល ប្រសិនបើបញ្ញត្តិនោះមិនផ្ទុយពីព្រះរាជក្រមមួយបានសរសេរជាភាសាខ្មែរ និងបកប្រែជាភាសារបារាំងផង បានត្រូវលាយព្រះហត្ថលេខាដោយព្រះអង្គម្ចាស់ជីវិតលើត្បូង នៅថ្ងៃទី០៤ ខែវិច្ឆិកា គ.ស១៩៥៤ ដែលមានលេខ៩១០ន.ស[២]។ នៅក្នុងព្រះរាជក្រមនោះមានតែមន្ទីសារការីតែមួយប៉ុណ្ណោះដែលត្រូវបានបង្កើតឡើង ដើម្បីប្រកបវិជ្ជាជីវៈនេះនៅក្នុងប្រទេសទាំងមូល។ ប៉ុន្តែនៅក្នុងព្រះរាជក្រមនេះនៅក្នុងមាត្រា៦ បានបញ្ញត្តិថា ត្រូវបង្កើតមន្ទីសារការីមួយនៅភ្នំពេញដែលអ្នកកាន់កាប់ត្រូវមានសមត្ថកិច្ច ដើម្បីចាត់ការមុខក្រសួងពេញអាណាខេត្តនៃព្រះរាជាណាចក្រកម្ពុជា។

តាមសេចក្តីស្នើសុំនៃរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គណៈរដ្ឋមន្ត្រីអាចបន្ថែមព្រះរាជក្រឹត្យតាមតម្រូវការឲ្យមន្ទីរសារការីមានចំនួនឡើងដល់ទៅ០៥នៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល។ ព្រះរាជក្រឹត្យដែលបង្កើតមន្ទីរជាថ្មី ត្រូវខណ្ឌព្រំដែននាទីសមត្ថកិច្ចនៃមន្ទីរនោះផង។ រហូតដល់ឆ្នាំ១៩៦៥ រដ្ឋាភិបាលបានបង្កើតព្រះរាជក្រឹត្យមួយទៀតលេខ ១២៩ ប.រ ដែលទ្រង់លាយព្រះហត្ថលេខាដោយ

[២] អាំង អេងថុង វិជ្ជាជីវៈសារការីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១២ ទំព័រទី១៧

សម្តេចព្រះប្រមុខរដ្ឋ ចុះថ្ងៃទី១៨ ខែមិនា គ.ស១៩៦៥ កម្រិតឲ្យមន្ទីរសារការីចំនួន០៥ កន្លែងទៀត[៣] ដូចការគ្រោងទុក គឺ៖

- មន្ទីរសារការីទី២ មាននៅរាជធានីភ្នំពេញ មានសមត្ថកិច្ចលើដែនដីក្នុងរាជធានីភ្នំពេញ និងខេត្តកណ្តាល ។
- មន្ទីរសារការីទី៣ នៅខេត្តបាត់ដំបង សម្រាប់ព្រំដែននៃដែនដីខេត្តបាត់ដំបង កំពង់ឆ្នាំង កំពង់ធំ ព្រះវិហារ ពោធិ៍សាត់ និងខេត្តសៀមរាប។
- មន្ទីរសារការីទី៤ នៅខេត្តកំពត សម្រាប់ព្រំដែននៃដែនដីខេត្តកំពត សម្រាប់ព្រំដែននៃដែនដីខេត្តកំពត កោះកុង កំពង់ស្ពឺ តាកែវ ព្រមទាំងមណ្ឌលស្វ័យយ័តភាពនៃក្រុងកែប បូកគោ គីរីរម្យ និងក្រុងព្រះសីហនុ។
- មន្ទីរសារការីទី៥ នៅខេត្តកំពង់ចាម សម្រាប់ព្រំដែននៃដែនដីខេត្តកំពង់ចាម ក្រចេះ មណ្ឌលគិរី រតនគិរី ព្រៃវែង ស្វាយរៀង និងខេត្តស្វាយរៀង។

ស្របតាមប្រការ៣ នៃព្រះរាជក្រមលេខ៩១០ ន.ស ឆ្នាំ១៩៩៤ នេះសារការីទាំងឡាយនឹងអាចធ្វើសារលិខិតជាសាធារណៈបានក្នុងមុខនាទី ក្នុងព្រំដែននៃដែនដីបានបញ្ជាក់ដូចខាងលើនេះ ស្រាប់បើពុំនោះទេសារការីនោះ នឹងត្រូវចោទប្រកាន់តាមវិធានវិន័យដែលបញ្ញត្តិក្នុងមាត្រា១៤ នៃ-ព្រះរាជក្រមលេខ៩១០ ន.ស ចុះថ្ងៃទី៤ ខែវិច្ឆកា គ.ស១៩៥៤ ។ ប៉ុន្តែព្រះរាជក្រមលេខ៩១០ ន.ស ឆ្នាំ១៩៥៤នេះ ត្រូវបានផ្អាកដំណើរការពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ដោយសារប្រទេសយើងស្ថិតក្នុងរបបខ្មែរក្រហម។ ក្រោយពីរួចផុតពីរបបនេះប្រល័យពូជសាសន៍នេះរហូតមកសព្វថ្ងៃ យើងពុំទាន់ឃើញមានបទដ្ឋានគតិយុត្តិណាចែងនិរាករណ៍ព្រះរាជក្រមនេះឡើយ តែទោះជាយ៉ាងណាក៏ដោយព្រះរាជក្រមនេះពុំត្រូវបានយកមកប្រើប្រាស់ ឬធ្វើជាបទដ្ឋានយោងក្នុងការតាក់តែងបទប្បញ្ញត្តិថ្មីៗក្រោយៗទៀត ដែលទាក់ទង់នឹងមុខងារសារការីនោះឡើយ។ ហេតុដូច្នេះយើងអាចសន្និដ្ឋានបានថា ព្រះរាជក្រមនេះត្រូវបាននិរាករណ៍ខ្លះៗដោយតុណ្ហីភាព គឺតាមរយៈការមិនយកមកប្រើប្រាស់។ បន្ទាប់មកទៀត ដោយមានតម្រូវការជាចាំបាច់ក្នុងការអនុវត្តន៍មុខងារសារការី រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតស្ថាប័នសារការីមួយតាមអនុក្រឹត្យលេខ៥០៥ អនក្រ.តត ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០១។ លោក ប៉ែន សម័យ ត្រូវបានតែងតាំងដោយអនុក្រឹត្យនេះក្នុងភាពចាំបាច់ នឹងជាបន្ទាន់នូវមុខងារបន្ថែមជាមេធាវីសារការីនៃព្រះរាជាណាចក្រកម្ពុជា ការតែងតាំងនេះត្រូវបានកំណត់ដោយរាជរដ្ឋាភិបាលជាមន្ត្រីសាធារណៈទទួលនូវមុខងារសារធារណៈ ឲ្យប្រកបវិជ្ជាជីវៈសេរីជាសារការី តម្រូវឲ្យមានទីតាំងត្រឹមត្រូវ ដើម្បីធ្វើជាមន្ទីរសារការីដែលត្រូវមានទ្រព្យធន និងមូលនិធិគ្រប់គ្រាន់សម្រាប់ធានា

[៣] អាំង អេងចុង វិជ្ជាជីវៈសារការីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១២ ទំព័រទី១៨

តម្កល់បំណុលរដ្ឋ និងសងការខូចខាតដល់អតិថិជន។ ដោយមុខងារសារការី ជាមុខងារមួយដែលស្ថិតក្នុងវិស័យច្បាប់ មុខងារនេះក៏ត្រូវបានចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងពពួកមេធាវី រហូតនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០២ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានទទួលញត្តិរបស់សមាជិក សមាជិកាមេធាវីរបស់ខ្លួន ដោយមានចុះហត្ថលេខាចំនួន១០៥នាក់ ដើម្បីស្នើដល់ក្រុមប្រឹក្សាគណៈមេធាវីបើកមហាសន្និបាតវិសាមញ្ញមួយពិសេស ស្តីអំពីមុខនាទីមេធាវីសារការីតាមអនុក្រឹត្យ ស្តីពីការផ្តល់សមត្ថកិច្ចបន្ថែម ជាសារការីដល់មេធាវីនៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជាលេខ ៥០៥ អន-ក្រ.ត.ត ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០១។ មហាសន្និបាតវិសាមញ្ញនេះ បានប្រព្រឹត្តទៅនៅសណ្ឋាគារអាំងទែរកង់ទីណង់តាល់។ ក្រោយៗមកទៀត សារការីប្រាំមួយរូបទៀតក៏ត្រូវបានតែងតាំងនាឆ្នាំ-២០១៦ ដោយរាជរដ្ឋាភិបាលក៏បានចេញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ ២០១៦ ដែលជាអនុក្រឹត្យដែលប្រកាសទទួលស្គាល់មន្ទីរសារការីដែលមានឈ្មោះថា "មន្ទីសារការីអង្គរ នៃព្រះរាជាណាចក្រកម្ពុជា"[៤]។ ហើយក៏មានបញ្ញតិមួយចំនួនទៀតទាក់ទង និងការតែងតាំងមន្ត្រីទទួលបន្ទុកសារការី ដូចជា ៨៧ កយ.ប្រក/១២ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១២។ ប្រកាសមួយទៀតទាក់ទងនឹងការកំណត់ មន្ត្រីទទួលបន្ទុកសារការីរបស់ក្រសួងយុត្តិធម៌ដែល លេខ៧២ កយ.ប្រក/១២ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២ដដែល ហើយធ្វើឲ្យប្រកាសលេខ៨៧ ត្រូវបាននិរករណ៍ដោយប្រកាសនេះ[៥]។ ហើយការវិវត្តន៍ចុងក្រោយ នៃវិជ្ជាជីវៈសារការីនៃព្រះរាជាណាចក្រកម្ពុជាយើងនេះ គឺការបង្កើតសាលាភូមិន្ទសារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ដោយអនុក្រឹត្យលេខ១១៧ អនក្រ.បកចុះ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨ និងការចាប់ផ្តើមបណ្តុះបណ្តាលសិស្សសារការីជំនាន់ទី១ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈសារការី ដែលសិស្សសារការីទាំង១៥នាក់ កំពុងបណ្តុះបណ្តាល សព្វថ្ងៃនេះត្រូវបានតែងតាំងដោយប្រកាសលេខ១៧ប្រក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ ។

ដោយសារតែប្រទេសកម្ពុជាធ្លាប់ស្ថិតនៅក្រោមអាណានិគមបារាំង ដូច្នេះប្រព័ន្ធសារការីកម្ពុជាក៏ត្រូវយកតាមប្រព័ន្ធច្បាប់ស៊ីវិល (Civil-Law system) ដែលជាប្រភពរបស់ច្បាប់រ៉ូម៉ាំង (Roman Law) ។ ហើយប្រព័ន្ធច្បាប់រ៉ូម៉ាំងនេះ មានភាពស៊ីជម្រៅជាងប្រព័ន្ធអង់គ្លេស (Common-Law system) (ដែលមានប្រភពមកពីប្រទេស អង់គ្លេស និងអាមេរិច ច្បាប់នេះអនុវត្តទៅតាមករណីយុត្តិសាស្ត្ររបស់តុលាការដែលធ្លាប់មានពីមុនមក)។

---

[៤] មាត្រា១នៃអនុក្រឹត្យនេះបានចែងថា៖ ត្រូវបានបង្កើតមន្ទីរសារការីមួយ ដែលមានឈ្មោះថា មន្ទីរសារការី អង្គរ នៃព្រះ-រាជាណាកម្ពុជា(ANGKOR Notary Public of the Kingdom of Cambodia) សរសេរកាត់ជាភាសាអង់គ្លេស "A.N.C."។

[៥] ប្រកាសលេខ៨៧ កយ.ប្រក/១២ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ត្រូវរបស់ក្រសួងយុត្តិធម៌ត្រូវទុកជានិរាករណ៍

ចំពោះគោលការណ៍នៃប្រព័ន្ធច្បាប់ស៊ីវិលវិញ រាល់លិខិតស្នាមទាំងអស់ត្រូវតែសរសេរជាលាយលក្ខណ៍អក្សរ។ ច្បាប់នេះត្រូវបានតាក់តែងតាមទម្រង់នីត្យានុកូលដើម្បីការពារ និងធានារាប់រងផលប្រយោជន៍ស្របតាមច្បាប់របស់រដ្ឋ និងប្រជាពលរដ្ឋទូទៅទាក់ទងនឹងកិច្ចសន្យា -ល- ។ មន្ទីរសារការីជាស្ថាប័នសាធារណៈ ដែលទទួលបាននូវអំណាចសាធារណៈពីរាជរដ្ឋាភិបាលក្នុងការធ្វើនីត្យានុកូលកម្ម ធ្វើលេខាចារឹក ប្រថាប់ត្រា លើឯកសារទាំងឡាយ ក្នុងគោលដៅកាត់បន្ថយនូវចំណុចវិវាទ ក្នុងរឿងក្តីតាមផ្លូវតុលាការដូចជារឿង ដីធ្លី កិច្ចសន្យា លក់ ទិញ បញ្ចាំ ជួល ផ្ទេរកម្មសិទ្ធិ និងកិច្ចសន្យាជំនួញផ្សេងៗទៀត។

ប្រវត្តិ និងការវិវត្តន៍នៃវិជ្ជាជីវៈសារការី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានបកស្រាយខាងលើនេះសបញ្ជាក់ឲយើញថា វិជ្ជាជីវៈសារការីបានកើតឡើងតាំងពីយូរយារណាស់មកហើយពោល គឺចាប់តាំងពីឆ្នាំ១៩៥៤ មកម្លេះ ហើយបន្តរហូតមកដល់បច្ចុប្បន្ន។ ហើយសារការីមានតួនាទីត្រូវការពារផលប្រយោជន៍ស្របច្បាប់របស់ភាគីទាំងអស់នៃលិខិត រួមទាំងរដ្ឋផងដោយឈរលើគោលការណ៍ឯករាជ្យ និងស្មោះត្រង់ មិនលំអៀង គោរពច្បាប់ និងក្រមសីលធម៌វិជ្ជាជីវៈខ្ពស់ ហេតុនេះហើយទើបរាល់លិខិត និងកិច្ចសន្យាធ្វើឡើយដោយសារការី ត្រូវបានផ្តល់នូវច្បាប់ នៃសារសំខាន់ជាយថាភូតដែលមានតម្លៃជាភស្តុតាងខ្ពស់និងមានកាលបរិច្ឆេទស្ពាពរ។

### ១.១.១ និយមន័យនៃពាក្យសារការី

ពាក្យថាសារការី មានន័យថា មន្ត្រីសាធារណៈ ដែលមានមុខងារធ្វើលិខិតយថាភូតបញ្ជាក់អំពីលក្ខណៈ ពិតប្រាកដត្រឹមត្រូវ ធានារ៉ាប់រងអំពីកាលបរិច្ឆេទតម្កល់ រក្សាទុក និងចេញសេចក្តីចម្លងយថាភូតនៃលិខិតទាំងឡាយណាដែលត្រូវតែឲ្យមានការបញ្ជាក់[៦]។ សារការី ជាមន្ត្រីមានភារៈខាងតែងលិខិតលក់ដូរ និងកិច្ចសន្យាផ្សេងៗឲ្យមានយថាភាពចំពោះតុលាការ។ ចំពោះលិខិតយថា-ភូតជាប្រភេទលិខិតធ្វើឡើងតាមរូមមន្តច្បាប់ដោយមន្ត្រីសារធាណៈ ដែលត្រូវបានអនុញ្ញាឲ្យប្រតិបត្តិមុខងារនោះ។ *ឧទារណោហ៍: អ៊ីប៉ូតែក ជាកិច្ចសន្យាដែលធ្វើនៅសារការី បើមិនដូច្នេះទេត្រូវទុកជាមោឃៈដាច់ខាត់។*

### ១.១.២. កំណើតនៃវិជ្ជាជីវៈសារការី

#### ក.ព្រះរាជក្រមលេខ៩១០ ន ស ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤

ដូចបានរៀបរាប់ខាងលើខ្លះហើយថាវិជ្ជាជីវៈសារការី គឺបានអនុវត្តនៅក្នុងប្រទេសយើងជាយូរណាស់មកហើយគឺតាំងពីសតវត្សទី២០មកម្លេះ ប៉ុន្តែពេលនៅយើងអនុវត្តនៅក្រោមឥទ្ធិពលនៃច្បាប់បារាំង។ ហើយបន្ទាប់មកទៀត ក៏មានការចែងពីមុខងារសារការីផងដែរ នៅក្នុងនោះក្រមរដ្ឋ-ប្បវេណីចាស់ឆ្នាំ

[៦] សទ្ទានុក្រម ផ្នែករដ្ឋប្បវេណី នៅឆ្នាំ ២០០៧ ទំព័រទី ២២

១៩៦៧ ប៉ុន្តែក្រមនេះ ពុំបានចែងឲ្យបានច្បាស់លាស់ទាក់ទងទៅនឹងសារការីនោះទេ។ បន្ទាប់មក នាឆ្នាំ១៩៥៤ ទើបយើងសង្កេតឃើញថាមុខងារ និងតួនាទីរបស់សារការីត្រូវបានលម្អិត និងពណ៌នា ច្បាស់លាស់ជាងអ្វីដែលបានចែងនៅ ក្នុងក្រមរដ្ឋបវេណីចាស់ដែលមុខងារទាំងនោះមានចែងនៅក្នុង ព្រះរាជក្រមលេខ ៩១០ ន.ស ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤។

មាត្រា១ នៃព្រះរាជក្រមលេខ៩១០ ន.ស ចុះថ្ងៃទី៤ ខែ វិច្ឆិកា ឆ្នាំ១៩៥៤ បានបញ្ញត្តិអំពីមុខ ងាររបស់សារការីថា។ សារការីជាមន្ត្រីសាធារណៈដែលតែងតាំងតាមព្រះរាជក្រឹត្យនៃរាជរដ្ឋាភិបាល ដោយមានវត្ថុបំណង៖

១. ទទួល និងធ្វើតាមលិខិត ឬកិច្ចសន្យាទាំងឡាយដែលគូសសញ្ញា ត្រូវធ្វើឲ្យមានឬចូលចិត្ត ឲ្យមានចរិតជាលក្ខណៈ តាមផ្លូវច្បាប់ដែលតែងតែមានដល់លិខិតរបស់រាជការកាន់អំណាច សាធារណៈ។

២.ធ្វើបញ្ជាក់កាលបរិច្ឆេទនៃលិខិតនេះ ទទួលរក្សាលិខិតនេះទុក និងចេញឲ្យសេចក្តីដើម ឬ សេចក្តីចម្លងលិខិតនេះ។

៣. ករណីយកិច្ចរបស់សារការី គឺបំភ្លឺឲ្យដំណឹង និងទូន្មានគូសសញ្ញា ដើម្បីពិនិត្យឲ្យដឹងថា សេចក្តីកត់ចុះក្នុងលិខិតទាំងនោះត្រឹមត្រូវតាមការពិត។

យើងទាំងអស់គ្នាឃើញថា មាត្រា១ ចំណុចទី១ នៃព្រះរាជក្រមនេះបានគូសបញ្ជាក់អំពីមុខងារ ដ៏ចម្បងជាងគេរបស់សារការី ដោយបានផ្តល់សមត្ថកិច្ច ឲ្យសារការីបំពេញមុខងាររបស់ខ្លួនក្នុងការ ផ្តល់ចារិតពេញលក្ខណៈតាមផ្លូវច្បាប់ដល់លិខិត ឬកិច្ចសន្យាទាំងឡាយពោលគឺលិខិតរបស់សារការី អាចយកមកអនុវត្តបានយ៉ាងពេញលេញ ព្រោះលិខិតនេះមានតម្លៃពេញលេញតាមផ្លូវ ច្បាប់។ ដោយផ្អែកលើលក្ខណៈយើងឃើញថា ការផ្តល់ចារិកជាលក្ខណៈតាមផ្លូវច្បាប់ដល់លិខិត ឬកិច្ចសន្យា ទាំងឡាយ គឺមានខ្លឹមសារថាជាការផ្តល់យថាភូតភាពលើលិខិតទាំងនោះ។ ព្រះរាជក្រមឆ្នាំ១៩៥៤ នេះ បានធ្វើវិវត្តពាក្យពេចន៍គតិយុត្ត នៃក្រមរដ្ឋប្បវេណីចាស់(លិខិតយថាភូត) ឬខ្លឹមសារដែលស្រដៀង យថាភូតភាពលើលិខិតនោះទេ ប៉ុន្តែដូចជាប្រើពាក្យដែលមានបានលើកឡើងដោយអក្សរជិតខាង លើទៅវិញ។លើសពីនេះទៅទៀតមាត្រា៣នៃព្រះរាជក្រមនេះ បានធ្វើការបញ្ជាក់បង្ហាញអំពីមុខងារ របស់សារការីបន្ថែមទៀតថា៖

ប៉ុន្តែទៅមុខទៀតមានតែសារការីទេ ដែលអាចបញ្ជាក់តាមទម្រង់មុខការរបស់ខ្លួននៅលិខិត គ្រប់ប្រភេទ បើកាលលិខិតនោះមានចុះទឹកប្រាក់ចំនួនប្រើនឹងលើសពី ២០០០០ រៀល។

យើងពិនិត្យឃើញថាលិខិត៣មិនបានប្រើប្រាស់ខ្លឹមសារផ្តល់យថាភូតលិខិតនោះទេ តែបាន ប្រើពាក្យជំនួសវិញ។ទោះយ៉ាងណាក៏ដោយយើងអាចធ្វើការសរុបមុខងាររបស់សារការីព្រះរាជក្រម នេះដោយខ្លីថា សារការីមានមុខងារ៖

- ផ្តល់យថាភូតភាព ទៅលើលិខិតទាំងឡាយជាពិសេស គឺរាល់លិខិតដែលមានចុះទឹកប្រាក់ចាប់ពី២០០០០០០ រៀលឡើងទៅ។
- ធ្វើការបញ្ជាក់លិខិត ទទួលរក្សាលិខិត ឬចេញសេចក្តីដើម ឬសេចក្តីចម្លងឲ្យគូភាគី។
- មានករណីកិច្ចធ្វើការបំភ្លឺ ផ្តល់ ឬលើកទស្សនៈយល់ឃើញរបស់ខ្លួនទៅគូភាគីនៃកិច្ចសន្យា។

ផ្អែកតាមលើកឡើងខាងលើ អំពីមុខងារសារការីមានចម្ងល់លើកឡើងថាតើព្រះរាជក្រមលេខ៩១០ ន.ស ឆ្នាំ ១៩៥៤នេះ នៅតែមានអនុភាព អនុវត្តមកដល់ពេលបច្ចុប្បន្នដែរឬយ៉ាងណា។

យើងមើលឃើញថាត្រូវបានបង្កើតតាំងពី ឆ្នាំ១៩៥៤មកម្លេះ។ តែពោលគឺក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩។ ក្រោយពីរួចផុតពីរបបប្រល័យពូជសាសរហូតមកដល់សព្វថ្ងៃនេះ យើងពុំឃើញមានបទដ្ឋានគតិយុត្តិណាចែង និរាករណ៍ព្រះរាជក្រមនេះឡើយ តែទោះបីជាយ៉ាងណាក៏ដោយព្រះរាជក្រមនេះពុំដែលយកមកប្រើប្រាស់ ឬជាបទដ្ឋានយោងក្នុងការតាក់តែងបទបញ្ញត្តិថ្មីៗ ក្រោយទៀតដែលទាក់ទងសារការីនោះឡើយ។ ហេតុដូច្នេះយើងអាចសន្និដ្ឋានបានថា បញ្ញត្តិមួយចំនួននៃព្រះរាជក្រមនេះត្រូវនិរាករណ៍ដោយតុណ្ហីភាព ហើយយើងក៏អាចនិយាយបានវាត្រូវបាននិរាករណ៍មិនយកមកប្រើប្រាស់។

### ខ. អនុក្រឹត្យលេខ៥០៥ អនក្រ.ត.តចុះថ្ងៃទី៨ឆ្នាំ២០០១

អនុក្រឹត្យលេខ៥០៥អនក្រ.ត.ត ស្តីពីការផ្តត់សមត្ថកិច្ចបន្ថែម ជាសារការីនៃមេធាវី នៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០០១នេះ ក៏មានផ្តល់សញ្ញាណច្បាប់ដែលទាក់ទង នឹងការផ្តល់យថាភូតដែលថ្មីត្បិតតែ អនុក្រឹត្យនេះជាប្រភេទអនុក្រឹតដែលតែងតាំងបុគ្គលក៏ពិតមែន ក៏បានឆ្លុះបញ្ជាំងពីមុខងារ និងសមត្ថកិច្ចរបស់ សារការីក្នុងការផ្ត ល់យថាភូតភាពឲ្យដល់ ប្រតិបត្តិការណ៍គតិយុទ្ធនានា ជាពិសេសក្នុងវិស័យអចលនវត្ថុ។

មាត្រា៣ នៃអនុក្រឹត្យផ្តល់សមត្ថកិច្ចការងារទូរទៅក្នុងវិស័យអចលនវត្ថុដល់មេធាវីសារការីដូចជា៖

- ទទួលនិងធ្វើឬចារិកបញ្ជាក់ និងប្រថាប់ត្រានូវលិខិតគតិយុទ្ធ ឬកិច្ចសន្យាទាំងឡាយដើម្បីជាបន្ទាល់ពេញលក្ខណៈតាមផ្លូវច្បាប់ដែលតែងតែមានិខិត របស់រាជការសាធារណៈ ធ្វើចម្លងនៃលិខិតឬកិច្ចសន្យាទាំងឡាយនោះតាមមុខការ
- កិច្ចការនេះត្រូវត្រួតពិនិត្យអានឲ្យអស់សេចក្តី និងចុះហត្ថលេខានៃគូភាគីនៅចំពោះមុខទើបសារការីចុះហត្ថលេខាប្រថាប់ត្រានៅពេលចារិកនៅពេលនោះជាចុងក្រោយ។

យើងពិនិត្យឃើញថា ចំណុចទី១ បានគូសបញ្ជាក់អំពីមុខងាររបស់មេធាវីសារការី ដែលមានសមត្ថកិច្ចក្នុងការចារិកបញ្ជាក់ និងប្រថាប់ត្រាលើលិខិតគតិយុទ្ធ ឬកិច្ចសន្យានានាដើម្បីឲ្យឯកសារទាំងនោះក្លាយជាឯកសារដែលមានលក្ខណៈតាមផ្លូវច្បាប់។

ទន្ទឹមនឹងនោះព្រះរាជក្រមលេខ៩១០ ន.ស ឆ្នាំ១៩៥៤ បានដាក់កំហិតថាបុគ្គលដែលមានសម្បទារជាសារការី ត្រូវបំពេញមុខងាររបស់ខ្លួនដែលមានមន្ទីសារការី[7]។ ការដាក់កហិតនេះដោយសារសារការីជាមន្ត្រីសាធារណៈ ដែលទទួលបានប្រតិភូកម្មពីរដ្ឋ ក្នុងការផ្តល់យថាភូត លើលិខិតកិច្ចសន្យាមួយចំនួន។ ហេតុដូច្នេះការបំពេញមុខងារនេះ សារការីត្រូវបំពេញមុខងារក្នុងនាមរដ្ឋ មិនមែនក្នុងនាមជាឯកជនទេ ដែលចាំបាច់មុខការដោយមានស្ថាប័នគ្រប់គ្រងមួយយ៉ាងជាក់លាក់ ដែលតម្រូវឲ្យមានមន្ទីសារការី។ ការកំហិតនេះក៏ទាក់ទងផងដែរ នឹងការទទួលខុសត្រូវរបស់សារការី។ យើងឃើញថា ប្រសិនបើសារការីបំពេញមុខងារក្នុងនាមខ្លួនឯងផ្ទាល់ ដោយមិនមែនជា មន្ទីច្បាស់លាស់ការទទួលខុសត្រូវ គឺកើតមានចំពោះតែលក្ខណៈបុគ្គលសារការីនោះតែប៉ុណ្ណោះ ផ្ទុយទៅវិញ ប្រសិនបើការបំពេញមុខងារ គឺស្ថិតនៅក្រោមរូបភាពជាមន្ទីសារការី ដែលបញ្ញត្តិដោយព្រះរាជក្រមនេះ ឃើញថាការទទួលខុសត្រូវគឺមានរូបភាពជាការទទួលខុសត្រូវរួមក្រោមរូបភាព ទិដ្ឋភាពជាស្ថាប័នតែម្តង។

### គ. អនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ ២០១៦

អនុក្រឹត្យលេខ៤២ ខាងលើជាអនុក្រឹត្យដែលមានចារិកលក្ខណៈជា អនុក្រឹត្យប្រកាសតែងតាំងបុគ្គលតែប៉ុណ្ណោះ មិនមែនជាអនុក្រឹត្យប្រកាសស្ថាប័ន ឬអង្គភាពអ្វីនោះទេ។ ដោយឡែកអនុក្រឹត្យ៤២ អនក្រ.បកចុះថ្ងៃទី១០ ខែ មីនា ឆ្នាំ ២០១៦ ជាអនុក្រឹត្យដែល ប្រកាសទទួលស្គាល់មន្ទីសារការី ដែលមានឈ្មោះថា មន្ទីសារការី អង្គរ នៃព្រះរាជណាចក្រកម្ពុជា។ អនុក្រឹត្យនេះបានផ្តល់តួនាទី និងភារកិច្ចសារការីតាមរយៈមាត្រា៣ដូចខាងក្រោម៖

- ទទួលធ្វើកិច្ចសន្យា ឬលិខិតគតិយុត្តទាំងឡាយដែលរូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទត្រូវការ
- ផ្តល់ប្រឹក្សាយោបល់ចំពោះកិច្ចការពាណិជ្ជកម្ម វិនិយោគ កិច្ចការគ្រួសារ និងការគ្រប់គ្រងចាត់ចែងទ្រព្យសម្បត្តិ
- ផ្តល់ការបញ្ជាក់សុពលភាពចំពោះការបង្កើត ឬកែប្រែលក្ខន្តិកៈក្រុមហ៊ុន និងនីតិបុគ្គលគ្រប់ប្រភេទ

[7] មាត្រា ៦នៃរាជក្រមលេខ ៩១០ ឆ្នាំ ១៩៥៤ ន.ស ឆ្នាំ១៩៥៤ បញ្ញត្តិថា៖លក្ខណៈត្រូវតាំងឲ្យកាន់មុខក្រសួងត្រូវបង្កើតនៅភ្នំពេញ មន្ទីសារការីមួយ ដែលអ្នកកាន់កាប់ត្រូវមានសមត្ថកិច្ច ដើម្បីចាត់ការមុខក្រសួងពេញណាខេត្តព្រះរាជាណាចក្រកម្ពុជា។

- ផ្តល់យថាភូតភាពដល់លិខិតគតិយុត្ត ឬកិច្ចសន្យា ឬឯកសារបកប្រែទាំងឡាយតាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- ស្នើសុំឲ្យស្ថាប័នអនុវត្តធ្វើការអនុវត្តដោយបង្ខំ នូវលិខិតគតិយុត្ត ឬកិច្ចសន្យាដែលទទួលបានយថាភូតភាពពីសារការី
- ទទួលបញ្ជាក់ការចម្លងត្រឹមត្រូវតាមច្បាប់ដើមនូវរាល់លិខិតគតិយុត្ត ឬកិច្ចសន្យានានាតាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- បញ្ជាក់ធានាហត្ថលេខា និងកាលបរិច្ឆេទនៃលិខិតគតិយុត្ត ឬកិច្ចសន្យានានា
- ធ្វើសំណើចុះបញ្ជី ឬចុះលេខាចារឹកទៅស្ថាប័នមានសមត្ថកិច្ច
- ទទួលតម្កល់ និងរក្សាទុកច្បាប់ដើមនៃកិច្ចសន្យា លិខិតឯកតោភាគីផ្សេងៗ មតកសាសន៍ និងលិខិតស្នាមគ្រប់ប្រភេទ
- ចេញច្បាប់ចំម្លងនៃលិខិតយថាភូត
- និងទទួលធ្វើកិច្ចការផ្សេងៗទៀត ដែលអនុញ្ញាតដោយច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន។

**ឃ. ក្រោយក្រមរដ្ឋប្បវេណី ២០០៧ ចូលជាធរមាន**

ក្រមរដ្ឋប្បវេណី ដែលប្រកាលឲ្យប្រើដោយព្រះរាជក្រមរដ្ឋវេណី ដែលប្រកាលឲ្យប្រើដោយព្រះរាជក្រមលេខណ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ និងច្បាប់ស្តីពីការអនុវត្តន៍ក្រមរដ្ឋប្បវេណី ដែលប្រកាលឲ្យប្រើដោយព្រះរាជក្រមលេខ នស /រកម/០៥១១ /០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ បានលើកឡើងអំពីលិខិតយថាភូត និងតួនាទីរបស់សារការីក្នុងមុខងារជាអ្នកធ្វើលិខិតយថាភូតព្រមទាំងមន្ត្រីទទួលបន្ទុកកិច្ចការសារការី ដែលត្រូវបានតែងតាំងដើម្បីបំពេញកិច្ចការសារការីជាបណ្តោះអាសន្ន[៨]។ ដើម្បីបំពេញកិច្ចការសារីបន្ទាប់ពីអនុវត្តក្រមរដ្ឋប្បីវេណីមក ក្រសួងយុតិធម៌បានចេញប្រកាសពីរ គឺប្រកាសលេខ ៤៧ កយ ប្រក ១២ ចុះថ្ងៃទី១៦ ខែកុម្ភះ ឆ្នាំ២០១២ និងប្រកាសលេខ ៣២កយ ប្រក ១២ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២ ស្តីពីការកំណត់មន្ត្រីទទួលបន្ទុកកិច្ចការសារការី ហើយត្រូវបំពេញកិច្ចការនេះរហូតដល់ មានច្បាប់ស្តីពីលក្ខន្តិកៈសារការី។ សរុបមកទោះបីជាមុខងារនៃវិជ្ជាជីវៈសារការី មានការវិវត្តន៍ជាច្រើនចាប់តាំងពីមានព្រះរាជក្រម៩១០ន ស.ន ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ រហូតមកដល់បច្ចុប្បន្ន ក៏មុខងារនៃវិជ្ជាជីវៈសេរីក៏ដោយមុខងារក្នុងការធ្វើលិខិតយថាភូត ផ្តល់យថាតភូតភាពចំពោះលិខិត និងកិច្ចសន្យាទាំងឡាយដែលច្បាប់បានប្រគល់ឲ្យ។ លិខិតយថាភូត នៅក្នុងជន្ទានុក្រមរដ្ឋប្បវេណីចចាស់ឆ្នាំ

[៨] មាត្រា ៩ និង មាត្រា ១០ នៃច្បាប់ស្តីពីការអនុវត្តន៍ក្រមរដ្ឋប្បវេណី ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១

១៩៦៧ និងច្បាប់ភូមិបាលឆ្នាំ១៩៩២ ព្រមទាំងច្បាប់ភូមិបាល ឆ្នាំ២០០១ បានផ្តល់និយមន័យដូចៗគ្នាថា លិខិតយថាភូត គឺជាលិខិតដែលធ្វើតាមរូបមន្តច្បាប់ ដូចជាជាលិខិតបញ្ជាក់ជាដើម។

សន្ធានុក្រមនៃក្រមរដ្ឋប្បវេណីចាស់ ព្រមទាំងច្បាប់ភូមិបាលឆ្នាំ១៩៩២ ក៏ដូចជាច្បាប់ភូមិបាលឆ្នាំ២០០១ មិនបានធ្វើការកំណត់ឲ្យបានដាច់ណាត់អំពីអត្ថន័យច្បាប់លាស់នៃ លិខិតយថាភូតនោះទេ។ សន្ធានុក្រមទាំងនេះគ្រាន់តែបានផ្តល់អត្ថន័យថា លិខិតយថាភូតជាលិខិត ដែលធ្វើតាមរូបមន្តនៃច្បាប់ដូចជា លិខិតបញ្ជាក់ជាដើម។

យោលតាមមាត្រា៩៤៥ នៃក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩៦៧បានបញ្ញត្តិអំពីលិខិតបញ្ជាក់ដែលបានសរសេរថា៖

លិខិតបញ្ជាក់ គឺសំបុត្រដែលគូភាគីបានចុះហត្ថលេខា ក្រោយដែលគេបានអានសេចក្តីសំបុត្រទាំងអស់យ៉ាងខ្លាំងៗ ដោយក្បោះក្បាយអោយភាគីស្តាប់ចំពោះមុខមន្ត្រីនៃរាជការសាធារណៈ។ មន្ត្រីនេះក្រោយដែលពិនិត្យអំពីអត្តសញ្ញាណ ការចូលមកនៃគូភាគី និងការអានលិខិតឲ្យគូភាគីស្តាប់អំពីហត្ថលេខាដែលភាគីបានចុះនោះឃើញថាត្រឹមត្រូវហើយ ទើបចុះហត្ថលេខាខ្លួនឯងក្បែរហត្ថលេខានៃគូភាគីព្រមទាំងបោះត្រាផង[៩]។

ឆ្លងតាមរយៈការបង្ហាញខាងលើ យើងអាចយល់បានថា លិខិតយថាភូតពុំត្រូវបានផ្តល់អត្ថន័យដោយមាត្រាច្បាប់ណាមួយនោះទេ។ សញ្ញាណនៃលិខិតយថាភូតនេះ គឺមានតែនៅក្នុងសទ្ទានុក្រមដែលភ្ជាប់ទៅនឹងច្បាប់ដូចបានអធិប្បាយខាងលើប៉ុណ្ណោះ។ ផ្ទុយទៅវិញ និយមន័យនៃលិខិតយថាភូតដែលបានពន្យល់នៅក្នុងសទ្ទានុក្រមទាំងនោះ មានទំនាក់ទំនងគ្នាយ៉ាងខ្លាំងនៅនឹងអត្ថន័យនៃលិខិតបញ្ជាក់ ហើយដែលលិខិតបញ្ជាក់នេះ គឺមានចែកយ៉ាងច្បាស់ទាំងខ្លឹមសារ ទាំងបែបបទនៃការអនុវត្ត ព្រមទាំងមន្ត្រីមានសមត្ថកិច្ចអនុវត្តផងដែរ។

តើលិខិតបញ្ជាក់ និងលិខិតយថាភូតមានទំនាក់ទំនងយ៉ាងដូចម្តេច?

អនុលោមតាមមាត្រា៩៤៥ នៃក្រមរដ្ឋប្បវេណីចាស់បានចែងថា៖"ប៉ុន្តែលិខិតទាំងឡាយគ្រប់ប្រភេទដែលមានដាក់តម្លៃត្រឹម ឬលើសពី២០០០០០ រៀលឡើងទៅត្រូវ តែឲ្យសារការីបញ្ជាក់តាមទម្រងនៃអាជីវកម្មរបស់អ្នក"[១០]។ ម្យ៉ាងទៀតមាត្រា៩៦១នៃក្រមរដ្ឋប្បវេណីចាស់បានចែងថា៖

[៩] តាមរយៈសទ្ទានុក្រមនៃក្រមរដ្ឋប្បវេណីចាស់បានឲ្យនិយមន័យលិខិតបញ្ជាក់ថា ជាលិខិតដែលមេឃុំ ឬ ចាហ្វាយស្រុកបានសូត្រខ្លាំងៗ ច្បាស់ៗ ឲ្យគូភាគីស្តាប់ ហើយចុះហត្ថលេខា ខ្លួនជាមួយ និងគូភាគី លើលិខិតនោះ។

[១០] មានចែកផងដែរនៅមាត្រា ៣ នៃព្រះរាជក្រម ៩១០ នសចុះថ្ងៃទី ៤ ខែវិច្ឆកា ឆ្នាំ១៩៥៤ ដែលចែងថា៖ ប៉ុន្តែតទៅមុខទៀត មានតែសារការីទេ ដែលអាចបញ្ជាក់តាមទម្រង់ការមុខក្រសួងខ្លួននូវលិខិតគ្រប់ប្រភេទ បើកាលណាលិខិតនោះមានចុះទឹកប្រាក់ចំនួនស្មើនិងលើសពី ២០០ ០០០រៀល។

(ព្រះរាជក្រម៩១០ នស ៤.១១.៥៤)ក្រៅអំពីលិខិតដែលបានបង្ហាញហើយនៅក្នុងមាត្រា៩៤៥ នឹងតទៅនោះ លិខិតទាំងឡាយដូចខាងក្រោមត្រូវចាត់ទុកជាលិខិតបញ្ជាក់ដែរ)៖

១/ លិខិតទាំងពួងដែលកុងស៊ុល ឬទូតខ្មែរធ្វើនៅបរទេសតាមរូបមន្តយថាភូតនៃសារការីខ្មែរ ក្នុងព្រំដែននៃអំណាចដែលរាជការខ្មែរ សម្រេចឲ្យធ្វើបានក្នុងរឿងនេះ។

២/ លិខិតទាំងពួង ដែលមន្ត្រីសាធាណៈបានធ្វើតាមរូបមន្តយថាភូត។ មន្ត្រីសាធាណៈគឺ សារការី ក្រឡាបញ្ជី ដែលរាជាការបារាំងបានតែងតាំងធ្វើជាសារការីផងឫដែលរាជការបារាំង បានអនុញ្ញាត ឲ្យធ្វើជាបណ្តោះអាសន្នក្រោយពី ការផ្ទេរសម្ពតកិច្ចជូនរាជរដ្ឋាភិបាលខ្មែរ ពេញ ផ្ទៃ ប្រទេស ទម្រាមមានសេចក្តីសម្រាចអំពីរឿងនេះជាថ្មី។

៣/ លិខិតយថាភូតទាំឡាយ ដែលអាជ្ញាធរបរទេសជាអ្នកមានសមត្ថកិច្ច បានធ្វើឯបរទេស តាមរូបមន្តដែលច្បាប់ខ្មែរបានបញ្ញាត្តិទុកមក។

៤/លិខិតយថាភូត ទាំងពួងធ្វើនៅប្រទេសខ្មែរដោយកុងស៊ុល ឬទូតបរទេសដែលទទួលការ តែងតាំងត្រឹមត្រូវឲ្យនៅអមព្រះរាជរដ្ឋាភិបាលខ្មែរ កាលណាបើកុងស៊ុល ឬទូតនោះប្រព្រឹត្តក្នុងមុខ ងារជាសារការី ក្នុងព្រំដែនដែលច្បាប់អន្តរជាតិសាធាណះទទួលស្គាល់ ឫដែលអនុសញ្ញាទូត ឫ កុងស៊ុលនោះនិងព្រះរាជរដ្ឋាភិបាល។

យោលតាមបទបញ្ញាត្តិនៃក្រមរដ្ឋប្បវេណីចាស់ និងព្រះរាជក្រម៩១០ន.ស ឆ្នាំ១៩៥៤ ដូច-ដែលបានលើកខាងលើនេះយើងអាចសន្នត់អំពីទំនាក់ទំនងនៃលិខិតបញ្ជាក់ និងលិខិតយថាភូតបាន ដូចខាងក្រោម៖

• ទី១ លិខិតយថាភូតដែលធ្វើឡើងដោយសារការី ជាប្រភេទនៃលិខិតបញ្ជាក់[១១]។

• ទី២ លិខិតទាំងឡាយ ដែលមានដាក់តម្លៃចាប់ពី ២០០.០០០រៀល ឡើងទៅត្រូវបញ្ជាក់ ដោយសារការី។ ត្រង់នេះអាចអោយយើងសន្និដ្ឋានបានថា លិខិតទាំងឡាយដែលបំពេញលក្ខខណ្ឌ បែបនេះគឺជា លិខិតយថាភូត។ រីឯលិខិត ដែលមានដាក់តម្លៃក្រោម២០០.០០០រៀល ជាលិខិត បញ្ជាក់ដែលត្រូវបញ្ជាក់ ដោយអាជ្ញាធរមូលដ្ឋាន(ចៅហ្វាយស្រុក ឫមេឃុំ)។

ប៉ុន្តែ បើផ្អែកលើធរមានបញ្ញត្តិបច្ចុប្បន្ន យើងមិនអាចធ្វើការបែងចែកភាពខុសគ្នារវាងលិខិត បញ្ជាក់ និងលិខិតយថាភូតឡើយ ដោយសារតែពុំមានបញ្ញញត្តិណាមួយចែងឲ្យបានច្បាស់លាស់ អំពីភាពខុសគ្នានេះឡើយ។

[១១] មាត្រ ៩៦១ នៃក្រនីតិវិធីរដ្ឋប្បវេណី

ម្យ៉ាងទៀតបើយើងពិនិត្យមើលសញ្ញាណនៃលិខិតយថាភូតនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ដែលនៅជាធរមាន នឹងកំពុងអនុវត្តនៅពេលបច្ចុប្បន្ននេះ ក៏ពុំឃើញមានបទប្បញ្ញត្តិនៃមាត្រាណាមួយផ្តល់និយមន័យដល់លិខិតយថាភូតនោះទេ។

ក៏ដូចជាច្បាប់មុនៗដែរ លិខិតយថាភូតត្រូវបានកំណត់អត្ថន័យនៅក្នុងសន្ទានុក្រម ផ្នែករដ្ឋប្បវេណីនៃក្រមនេះដោយបានកំណតខ្លឹមសារថា ៖លិខិតយថាភូត ជាលិខិតធ្វើតាមរូបមន្តច្បាប់ ដោយមន្ត្រីសាធារណៈ ដែលត្រូវបានអនុញ្ញាតប្រតិបត្តិមុខងារនោះ។ តាមន័យចង្អៀត លិខិតយាថាភូត គឺជាលិខិតទាំងឡាយដែលរៀបចំឡើងដោយសារការី។

ប្រហាក់ប្រហែលនឹងអត្ថន័យ ដែលផ្តល់ឲ្យអោយដោយសន្ទានុក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ខាងលើ សន្ទានុក្រមបារាំងខ្មែរនៃពាក្យច្បាប់របស់សាកលវិទ្យាល័យ ភូមិន្ទនិតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបានឲ្យនិយមន័យ នៃលិខិតយថាភូតថា៖ លិខិតយថាភូត ជាលិខិតលាយលក្ខ័អក្សរដែលធ្វើឡើងដោយមន្ត្រីសាធារណៈដូចជាសារការីជាដើម។ សេចក្តីអំណះអំណាងរបស់មន្ត្រីនេះក្នុងលិខិតមានតម្លៃខ្ពស់បំផុត ដែលគេត្រូវជឿទុកចិត្តថាត្រឹមត្រូវលើកលែងតែមានការប្តឹងចោទប្រកាន់ជាមុនថាជាលិខិតក្លែងក្លាយ។ លិខិតយថាភូតអាចអនុវត្តដោយបង្ខំបាន[១២]។

តាមរយៈការលើកឡើងខាងលើ យើងឃើញថាទោះបីជាមានការផ្តល់អត្ថន័យ នៃលិខិតយថាភូតដោយឈរលើមូលដ្ឋាន នៃការវិវត្តន៍ច្បាប់តាំងពីក្រមរដ្ឋប្បវេណីចាស់ ព្រះរាជក្រមលេខ ៩១០ឆ្នាំ ១៩៥៤ ច្បាប់ភូមិបាល ឆ្នាំ១៩៩២ ច្បាប់ភូមិបាល២០០១ ព្រមទាំងក្រមប្រពៃណីឆ្នាំ២០០៧ យ៉ាងណាក៏ដោយការកំណតអត្ថន័យលិខិតយថាភូតទាន់មានឯកសណ្ឋានមួយពិតប្រាកដ និងពុំមានវិសាលភាពច្បាស់លាស់នៅឡើយ។ ទន្ទឹមនឹងនេះដែរពាក្យលិខិតយថាភូតនៅក្នុងសប្បទានុក្រមនៃក្រមរដ្ឋប្បវេណីថ្មី២០០៧ ក៏បានលើកឡើងស្រដៀងគ្នា សប្បទានុក្រមនៃរដ្ឋប្បវេណីចាស់ឆ្នាំ១៩៦៧ ច្បាប់ភូមិបាលឆ្នាំ១៩៩២ ក៏ដូចជាច្បាប់ភូមិបាលឆ្នាំ២០០១ផងដែរ ត្រង់ចំណុចដែលថាលិខិតយថាភូតជាលិខិតធ្វើឡើងតាមរូបមន្តនៃច្បាប់។

## ១.២. លក្ខខណ្ឌដើម្បីបានទទួលមុខងារជាសារការី

បើយើងក្រឡេកមើលចាប់តាំងពីការកកើតសារការីមក ពោលគឺចាប់តាំងពីមុនមានក្រមរដ្ឋប្បវេណីចាស់មករហូតមកដល់បច្ចុប្បន្ន គេពុំទាន់ឃើញមានបញ្ញត្តិណាចែងជាក់លាក់អំពីលក្ខខណ្ឌដើម្បីទទូលបានពីមុខងារសារការីនោះទេ ក្រៅពីរាជក្រមលេខ ៩១០ ន.ស ចុះថ្ងៃទី ០៤ វិច្ឆិកា ឆ្នាំ ១៩៥៤។

[១២] មាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៧

មាត្រា៧ នៃរាជក្រមលេខ៩១០ ន.ស ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ១៩៥៤ បេក្ខជនដែលសមកាន់តមណែងជាសារការីត្រូវមាន សញ្ជាតិខ្មែរ មានសិទ្ធិជាពលរដ្ឋ និង នយោបាយ ហើយត្រូវមានអាយុចាប់ពី ៣០ឆ្នាំយ៉ាងតិច មានសញ្ញាបត្រច្បាប់ ឬថ្នាក់បណ្ឌិតច្បាប់ មានបទពិសោធន៍ការងារយ៉ាងតិច២(ពីរ) ឆ្នាំនៅក្នុង មន្ទីសារការីដែលតាំងនៅប្រទេសខ្មែរ ឬ ប្រទេសណាមួយក្នុង សហភាពបារាំង។

ចំពោះបេក្ខជនដែលមានសមត្ថភាពច្បាប់ ឬមានសញ្ញាបត្រសមមូល និងសមត្ថភាពច្បាប់ ព្រមទាំងបេក្ខជនដែលមាន សញ្ញាបត្រវិជ្ជាស្ថានយុត្តិធម្មសាស្ត្រ និងសេដ្ឋកិច្ចរបស់ជាតិ[១៣] រយៈពេលនៃបទពិសោធន៍ត្រូវមានយ៉ាងតិច៥ឆ្នាំ (មាត្រា៨ ស្តីពីអន្តរបញ្ញត្តិ)។

ទី១. ក្នុងរយៈពេល៣ឆ្នាំ ចាប់ពីដែលព្រះរាជក្រមនេះចូលជាធរមាន រាជរដ្ឋាភិបាលអាចតែងតាំងឲ្យកាន់តំណែងសារការី ដោយមិនគិតនៅបទពិសោធន៍នៅបេក្ខជនណា ដែលបានបំពេញលក្ខខណ្ឌ អាយុ សញ្ជាតិ និងសីលធម៌ពេញបរិបូណ៌ តាមមាត្រា៧ ខាងលើនេះ ហើយឲ្យបេក្ខជននោះត្រូវមានសញ្ញាបត្រផង។

ទី២. បេក្ខជនណាដែលមានត្រឹមសញ្ញាបត្រ សមត្ថភាពច្បាប់ ឬមានសញ្ញាបត្រសមមូល និងសមត្ថភាពច្បាប់ អាចតែងតាំងក្នុងតំណែងសារការីក្នុងកំណត់ពេល៥ឆ្នាំ ហើយបេក្ខជននោះទុកជាបានបំពេញលក្ខខណ្ឌ អាយុ សញ្ជាតិ និង សីលធម៌ពេញបរិបូណ៌តាមធម្មតា។ លុះផុតរយៈពេល៥ឆ្នាំ ហើយបេក្ខជននេះទុកជាបានបំពេញសមត្ថកិច្ច មានបទពិសោធន៍ដោយហាត់ធ្វើការ ហើយត្រូវតែងតាំងបេក្ខជននោះអស់មួយជីវិត។

ទី៣. បេក្ខជនណាដែលគ្មានសញ្ញាបត្រ តែត្រូវបានបញ្ជាក់ថាបានធ្វើការប្រកបដោយវិជ្ជាជីវៈចំនួន១៥ឆ្នាំ ក្នុងក្របខណ្ឌជាន់ខ្ពស់ ក្នុងរាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា អាចត្រូវតែងតាំងជាសារការីក្នុងរយៈពេល៥ឆ្នាំ។ លុះចប់រយៈពេល៥ឆ្នាំហើយ អាចធ្វើការតែងតាំងជាថ្មីបាន ប្រសិនបើបេក្ខជននោះបានពេញលក្ខខណ្ឌ អាយុ សញ្ជាតិ និង សីលធម៌ពេញបរិបូណ៌។ បេក្ខជនជំពូកនេះអាចតែងតាំងអស់មួយជីវិតបានប្រសិនបើជាខ្លួនមានសញ្ញាបត្រសមត្ថភាពច្បាប់ ឬសញ្ញាបត្រសមមូលនឹងសមត្ថភាពច្បាប់រយៈពេល៥ឆ្នាំ ដែលបានតែងតាំងខ្លួនជាបណ្តោះអាសន្ន។ ការតែងតាំងអស់មួយជីវិត មិនអាចធ្វើបានទេបើសាមីខ្លួន មិនទាន់ធ្វើជាមេមន្ទីសារការី រយៈពេល៥ឆ្នាំនោះ។

[១៣] វិជ្ជាស្ថានយុត្តិធម្មសាស្ត្រ និងសេដ្ឋសាស្ត្ររបស់ជាតិ (INEJE) គឺបង្កើតឡើងមុនមហាវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ក្រោយមកបាបលុបចោល ជំនួសដោយមហាវិទ្យាល័យក្រោយនេះវិញនាឆ្នាំ១៩៥៩។

តាមមាត្រា៩ ការតែងតាំងសារការីត្រូវធ្វើតាមព្រះរាជក្រឹត្យ តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ ព្រះរាជក្រឹត្យនេះត្រូវ ត្រូវកំរិតប្រាក់ធានា ដែលមេមន្ទីត្រូវបង់មុន នឹងទទួលសម្បថសច្ចាប្រណិធានផង ។ តាមព្រះរាជក្រមលេខ ៩១០ ប្រាក់ធានាត្រូវបានកម្រិតដូចខាងក្រោមនេះ ៖

១.ដាក់ប្រាក់ធានា ៥០០.០០០រៀល ក្នុងគណនីឃ្លាំងធានាគារ ឬគ្រឹះស្ថានចងការប្រាក់ដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានអនុញ្ញាត

២.បញ្ជាក់ថា ខ្លួនមានអសង្ហារឹមនៅប្រទេសខ្មែរ ផុតចាកពីការដាក់ធានាបញ្ចាំ និងការបញ្ចាំទាំងអស់ អាចបញ្ចាំជាតម្លៃតាមក្បួនប្រថាប់ត្រាបានយ៉ាងតិច ១.០០០.០០០រៀល មុននឹងទទួលសម្បថសច្ចាប្រណិធាន សាមីខ្លួនត្រូវដាក់បញ្ចាំអសង្ហារឹមនេះ ជាប្រយោជន៍ឃ្លាំងប្រាក់ជាតម្លៃ ១.០០០.០០០រៀល ។

ប៉ុន្តែដោយបញ្ញត្តិមួយចំនួននៃព្រះរាជក្រមនេះមិនត្រូវបានគេយកមកអនុវត្ត រហូតមកដល់បច្ចុប្បន្ននេះទេ បើទោះបីជាគ្មានបញ្ញត្តិណានិរាករណ៍។ ជាក់ស្តែងក្នុងពេលបច្ចុប្បន្ន ការទទួលបានមុខងារសារការីមានពីរ គឺសារការីអាចទទួលបានតាមរយៈការប្រឡងជ្រើសរើស និងការទទួលបានមុខងារសារការីដោយការតែងតាំង។

### ១.២.១. សារការីតាមរយៈការប្រឡងជ្រើសរើស

#### ១.២.១.១. លក្ខខណ្ឌនៃការប្រឡង

សាលាភូមិន្ទសារការីនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវបានបង្កើតឡើងតាមអនុក្រឹត្យលេខ ១១៧ អនក្រ បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨ ដែលមានបេសកម្មធ្វើការបណ្តុះបណ្តាលបន្តសម្រាប់សារការី។

ដើម្បីទទួលបាននៅការបណ្តុះបណ្តាលនៅសាលាសារការីបាន គេត្រូវឆ្លងកាត់ការបំពេញបែបបទ និងលក្ខខណ្ឌនៃការប្រលងប្រជែងជ្រើសរើសសិស្សសារការីជាមុនសិន។ បែបបទ និងលក្ខខណ្ឌនៃការប្រលងប្រជែងសិស្សសារការីមានដូចខាងក្រោម៖

- បេក្ខជនទាំងពីរភេទត្រូវមានសញ្ជាតិខ្មែរ ចំពោះបេក្ខជនជានិស្សិត ត្រូវមានអាយុមិនលើសពី ៣៥ឆ្នាំ ម្យ៉ាងវិញទៀតបេក្ខជនជាមន្ត្រីរាជការត្រូវមានអាយុមិនលើសពី ៥០ឆ្នាំ គិតមកត្រឹមថ្ងៃប្រលង
- ត្រូវមានបរិញ្ញបត្រនីតិសាស្ត្រឡើងទៅ
- ត្រូវមានលិខិតថ្កោលទោសបញ្ជាក់ថា មិនធ្លាប់មានទោសពីបទមជ្ឈឹម ឬបទឧក្រិដ្ឋ
- ត្រូវមានកាយសម្បទាគ្រប់គ្រាន់
- ការប្រលងប្រជែងជ្រើសរើសសិស្សសារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការត្រូវបាន

ចែកចេញជាពីរដំណាក់កាលគឺ

**១.ដំណាក់កាលទី១៖ វិញ្ញាសារសរសេរ(វិញ្ញាសារបង្ខំ)** ដែលមានមុខវិជ្ជា នីតិកាតព្វកិច្ច និងកិច្ចសន្យា នីតិអចលនទ្រព្យ នីតិជំនួញ និងភាសាបារាំង។

**២.ដំណាក់កាលទី២៖ វិញ្ញាសារ សួរផ្ទាល់មាត់(វិញ្ញាសារជ្រើសរើស)** ដែលមានមុខវិជ្ជា នីតិគ្រួសារ នីតិពាណិជ្ជកម្ម នីតិអចលនទ្រព្យ និងនីតិរដ្ឋបាល។ បេក្ខជនត្រូវជ្រើសរើសមួយក្នុងចំណោមមុខវិជ្ជាទាំងអស់ខាងលើ សម្រាប់ឆ្លើយនិងសំណួររបស់គណៈមេប្រយោគ។ ប្រសិនបើយល់ឃើញថាមានការចាំបាច់ នោះគណៈមេប្រយោគអាចសួរសំណួរបន្ថែម ទៅបេក្ខជនលើមុខវិជ្ជាបីផ្សេងទៀតដែលនៅសល់។

ទាំងអស់នេះ គឺជាវិញ្ញាសារប្រឡងដើម្បីបានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈសារការី នៅសាលាភូមិន្ទសារការី។

បន្ទាប់ពីបានទទួលលទ្ធផលប្រឡងជាប់ហើយនោះសិស្សសារការី របស់សាលាភូមិន្ទសារ-ការីនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវឆ្លងកាត់ការបណ្តុះបណ្តាលរយៈពេល៣០ខែ បន្ទាប់ពីបានប្រលងជាប់នៅវិញ្ញាសារ ដែលបានដាក់ជូនដើម្បីមានសិទ្ធិទទួលការបណ្តុះបណ្តាលនេះ។ ការបណ្តុះបណ្តាលចែកចេញជាពីរដំណាក់កាល៖

- ដំណាក់កាលធ្វើសិក្ខាគារិកមានរយៈពេល១២ខែ
- ដំណាក់កាលធ្វើកម្មសិក្សា មានរយៈពេល១៨ខែ

**១.២.១.២. បណ្តុះបណ្តាលបឋម៖**

ការសិក្សានៅក្នុងកម្មវិធីបណ្តុះបណ្តាលសារការី គឺយើងមានរយៈពេល ២ឆ្នាំ និង៦ខែ ហើយនៅក្នុងដំណាក់កាលនៃការបណ្តុះបណ្តាលបឋមគឺមានរយៈពេល ១ឆ្នាំស្មើ និង៤ត្រីមាស ហើយកម្មសិក្សា និងការជួបជុំប្តូរបទពិសោធន៍ ។ ចំពោះការសិក្សាទៅលើក្នុងត្រីមាសនីមួយៗមានមុខវិជ្ជាសិក្សាមិនតិចជាង៦មុខវិជ្ជានោះទេ ហើយនៅក្នុងត្រីមាសទី១ដែលត្រូវសិក្សាអំពីនីតិទូទៅ ដែលជាមូលដ្ឋាននៃការសិក្សាដំបូង ។

**ក.ត្រីមាសសិក្សាអំពីនីតិទូទៅ**

នៅក្នុងការសិក្សាក្នុងត្រីមាសទ១ គឺសិក្សាទៅលើនីតិទូទៅ មានមុខវិជ្ជាចំនួន ៦មុខវិជ្ជារាប់ទាំងការសិក្សាទៅលើភាសាបារាំង និងសិក្ខាសាលាផងដែរ ។ ហើយមុខវិជ្ជាដែលត្រូវសិក្សានោះមានដូចជា នីតិកាតព្វកិច្ច, កិច្ចសន្យាពិសេស, ស្ថាប័នតុលាការ, ស្ថានប័នរដ្ឋបាល, សញ្ញាណនានាស្តីពីបច្ចេកទេសអនុវត្តក្នុងវិជ្ជាជីវៈសារការី (លិខិតសារការីក្រមសីលធម៌ការទទួលខុសត្រូវរបស់

សារការី), នីតិវិធីអនុវត្តសេចក្តីសម្រេច, ភាសាបារាំង, និងសិក្ខាសាលា ដែលមុខវិជ្ជាទាំងអស់ខាងលើគឺចំនាយពេលអស់ប្រមាណជា ២២០ម៉ោង ក្នុងការសិក្សាក្នុងត្រីមាសទី១។

### ខ.ត្រីមាសសិក្សាអំពីនីតិគ្រួសារ

ចំពោះនៅក្នុងត្រីមាសទី២វិញ គឺសិក្សាទាក់ទងទៅ និងនីតិគ្រួសារ ដែលសិក្សាត្រឹមតែ ៥ មុខវិជ្ជា ប៉ុន្តែប្រើពេលវេលាអស់ ២២០ម៉ោង នេះមិនទាន់រាប់ ការសិក្សាទៅលើភាសាមួយមុខទៀតនោះទេ ដែលពេលវេលានេះចំណាយច្រើនជាងការសិក្សានៅឆមាសទី១ ថែមទៀតផង ហើយមុខវិជ្ជាដែលត្រូវសិក្សានៅក្នុងឆមាសទី២ នេះមានដូចជា នីតិបាតិបុគ្គល, អសមត្ថជន, នីតិរបបមាតិភណ្ឌ , នីតិសន្តតិកម្ម និងសន្ទានទាន, នីតិគ្រួសារ( សិក្សាពីទិដ្ឋភាពជម្រះបញ្ជីមាតិកភណ្ឌ និងមរតក), និង ភាសាបារាំង ។

### គ. ត្រីមាសសិក្សាអំពីនីតិអចលនទ្រព្យ

នៅក្នុងត្រីមាសទី៣វិញ គឺសិក្សាទៅលើនីតិអចលនទ្រព្យដែលនៅក្នុងត្រីមាសទី២ និងទី៣ គឺកាន់ដែលស៊ីជម្រៅទៅលើជំនាញដែលខុសពីឆមាសទីមួយគឺសិក្សាទៅលើតែអ្វីដែលពាក់ពន្ធ័ និងនីតិទូទៅ ហើយនៅក្នុងត្រីមាសទី៣ នេះគឺយើងសិក្សាទៅលើ ៥មុខវិជ្ជា និង ២២០ម៉ោង ដែលក្នុងនោះមានមុខវិជ្ជាដូចជា នីតិអចលនទ្រព្យ, កម្មសិទ្ធិលើអចលនទ្រព្យ, នីតិឥណទានលើអចលនវត្ថុ, នីតិប្រតិភោគ, នីតិសាងសង, នីតិនគរូបនីយកម្ម, និងភាសាបារាំង ។

### ឃ. ត្រីមាសសិក្សាអំពីនីតិជំនួញ

នៅត្រីមាសទី៤ ជាត្រីមាសចុងក្រោយនៃរយៈពេលមួយឆ្នាំ ដែលត្រីមាសនេះគឺជាត្រីមាសដែលសំខាន់ផងដែរ ពីព្រោះសិក្សាទៅលើមុខជំនាញ នីតិជំនួញ ដែលបច្ចុប្បន្ននៅប្រទេសកម្ពុជាយើងក៏កំពុងអភិវឌ្ឍផ្នែកជំនួញនេះយ៉ាងខ្លាំងផងដែរ ដោយប្រទេសកម្ពុជា ជាប្រទេសបែបទីផ្សារសេរីដូច្នេះហើយគឺមានក្រុមហ៊ុនបរទេសជាច្រើនមកវិនិយោគទុនជាច្រើន ដូច្នេះត្រីមាសចុងក្រោយនេះគឺជាត្រីមាសដែលសំខាន់ព្រោះត្រីមាសនេះ គឺសិក្សាទៅលើមុខវិជ្ជាដូចជា នីតិពាណិជ្ជកម្ម(មូលនិធិពាណិជ្ជកម្ម និងប្រតិបត្តិការដែលពាក់ពន្ធភតិសន្យាពាណិជ្ជកម្ម), នីតិក្រុមហ៊ុន, នីតិព្រហ្មទណ្ឌនៃជំនួញ, ទម្រង់បែបបទ និងពន្ធដាសរការី(អចលនវត្ថុពាណិជ្ជកម្មគ្រួសារ), ភាសារបារាំង, និងសិក្ខាសាលាផងដែរ។ ហើយសម្រាប់ម៉ោងនៃការសិក្សានៃត្រីមាសចុងក្រោយនេះក៏មានច្រើនជាង ៣ត្រីមាសខាងលើផងដែរ គឺសរុបទាំងអស់នោះគឺ ២៧០ម៉ោង រាប់ទាំងសិក្ខាសាលាដែលមានចំនួន ១៥ម៉ោង។

### ១.២.១.៣. កម្មសិក្សា និងការជួបជុំផ្លាស់ប្តូរបទពិសោធន៍

**ក.ការសិក្សា និងការបណ្តុះបណ្តាលផ្លាស**

- កម្មសិក្សារយៈពេល៦ខែនៅតាមបណ្តាលមន្ទីសារការីនៅប្រទេសបារាំង
- ការបណ្តុះបណ្តាលផ្លាស់រយៈពេល៩ខែ នៅប្រទេសកម្ពុជា(រៀនមួយថ្ងៃនៅសាលាភូមិន្ទសារការី ចុះកម្មសិក្សា៤ខែ)
    - កម្មសិក្សាចំនួន៨៦៤ម៉ោងនៅតាមបណ្តោយស្ថាប័ននានា (រដ្ឋលសុរិយោដីរដ្ឋបាលពន្ធដារ អាជ្ញាធរដែនដីជាដើម)
    - នីតិសាងសង និងនគរូបណីយកម្ម
    - (ឯកសារនគរូបណីយកម្មលិខិតអនុញ្ញាតសាងសងជាដើម)
    - នីតិសាពើពន្ធ(សារពើពន្ធអចលនវត្ថុប្រថាប់ត្រាចុះបញ្ជីជាដើម)
    - ឯកសាររដ្ឋបាល (សំបុត្រកមណើតជាដើម)
    - ភាសាបារាំង

**ខ.ការជួបជុំផ្លោះប្តូរបទពិសោធន៍**

- នៅពេលចាប់វគ្គបណ្តុះបណ្តាលការណែនាំឲស្វែងយល់ពីច្បាប់ថ្មីៗ
- នៅពេលត្រលប់ពីកម្មសិក្សានៅប្រទេសបារាំង៖ វិភាគអំពី ការសិក្សាអំពីការអនុវត្តជាក់ស្តែងខាងផ្នែកសារការីដោយភ្ជាប់ទៅ និងការបច្ចេទក្នុងស្រុក។

នេះគឺជាការបណ្តុះបណ្តាល ដើម្បីទទួលបានមុខងារ ក៏ដូចជាតួនាទីជាសារការីតាមរយៈការប្រឡងចូលសាលាភូមិន្ទវិជ្ជាជីវៈសារការី។

### ១.២.១.៤. ការតែងតាំងនូវមុខងារសារការីដល់សិស្សដែលបានបញ្ចប់ការសិក្សា

យោងតាមប្រកាសលេខ ១៧ ប្រក ចុះថ្ងៃ២៨ ខែកុម្ភៈ ឆ្នាំ២០១៣របស់ទីស្តីការគណៈរដ្ឋមន្ត្រីអំពីការតែងតាំងសិស្សសារការីជំនាន់ទី១ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការដែលមានចំនួន១៥នាក់[១៩] បានបញ្ជាក់ឲ្យឃើញថា ព្រះរាជាណាចក្រកម្ពុជាយើង ទើបតែនឹងបង្កើតឲ្យមានការបណ្តុះបណ្តាលវិជ្ជាជីវៈសារការីនេះឡើងដើម្បីរួមចំណែកក្នុងការពង្រឹងវិស័យយុត្តិធម៌។ ម្យ៉ាងវិញទៀតសបញ្ជាក់ឲ្យឃើញថា សិស្សសារការីទាំងអស់ក្រោយពីការបំពេញគ្រប់លក្ខខន្តិកៈក្នុងការសិក្សាហើយ ទោះបីជាសិស្សសារការីបានប្រឡងបញ្ចប់ការវគ្គបណ្តុះបណ្តាលដែលសាលាភូមិន្ទសារការីបានកំណត់ហើយក៏ដោយ ក៏សិស្សសារការីមិនទាន់ខ្លាចខ្លួនជាមន្ត្រីសារការីពេញសិទ្ធិនៅឡើយ លុះត្រាតែមានការតែងតាំងដោយ

[១៩] ប្រការ១ នៃប្រកាសលេខ ១៧ ប្រក ចុះថ្ងៃ២៨ ខែកុម្ភៈ ឆ្នាំ២០១៣របស់ទីស្តីការគណៈរដ្ឋមន្ត្រីអំពីការតែងតាំងសិស្សសារការីជំនាន់ទី១ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

ប្រកាសនៃទីស្ដីការគណៈរដ្ឋមន្ត្រីទើបខ្លាចខ្លួនជាមន្ត្រីសារការីពេញសិទ្ធិ និងអនុវត្តន៍នៅសិទ្ធិកាតព្វកិច្ចរបស់មន្ត្រីសារការីបាន។

### ១.២.២. ការទទួលបានមុខងារសារការីតាមរយៈការតែងតាំង

ដោយមានតម្រូវការជាចាំបាច់នូវមន្ត្រីសារការី ក្នុងការប្រត្តិបត្តិការនានាលើវិស័យអចលនវត្ថុ នឹងវិសយ័ដែលពាក់ព័ន្ធ ដែលតម្រូវឲ្យមាន ការទិញលក់ ការជួល ការធ្វើមរតកសាសន៍ ដែលទាមទារឲ្យមានការផ្ដល់យថាភូតដោយមន្ត្រីសារការី ដើម្បីឲ្យមានសុពលភាព។ សព្វថ្ងៃនេះ ពុំទាន់មានសារការីគ្រប់គ្រាន់នៅក្នុងប្រិត្តិបត្តិការទាំងនោះផង ដូច្នេះហើយទើបរាជរដ្ឋាភិបាលបានចេញអនុក្រឹត្យ៥០៥ អនក្រ/តតចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០១ តែងតាំងលោក ប៉ែន សុនសម័យ ដែលជាសមាជិកមេធាវី របស់គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា នូវមុខងារបន្ថែមជា មេធាវីសារការីដំបូងគេបង្អស់ ។ នាពេលបច្ចុប្បន្នមានមេធាវីជាច្រើនបានខ្លាចខ្លួនជាសារការី ឬជាមេធាវីសារការីមិនតែប៉ុណ្ណោះមន្ទីសារការីក៏បានកកើតឡើងជាបន្តបន្ទាប់ផងដែរ។មេធាវីសារការីជាមន្ត្រីសារធារណៈទទួលបាននៅអំណាចតាមការតែងតាំងនៃអនុក្រឹត្យ ។ ហើយត្រូវបានកំណត់ដោយរាជរដ្ឋាភិបាលជារដ្ឋមន្ត្រីសាធារណៈទទួលមុខងារជាសាធារណៈ ឲ្យប្រកបវិជ្ជាជីវៈសេរីជាសារការីហើយតម្រូវឲ្យមានទីតាំងត្រឹមត្រូវ ដើម្បីធ្វើជាមន្ទីសារការីមានទ្រព្យធន នឹងមូលនីធិគ្រប់គ្រាន់សម្រាប់ធានាបំណុលរដ្ឋ និងការខូចខាតដល់អតិថិជន។ មួយវិញទៀត តម្រូវអោយតម្កល់ប្រាក់ធានាសំណងមួយចំនួនធំ នៅធានាគារជាតិនៃកម្ពុជាដែលចែងក្នុងបញ្ញត្តិនៃមាត្រា៤ នៃអនុក្រឹត្យនេះ មេធាវីសារការីត្រូវតម្កល់ប្រាក់ធានាចំនួន ៦០០,០០០,០០០ ( ប្រាំមួយរយលានរៀល ) នៅធានាគារជាតិនៃកម្ពុជាសម្រាប់ទទួលខុសត្រូវក្នុងមុខងារនេះ។ ជាមួយគ្នានេះដែរយោងតាមព្រះរាជក្រមលេខ ៩១០ ន.ស ចុះថ្ងៃទី៤ ខែវិច្ឆកា ឆ្នាំ១៩៥៤ និងការសង្កេតឃើញជាក់ស្ដែង មេធាវីដែលដែលទទួលបានមុខងារជាសារការីបន្ថែម សុទ្ធសឹងជាសមាជិកនៃគណៈមេធាវីដែលពោពេញទៅដោយបទពិសោធន៍ចំណេះដឹងផ្នែកច្បាប់យ៉ាងទូលំទូលាយ និងបានបំពេញលក្ខណៈអាយុ សញ្ជាតិ នឹងសីលធម៌បរិបូណ៌។

នេះគឺជាការទទួលបានមុខងារមេធាវីសារការី ដោយការតែងតាំងដោយអនុក្រឹត្យនេះទៅអោយសមាជិកមេធាវីនៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជាដើម្បីបំពេញមុខងារជាសារការីដើម្បីបំពេញសេចក្ដីត្រូវការនៅមុខងារសារការីនេះនៅក្នុងសង្គម ។

ទោះបីជាមានការតែងតាំងខាងលើនេះហើយក៏ដោយ ក៏សារការីនៅតែមានចំនួនមួយតិចនៅឡើយ បើប្រៀបធៀបទៅនឹងសេចក្ដីត្រូវការរបស់សង្គមនៅមុខងារនេះ។ ដោយមើលឃើញនូវកង្វះខាតនៃសារការី ដើម្បីបំពេញមុខងារនេះនៅក្នុងជីវភាពប្រចាំថ្ងៃនោះ រដ្ឋាភិបាលក៏បានចេញ

អនុក្រឹត្យមួយទៀតលេខ១៩៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៨ ទទួលស្គាល់**មន្ទីសារការី អេច ប៊ី អេស** នៃព្រះរាជាណាចក្រកម្ពុជា។ ដោយអនុក្រឹត្យនេះ បានតែងតាំងសារការី ចំនួនពីររូបទៀត។ មន្ទីរសារការីនេះមានទីតាំងស្ថិតនៅអគារពាណិជ្ជកម្ម សូម៉ា ផ្លូវលេខ ១២០ សង្កាត់ផ្សារថ្មីទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ[១៥]។ ហើយមន្ទីរសារការីនេះត្រូវដឹកនាំដោយ សារការី លី តែសេង ជាប្រធាន និង សារការី **តាន់ ហ៊ាង ដាវ័ណ្ណ**[១៦]។

អនុក្រឹត្យនេះក៏តម្រូវផងដែរ នូវការដាក់ប្រាក់តម្កល់ចំនួន ៦០០.០០០.០០០ លានរៀល នៅរតនាគារជាតិនៃកម្ពុជា សម្រាប់ធានាការទទួលខុសត្រូវក្នុងការបំពេញភារកិច្ចរបស់ខ្លួន[១៧]។

នេះគឺជាការទទួលមុខងារជា សារការីដោយអនុក្រឹត្យតែងតាំង ពីសំណាក់រាជរដ្ឋាភិបាល ដើម្បីទទួលបានមុខងារ ក៏ដូចជាបង្កើតមន្ទីសារការីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

[១៥] មាត្រា២ នៃអនុក្រឹត្យលេខ ១៩៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៨

[១៦] មាត្រា៤ នៃអនុក្រឹត្យលេខ ១៩៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៨

[១៧] មាត្រា៥ នៃអនុក្រឹត្យលេខ ១៩៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៨

# ជំពូកទី២

# សិទ្ធិ និងភារកិច្ចរបស់សារការី

# ជំពូកទី២
# សិទ្ធិ និងភារកិច្ចរបស់សារការី

## ២.១. សិទ្ធិរបស់សារការី

### ២.១.១. ផ្តល់ប្រឹក្សាយោបល់

យោងតាមមាត្រា១ នៃព្រះរាជក្រមលេខ៩១០ន.ស ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ ក៏ដូចជាអនុក្រឹត្យលេខ៤២ អនក្រ.បក ស្តីពីការបង្កើតមន្ទីរសារការីអង្គរ រួមជាមួយបញ្ញត្តិនានា ដែលទាក់ទងទៅនឹងសារការី យើងអាចកំណត់ បានថាសារការីជាអ្នកជំនាញផ្នែកច្បាប់។ សារការីទទួលបានការតែងតាំងមុខងារជាសារការីដោយរាជរដ្ឋាភិបាល ដែលមានសិទ្ធិក្នុងការ ប្រឹក្សាយោបល់ផ្នែកច្បាប់កិច្ចការពាណិជ្ជកម្ម វិនិយោគ កិច្ចការគ្រួសារ និងការគ្រប់គ្រងចាត់ចែងទ្រព្យសម្បត្តិ រួមជាមួយវិស័យផ្សេងៗ ទៅតាមចំណេះដឹងរបស់ខ្លួនជូនដល់អតិថិជន តាមការស្នើសុំ[១៨]។ សារការីត្រូវធ្វើការពន្យល់ដល់អតិថិជនក្នុងផ្នែកនីមួយៗឲ្យបានច្បាស់លាស់ និងលំអិតទាក់ទង នឹងជុំវិញបញ្ហាផ្នែកច្បាប់ ដោយធ្វើការពន្យល់ទាំងផលវិជ្ជមាន ផលអវិជ្ជមានដែលអាចកើតមានក្នុងពេលបច្ចុប្បន្ន និងនាពេលអនាគតទៅលើកម្មវត្ថុ ឬគោលបំណងដែលអតិថិជនចង់បាន។

### ២.១.២. ការតាក់តែង និងផ្តល់យថាភូតរាល់លិខិតគតិយុត្ត ឬកិច្ចសន្យានានា

យើងបានបង្ហាញរួចមកហើយក្នុងជំពូកទី១ អំពីវត្តមានដែលក្រមរដ្ឋប្បវេណីចាស់បានចរឹតពាក់ព័ន្ធទៅនឹងលិខិតយថាភូតរបស់សារការី ដែលមានចាប់តាំងពីឆ្នាំ១៩២០មកម្ល៉េះ។ ប៉ុន្តែក្រមខាងលើពុំបានបញ្ញត្តិអំពីខ្លឹមសារ និងនិយមន័យឲ្យបានច្បាស់លាស់នៃលិខិតយថាភូតនោះឡើយ។ ដោយសម័យកាលនោះ ជាគោលការណ៍ លិខិតយថាភូតដែលប្រជាពលរដ្ឋស្គាល់ គឺសំដៅលើលិខិតដែលធ្វើឡើងដោយសារការី ឬក្រឡាបញ្ជី,ចៅហ្វាយស្រុក,មេឃុំ និងមេភូមិ។

រហូតដល់មកដល់ឆ្នាំ២០០៧ ក្រមរដ្ឋប្បវេណីថ្មីនៃព្រះរាជណាចក្រកម្ពុជាបានចូលជាធរមាន ក៏មិនបានឲ្យនិយម័យនៃលិខិតយថាភូតដែរ ប៉ុន្តែក្រមរដ្ឋប្បវេណីថ្មីនេះបានឲ្យនិយម័យសារការីដូចដែលបាននិយាយរួចមកហើយក្នុងជំពូកទី១ សារការី ជាមន្ត្រីសាធារណៈ ដែលមានមុខងារធ្វើលិខិតយថាភូតបញ្ជាក់អំពីលក្ខណៈពិតប្រាកដត្រឹមត្រូវ ធានារ៉ាប់រងអំពីកាលបរិច្ឆេទតម្កល់ រក្សាទុក និងចេញសេចក្តីចម្លងយថាភូតនៃលិខិតទាំងឡាយដែលត្រូវតែឲ្យមានការបញ្ជាក់។ យើងអាចទាញបានអំពីអត្ថន័យនៃលិខិតយថាភូតដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី២០០៧ សំដៅទៅលើលិខិតយថាភូតដែលកំណត់នៅក្នុងមាត្រា៣៣៦ (ស្តីពីការបង្កើតកិច្ចសន្យាដោយសំណើរ និងស្វីការ) មាត្រា៥១៦

[១៨] មាត្រា១ កថាខណ្ឌទី១ ព្រះរាជក្រមលេខ៩១០ ន.ស, មាត្រា៤ ចំណុច ២ អនុក្រឹតលេខ៤២ អនក្រ.បក ស្តីពីការបង្កើតមន្ទីសារការីអង្គរ

(ស្តីពីការបង្កើតកិច្ចសន្យាលក់ទិញ) និងមាត្រា៨៦២ (អានុភាពនៃការចាត់ចែងហ៊ីប៉ូតែក) នៃក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតដែលត្រូវធ្វើឡើងដោយសារការី ឬលិខិតឯកជនដែលសារការីចុះនិទ្ទេសថាលិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់ និងចុះកាលបរិច្ឆេទ និងហត្ថលេខាក្រោយពេលខ្លួនបញ្ជាក់ថាលិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់[១៩]។ មិនតែប៉ុណ្ណោះមាត្រាខាងលើបានចែងបន្ថែមថា ចំពោះលិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើង ដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជីក៏ជាលិខិតយថាភូតដែរ[២០]។ យោងតាមការឲ្យនិយមន័យ និងមាត្រាខាងលើយើងកំណត់បានថា សារការីមានសិទ្ធិការតាក់តែងរាល់លិខិតស្នាមទាំងឡាយ ដែលរូបវន្តបុគ្គល ឬនីតិបុគ្គលបានស្នើសុំ និងកើតឡើងតាមការព្រមព្រៀង នឹងឆន្ទៈពិតប្រាកដនៃគូភាគី។ ក្រោយពីការតាក់តែងលិខិតត្រូវបានចប់រួចរាល់នោះ ដើម្បីឲ្យលិខិតទាំងនោះក្លាយជាលិខិតយថាភូតដោយត្រឹមត្រូវស្របតាមច្បាប់ និងមានសុពលភាព សារការីត្រូវធ្វើការចុះហត្ថលេខា និងប្រថាប់ត្រាលើលិខិតទាំងអស់នោះ។ ម៉្យាងទៀតលិខិតគតិយុត្ត ឬកិច្ចសន្យាទាំងឡាយដែលធ្វើឡើងដោយសារការីនេះ មាននៅក្នុងជីវៈភាពរស់នៅជាក់ស្តែងរបស់មនុស្សស្ទើគ្រប់វិស័យនៅក្នុងសង្គមបច្ចុប្បន្ន។

**២.១.២.១. វិស័យអចលនទ្រព្យ ឬអចលនវត្ថុ**

បើយើងសង្កេតមើលទៅលើស្ថានភាពបច្ចុប្បន្ន ការទិញលក់ ផ្ទេរកម្មសិទ្ធិ ការជួលផ្សេងៗមិនត្រឹមតែវិស័យចលនវត្ថុនោះទេ ក្នុងវិស័យអចលនទ្រព្យ សារការីបានដើរតួយ៉ាងសំខាន់ផងដែរ ក្នុងការតាក់តែងលិខិត កិច្ចសន្យាផ្សេងៗ ដូចជាការទិញលក់ ការជួល ប្រាតិភោគ អំណោយលើអចលនវត្ថុជាដើម។ ប៉ុន្តែមុននឹងយើងឈានចូលក្នុងវិស័យអចលនទ្រព្យ ឬអចលនវត្ថុ យើងគប្បីយល់ពីអត្ថន័យនៃពាក្យនេះជាមុនសិន។ តាមការឲ្យនិយមន័យរបស់ក្រមរដ្ឋប្បវេណី នៃពាក្យអចលនទ្រព្យ ឬអចលនវត្ថុមានន័យថា ៖

- ដីធ្លី និងវត្ថុជាប់នៅនឹងដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបានដូចជា អាគារ សំណង់ ដំណាំរុក្ខជាតិ។ល។
- សិទ្ធិប្រត្យក្ស ឬសិទ្ធិភណ្ឌិកលើអចលនវត្ថុ និងចលនវត្ថុទាំងឡាយដែលច្បាប់កំណត់ថាជាអចលនវត្ថុ។

បើយើងនិយាយដល់អចលនទ្រព្យ សព្វថ្ងៃយើងសង្កេតឃើញអចលនទ្រព្យកំពុងមានការរីកចម្រើនយ៉ាងខ្លាំង ក្នុងនោះរួមមានការលក់ទិញផងដែរ ដែលកើតមានជារៀងរាល់ថ្ងៃ ។ ការលក់ទិញទាំងនោះដើម្បីឲ្យមានលក្ខណៈត្រឹមត្រូវស្របតាមផ្លូវច្បាប់ ការលក់ទិញនោះត្រូវតែធ្វើឡើងជាលាយលក្ខណ៍

[១៩] មាត្រា៩ ចំណុច ក ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ២០០៧

[២០] មាត្រា៩ ចំណុច ខ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ២០០៧

អក្សរ និងជាលិខិតយថាភូត ហើយមុននឹងឈានចូលដល់កិច្ចសន្យាលក់ទិញយើងគប្បីយល់ពីនិយមន័យនៃការលក់ទិញជាមុនសិន។

និយមន័យនៃការលក់ទិញ សំដៅលើកិច្ចសន្យាមួយដែលភាគីម្ខាងហៅថា អ្នកលក់មានករណីយកិច្ចត្រូវផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិ ឲ្យទៅភាគីម្ខាងទៀតហៅថាអ្នកទិញ ហើយអ្នកទិញមានករណីយកិច្ចត្រូវចេញថ្លៃជាប្រាក់ឲ្យអ្នកលក់[២១]។ យោងតាមមាត្រា ៥១៦ កិច្ចសន្យាលក់ទិញអាចត្រូវបានបង្កើតឡើង ដោយមានការព្រមព្រៀងគ្នារវាងភាគីទាំងសងខាងតែប៉ុណ្ណោះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់។ ប៉ុន្តែភាគីអាចកំណត់ការធ្វើលិខិតយថាភូត ឬលិខិតឯកជនជាលក្ខខ័ណ្ឌសម្រាប់ការបង្កើតកិច្ចសន្យាបាន[២២]។ ចំពោះការបង្កើតកិច្ចសន្យាលក់ទិញជាគោលការណ៍ គឺអាចបង្កើតឡើងឲ្យតែមានការព្រមព្រៀង រវាងភាគី ដោយមិនចាំបាច់មានទម្រង់ដូចជាការប្រគល់វត្ថុទេ (គោលការណ៍នៃការបង្កើតដោយការព្រមព្រៀង)។ ក្នុងករណីដែលចាំបាច់មានទម្រង់ ដូចជាលិខិតកិច្ចសន្យាលក់ទិញជាលាយល័ក្ខអក្សរ សេចក្តីបញ្ជាក់ការចុះបញ្ជីជាដើម ក្នុងការបង្កើតកិច្ចសន្យាលក់ទិញ ឬដើម្បីបញ្ជាក់កិច្ចសន្យាលក់ទិញ ច្បាប់ ឬបទដ្ឋានគតិយុត្តផ្សេងទៀត នឹងកំណត់អំពីទម្រង់នេះ។ ដោយឡែកសម្រាប់កិច្ចសន្យាជួល ប្រាតិភោគ អំណោយ ឬកិច្ចសន្យាមួយចំនួនទៀត ក៏មិនខុសគ្នាពីកិច្ចសន្យាលក់ទិញប៉ុន្មានដែរ សារការីមានសិទ្ធិនៅក្នុងការតាក់តែងដូចគ្នាគ្រាន់តែការតាក់តែងមានការប្រែប្រួលទៅតាមកម្មវត្ថុ និងលក្ខខណ្ឌនៃកិច្ចសន្យាទាំងនោះតែប៉ុណ្ណោះ សារការីធ្វើរតាក់តែងទៅតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ទោះបីជាគ្មានបញ្ញាត្តិនៅក្នុងច្បាប់ ឬបទដ្ឋានគតិយុត្តផ្សេងទៀងក៏ដោយ ក៏ភាគីមានសេរីភាពក្នុងការយកទម្រង់ណាមួយ មកធ្វើជាលក្ខខណ្ឌដើម្បីបង្កើតកិច្ចសន្យាបានដែរ សារការីមានសិទ្ធិបញ្ជាក់ទៅលើកិច្ចសន្យា និងការកំណត់ការធ្វើលិខិតយថាភូត។

**២.១.២.២. វិស័យនីតិគ្រួសារ**

នៅក្នុងវិស័យគ្រួសារ ជាវិស័យមួយដែលនិយាយរៀបរាប់អំពីជីវិតគ្រួសារ អាពាហ៍ពិពាហ៍ ក៏ដូចជាការគ្រប់គ្រង ចាត់ចែងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ មរតកសាសន៍ ដែលរាល់ការបែងចែកការគ្រប់គ្រង និងការបែងចែកទ្រព្យទាំងនោះទាមទារជាចាំបាច់នៅលិខិតយថាភូតពីស្ថាប័នមានសមត្ថកិច្ច ដើម្បីឲ្យការគ្រប់គ្រង ឬការបែងចែកនោះអាចមានសុពលភាព និងត្រឹមត្រូវស្របតាមបញ្ញត្តិច្បាប់ ជាក់ស្តែងសារការីជាស្ថាប័នដែលមានជំនាញផ្នែកច្បាប់មួយដែលមានសមត្ថកិច្ចក្នុងការតាក់តែង និងផ្តល់យថាភាពលើលិខិតគតិយុត្តដែលស្របតាមច្បាប់ដូចបានរៀបរាប់នៅចំណុចខាងរួចមកហើយ។

---

[២១] មាត្រា៥១៥ ក្រមរដ្ឋប្បវេណី ២០០៧

[២២] មាត្រា៥១៦ ក្រមរដ្ឋប្បវេណី ២០០៧

## ក.ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា

បើយើងមើលលើប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ យើងនឹងឃើញការបែងចែកប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិជាពីរគឺ ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា និងប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់[២៣] នៅក្នុងនេះដែរយើងលើកយកប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា ដែលពាក់ព័ន្ធនឹងសិទ្ធិរបស់សារការីមកនិយាយ។ មានបញ្ញត្តិជាច្រើនបាននិយាយពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដែលប្តីប្រពន្ធអាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិ នៅមុនឬក្រោយអាពាហ៍ ពិពាហ៍បាន។ ប៉ុន្តែកិច្ចសន្យានេះមិនអាចធ្វើផ្ទុយនឹងបញ្ញត្តិស្តីពីសិទ្ធិទាមទារអាហារកិច្ច និងភាគបម្រុងបានឡើង[២៤]។ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ។

ក្នុងករណីដែលប្តីប្រពន្ធបានធ្វើកិច្ចសន្យា ផ្សេងពីប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ បើមិនបានចុះបញ្ជីទេមិនអាចយកកិច្ចសន្យានោះមកតតាំងជាមួយនឹងតតិយជនបានឡើយ[២៥]។ នាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌មានសមត្ថកិច្ចលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ[២៦]។ បើយោងតាមព្រះរាជាក្រមលេខ៩១០ន.ស ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ និងអនុក្រឹត្យស្តីពីការផ្តល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវី និងការបង្កើតមន្ទីរសារការីផ្សេងៗនៃព្រះរាជាណាចក្រកម្ពុជា បានចែងសិទ្ធិរបស់សារការីក្នុងការធ្វើរាល់លិខិតគតិយុត្តតាមការស្នើសុំពីរូបវន្តបុគ្គល ឬនីតិបុគ្គល និងធ្វើសំណើចុះបញ្ជី ឬចុះលេខាចារឹកផ្សេងៗ ទៅស្ថាប័នមានសមត្ថកិច្ចនានា[២៧]។ ទោះបីជាមិនមានបញ្ញត្តិណាមួយចែងឲ្យច្បាស់ពីសិទ្ធិរបស់សារការី លើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ក៏ដោយប៉ុន្តែសារការីនៅតែអាចធ្វើទៅបាននៃកិច្ចសន្យានោះរួមទាំងអាចធ្វើសំណើចុះបញ្ជីទៅក្រសួងយុត្តិធម៌ផងដែរ។

## ខ.មរតកសាសន៍

បើយើងក្រឡេកទៅមើលបញ្ញត្តិស្តីពីមរតកសាសន៍ មានបញ្ញត្តិជាច្រើនបាននិយាយពីទម្រង់នៃលិខិតមរតកសាសន៍នេះ ប៉ុន្តែយើងសូមលើកឡើងនៅបញ្ញត្តិមួយចំនួនដែលពាក់ព័ន្ធសារការីមកនិយាយ។ មរតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើងដោយម្ចាស់បណ្តាំ នៅចំពោះមុខសារការី ដោយម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់នូវខ្លឹមសារនៃមរតកសាសន៍ចំពោះសារការី ហើយសារការីត្រូវសរសេរនូវអត្ថន័យនៃមរតកសាសន៍របស់ម្ចាស់បណ្តាំ នោះជាលាយល័ក្ខណ៍អក្សរហើយត្រូវសូត្រ

[២៣] មាត្រា៩៦៩ ក្រមរដ្ឋប្បវេណី ២០០៧

[២៤] មាត្រា៩៦៩ ចំណុច ១ ក្រមរដ្ឋប្បវេណី ២០០៧

[២៥] មាត្រា៩៧០ ចំណុច ២ ក្រមរដ្ឋប្បវេណី ២០០៧

[២៦] ប្រការ៤ ប្រកាសលេខ ៨១ កយ.ស្រក/១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

[២៧] មាត្រា៤ ចំណុច៨ អនុក្រឹត្យលេខ ៨២ អនក្រ.បក ស្តីពីការបង្កើតមន្ទីរសារការីអង្គរ

ឲ្យម្ចាស់បណ្តាំ និងសាក្សីពីរនាក់ស្តាប់ បន្ទាប់ពីម្ចាស់បណ្តាំ និងសាក្សីបានទទួលស្គាល់ថាកំណត់ជាលាយល័ក្ខអក្សរនោះត្រឹមត្រូវហើយ ជននីមួយៗនោះត្រូវធ្វើអោយមានភាពច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ លំនៅឋាន ហើយត្រូវចុះហត្ថលេខារៀងៗខ្លួន ប៉ុន្តែបើម្ចាស់បណ្តាំមិនអាចសរសេរអក្សរ ឬមិនអាចចុះហត្ថលេខាបានទេ សារការីអាចជំនួសការសរសេរ និងហត្ថលេខាដូចកំណត់ចែងលើនេះ ដោយសរសេរឈ្មោះ អាយុ និងលំនៅឋានរបស់ជននោះ ហើយត្រូវសរសេរបន្ថែមនូវហេតុនោះផងដែរ ក្រោយពីម្ចាស់បណ្តាំទទួលស្គាល់ថាកំណត់ជាលាយល័ក្ខណ៍អក្សរនោះត្រឹមត្រូវ និងចុះហត្ថលេខារួចរាល់ហើយ សារការីត្រូវសរសេរថ្ងៃខែឆ្នាំ ហើយត្រូវចុះហត្ថលេខាលើមតកសាសន៍នោះ[២៨]។ ក្នុងករណីដែលបុគ្គលដែលមិនអាចនិយាយបាន ធ្វើមតកសាសន៍តាមទម្រង់មតកសាសន៍ដោយលិខិតយថាភូត ឬមតកសាសន៍តាមទម្រង់មួយចំនួនទៀតដូចជាមាត្រា ១១៧៥,១១៧៧ នៃក្រមរដ្ឋប្បវេណី ម្ចាស់បណ្តាំនោះអាចជំនួសការប្រាប់បាន ដោយធ្វើសេចក្តីថ្លែងការណ៍អំពីខ្លឹមសារនៃមតកសាសន៍ ឬសេចក្តីថ្លែងការថាលិខិតនោះជាលិខិតមរតកសាសន៍ តាមការបកប្រែរបស់អ្នកបកប្រែ ឬសរសេរដោយដៃផ្ទាល់នៅចំពោះមុខសារការី ឬសាក្សីក្នុងករណីដែលសារការី ឬបុគ្គលផ្សេងទៀតក្នុងក្រមនេះត្រូវអានឲ្យម្ចាស់បណ្តាំស្តាប់ ឬសាក្សីស្តាប់នូវអត្ថន័យនៃមតកសាសន៍នោះ បើម្ចាស់បណ្តាំ និងសាក្សីនោះ បែរជមនុស្សថ្លង់មិនអាចស្តាប់បានទេ សារការី ឬបុគ្គលផ្សេងទៀតដែលត្រូវបានកំណត់នៅក្នុងក្រមនេះ អាចជំនួសការអានឲ្យស្តាប់បាន ដោយប្រាប់អំពីអត្ថន័យដែលខ្លួនបានសរសេរនោះ តាមការបកប្រែរបស់អ្នកបកប្រែ ទៅម្ចាស់បណ្តាំ ឬ សាក្សីនោះ[២៩]។ ក្នុងន័យនេះចង់និយាយអំពីការធ្វើមតកសាសន៍ដោយលិខិតយថាភូត ជាអាទិ៍ដោយបុគ្គលដែលមិនអាចនិយាយបាន ហើយការប្រាប់នូវឆន្ទៈរបស់សាមីខ្លួនដល់សារការី អាចធ្វើឡើងដោយមានអ្នកបកប្រែភាសាសញ្ញា ឬសារសេរដោយដៃខ្លួនឯងផ្ទាល់ ដើម្បីជំនួសនូវសេចក្តីថ្លែងការណ៍ ហើយសារការី ឬជនផ្សេងទៀតដែលក្រមបានកំណត់ ក្រោយពីបានសរសេរជាលាយល័ក្ខណ៍អក្សរនូវខ្លឹមសារ នៃមតកសាសន៍រួចរាល់អាចប្រាប់នូវខ្លឹមសារ ដែលបានសរសេរនោះតាមរយៈការបកប្រែទៅម្ចាស់បណ្តាំ ឬសាក្សី ដើម្បីជំនួសការស្តាប់បាន។ ករណីដែលលិខិតមតកសាសន៍នោះត្រូវបានតម្កល់ទុកនៅមន្ទីរសារការី សារការីជាអ្នកទទួលបានសិទ្ធិក្នុងអនុវត្ត និងប្រកាសនូវមតក-សាសន៍ ទៅដល់សន្តតិជនដែលទទួលបានចំណែកមតកសាសន៍ នៅពេលដែលលក្ខខណ្ឌក្នុងការអនុវត្តមតកសាសន៍នោះបានបំពេញគ្រប់គ្រាន់អស់ដូចជា ម្ចាស់បណ្តាំនៃមរកសាសន៍បានទទួលមរណភាពជាដើម។

[២៨] មាត្រា១១៧៣ ក្រមរដ្ឋប្បវេណី ២០០៧

[២៩] មាត្រា១១៧៩ ក្រមរដ្ឋប្បវេណី ២០០៧

### ២.១.៣. ផ្តល់យថាភូតរាល់លិខិតគតិយុត្ត ឬកិច្ចសន្យានានា

យើងបានដឹងថាសារការី ជាអ្នកតាក់តែងរាល់លិខិតគតិយុត្ត ឬលិខិតយថាភូតផ្សេងៗ ដូចដែលបានរៀបរាប់ នៅចំនុចខាងលើរួចមកហើយ ប៉ុន្តែយើងមិនបានដឹងថាលិខិតដែលមិនបានតាក់តែងដោយសារការី តើអាចក្លាយជា លិខិតយថាភូតបានដែរឬទេ? ទោះបីជាលិខិតគតិយុត្តទាំងអស់នោះ មិនបានតាក់តែងឡើងដោយសារការីក៏ដោយ សារការីនៅតែមានសិទ្ធិក្នុងការផ្តល់យថាភូតនូវរាល់លិខិតទាំងឡាយដែលច្បាប់បានផ្តល់ឲ្យ។ លិខិតយថាភូតដែលកំណត់ក្នុងមាត្រា ៣៣៦ (ការបង្កើតកិច្ចសន្យាដោយសំណើ និងស្ទីការ) មាត្រា៥១៦ (ការបង្កើតកិច្ចសន្យាលក់ទិញ) និងមាត្រា៨៦២ (អានុភាពនៃការចាត់ចែងហ៊ីប៉ូតែក) នៃក្រមរដ្ឋប្បវេណី សំដៅលើលិខិតដែលត្រូវធ្វើឡើងដោយសារ-ការី ឬលិខិតឯកជនដែលសារការីចុះនិទ្ទេសថា លិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់[៣០]។ មិនតែប៉ុណ្ណោះបើយើងមើលលើការអនុវត្តជាក់ស្តែង សារការីអាចផ្តល់យថាភូតនូវរាល់លិខិតគតិតយុត្តិដែលខ្លួនគិតថាត្រឹមត្រូវស្របទៅតាមបញ្ញត្តិនៃច្បាប់។ ឧទាហរណ៍ ៖ នីតិបុគ្គលឯកជន (ធនាគារ ក) បានព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាហ៊ីប៉ូតែក ជាមួយបុគ្គលឯកជន(លោក ខ) ហើយលោក (ខ) បានយល់ស្របនូវអត្ថន័យនៃកិច្ចសន្យាដែលភាគីខាងធនាគារ (ក) បានតាក់តែង ប៉ុន្តែកិច្ចសន្យាហ៊ី-ប៉ូតែកនេះមិនទាន់មានអានុភាពឡើយ បើមិនមានការផ្តល់យថាភូតពីស្ថាប័នមានសមត្ថកិច្ច សារ-ការីជាស្ថាប័នមួយដែលមានសមត្ថកិច្ចផ្តល់យថាភូតលើកិច្ចសន្យានេះ។ យោងតាមមាត្រាខាងលើសបញ្ជាក់ឲ្យឃើញថា កិច្ចសន្យាហ៊ីប៉ូតែក ក៏ដូចជាកិច្ចសន្យាផ្សេងៗទៀត ទោះបីជាមិនបានតាក់តែងឡើងដោយសារការីក៏ដោយ ក៏សារការីមានសិទ្ធិក្នុងការផ្តល់យថាភូតលើកច្ចសន្យាទាំងអស់នោះដែរ ឲ្យតែកិច្ចសន្យា ឬលិខិតទាំងនោះស្របទៅតាមបញ្ញត្តិច្បាប់។

### ២.១.៤. ចេញច្បាប់ចម្លងនៃលិខិតយថាភូត

កន្លងមកយើងបានសង្កេតឃើញថារដ្ឋបាលស្រុក ខណ្ឌ ខេត្ត ក្រុង មានសមត្ថកិច្ចក្នុងការបញ្ជាក់លើច្បាប់ចម្លងនៃលិខិតយថាភូតផ្សេងៗ ដែលប្រជាពលរដ្ឋគ្រប់រូបបានដឹងថា ច្បាប់ចម្លងដែលបានបញ្ជាក់នោះមានសុពលភាព និងអាចប្រើប្រាស់បានតាមការកំណត់នៃច្បាប់។ ម្យ៉ាងទៀត បើយោងតាមមាត្រា៣ ចំណុចខ នៃអនុក្រឹត្យលេខ ៥០៥ អនក្រ.តត. ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០១ ស្តីពីការផ្តល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងយោងតាមមាត្រា៤ នៃអនុក្រឹត្យស្តីពីការបង្កើតមន្ទីរសារការីអង្គរ ក៏ដូចជាអនុក្រឹត្យស្តីពីការបង្កើតមន្ទីរសារការីផ្សេងៗទៀត បានចែងអំពីសមត្ថកិច្ចរបស់សារការី ក្នុងការចេញច្បាប់ចម្លងនៃលិខិត

[៣០] មាត្រា៩ ចំណុច ក ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី

យថាភូតផ្សេងៗផងដែរ[៣១]។ បើយោងតាមការចុះកម្មសិក្សាផ្ទាល់ បានសង្កេតឃើញពីការចេញច្បាប់ចម្លងនៃលិខិតយថាភូតនេះមានដូចជា អត្តសញ្ញាណប័ណ្ណ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ សាលក្រម សញ្ញាបត្រ នឹងលិខិតគតិយុត្តផ្សេងៗទៀត ដែលមានច្បាប់ដើម។ ជាក់ស្តែងមិនទាន់មានបញ្ញត្តិណាមួយដែលចែងឲ្យបានច្បាស់លាស់ ទៅលើសមត្ថកិច្ចផ្តាច់មុខក្នុងការចេញច្បាប់ចម្លងនៃលិខិតយថាភូត ដូចនេះហើយច្បាប់ចម្លងដែលបានចេញដោយសារការី និងមានសុពលភាពដូចគ្នាទៅនឹងច្បាប់ចម្លង ដែលបានបញ្ជាក់ដោយរដ្ឋបាលស្រុក ខណ្ឌ ខេត្ត ក្រុង ដែរ។

### ២.១.៥. ផ្តល់ការបញ្ជាក់សុពលភាពចំពោះការបង្កើត ឬកែប្រែលក្ខន្តិកៈក្រុមហ៊ុន

នៅក្នុងការបង្កើតក្រុមហ៊ុនមួយ លក្ខន្តិកៈរបស់ក្រុមហ៊ុនជារឿងដែលសំខាន់មួយដែលមិនអាចខ្វះបាន ដែលក្នុងលក្ខន្តិកៈបាននិយាយរៀបរាប់អំពីព័ត៌មានរបស់ក្រុមហ៊ុនទាំងអស់ ជាពិសេសនោះគឺគោលបំណង នាមករណ៍ ទីតាំងនៃទីស្នាក់ការកណ្តាល រួមទាំងចំណុចផ្សេងៗចាំបាច់ជាច្រើនទៀត។ ទោះបីជាលក្ខន្តិកៈក្រុមហ៊ុនបានបង្កើតរួចរាល់ជាស្ថាពរហើយក៏ដោយ ក៏លក្ខន្តិកៈនោះពុំទាន់មានអានុភាពស្របច្បាប់ ដើម្បីអនុវត្តបាននៅឡើយដែរ លុះត្រាតែទទួលបានការបញ្ជាក់ពីសារការី ទើបលក្ខន្តិកៈក្រុមហ៊ុននោះមានសុពលភាពស្របច្បាប់ក្នុងការអនុវត្តបាន។ យោងតាមបញ្ញត្តិនៃក្រម រដ្ឋប្បវេណី (ស្តីពីនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិតមាត្រា៨២ ការបង្កើត និងលក្ខន្តិកៈ ចំណុច៣), យោងតាមបញ្ញត្តិស្តីពី (នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត មាត្រា១០១ ការបង្កើត និងលក្ខន្តិកៈ ចំណុច៣), យោងតាមបញ្ញត្តិស្តីពី (នីតិបុគ្គលមូលនិធិមាត្រា១១០ ការបង្កើត និងលក្ខន្តិកៈ ចំណុច៣) បានចែងពីថា លក្ខន្តិកៈពុំមានអានុភាពឡើយ បើពុំបានទទួលសេចក្តីបញ្ជាក់ពីសារការី[៣២]។ យោងតាមមាត្រា៩៧ ចំណុច២,មាត្រា១០៩ ចំណុច៣ នៃក្រមរដ្ឋប្បវេណីបានចែងថា ការកែប្រែលក្ខន្តិកៈពុំមានអានុភាពឡើយ បើពុំទទួលបានសេចក្តីបញ្ជាក់ពីសារការី[៣៣]។ ក្នុងន័យដែលបានរៀបរាប់ខាងលើ មានគោលបំណងបញ្ជាក់ថា ដើម្បីធ្វើការកែប្រែលក្ខន្តិកៈដែលកំណត់អំពីបទដ្ឋាននៃកិច្ចការរបស់នីតិបុគ្គលសាជីវកម្ម ចាំបាច់ត្រូវមានការសម្រេចពិសេសលើកលែងតែមានចែងពិសេសក្នុងលក្ខន្តិកៈ។ ប្រសិនបើនីតិបុគ្គលនោះបានធ្វើសេចក្តីសម្រេចពិសេស ដើម្បីកំណត់នូវលក្ខន្តិកៈដែលជាបទដ្ឋានមូលដ្ឋានរបស់ខ្លួន ការគោរពលក្ខន្តិកៈគឺជាការសមស្របនឹងស្វ័យភាពឯកជន ឬស្វ័យភាពរបស់ក្រមនោះហើយ។ លក្ខខណ្ឌអានុភាពនៃការកែប្រែលក្ខន្តិកៈ គឺជាសេចក្តីបញ្ជាក់ពីសារការី ។ តួយ៉ាងដើម្បីកែប្រែលក្ខន្តិកៈដែលជាបទដ្ឋាន

---

[៣១] មាត្រា៣ ចំណុច២ អនុក្រឹត្យលេខ ៥០៥ អនក្រ.តត.ស្តីពីការផ្តល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៤ ចំណុច១០ អនុក្រឹត្យលេខ៨៤២ អនក្រ.បក ស្តីពីការបង្កើតមន្ទីរសារការីអង្គរ

[៣២] មាត្រា៨២, ១០១, ១១០ ក្រមរដ្ឋប្បវេណី២០០៧

[៣៣] មាត្រា៩៧, ១០៩ ក្រមរដ្ឋប្បវេណី២០០៧

នៃកិច្ចការរបស់នីតិបុគ្គល ចំពោះនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ចាំបាច់ត្រូវមានការសម្រេចពិសេសនៃមហាសន្និបាតសមាជិក ក៏ប៉ុន្តែចំពោះនីតិបុគ្គលទទួលខុសត្រូវគ្មានកម្រិតវិញ មិនមានមហាសន្និបាតសមាជិកទេ ហេតុនេះហើយចាំបាច់ត្រូវមានការយល់ព្រមពីសមាជិកទាំង-អស់។ ក៏ប៉ុន្តែក្នុងករណីដែលមានចែងពិសេសក្នុងលក្ខន្តិកៈ ត្រូវគោរពតាមលក្ខន្តិកៈនោះ។ ម៉្យាងទៀត ការចែងពិសេសក្នុងលក្ខន្តិកៈនោះ ខុសគ្នានឹងករណីនៃនីតិបុគ្គលសាជិវកម្មទទួលខុសត្រូវមានកម្រិត គឺមិនយកអត្រានៃសិទ្ធិសម្រេចមកធ្វើជាមូលដ្ឋាននៃការសម្រេចទេ គឺយកចំនួនសមាជិកមកធ្វើជាបទដ្ឋាននៃការសម្រេចទៅវិញ ។ ម្យ៉ាងទៀត លក្ខន្តិកៈដែលបានកែប្រែចាំបាច់ត្រូវមានការទទួលស្គាល់ដោយសារការី ប្រសិនបើមិនមានការទទួលស្គាល់ពីសារការីទេ មិនមានអានុភាពឡើយ។

### ២.១.៦. បញ្ជាក់ហត្ថលេខា និងកាលបរិច្ឆេទនៃលិខិតគតិយុត្តិ ឬកិច្ចសន្យានានា

ការបញ្ជាក់ហត្ថលេខា និងកាលបរិច្ឆេទ ទៅលើឯកសារមួយចំនួនដែលជាលិខិតគតិយុត្តិ ឬក៏កិច្ចសន្យានោះ នាពេលបច្ចុប្បន្នមិនទាន់មានវិសាលភាពទូលំទូលាយនៅឡើយទេ។ ជាការពិតការបញ្ជក់ហត្ថលេខាពិតជាមានសារសំខាន់ដែលជាពិសេសគឺត្រូវធ្វើនៅចំពោះមុខសារការី ដើម្បីឲ្យសារការីបញ្ជក់ថាពិតជាត្រឹមត្រូវពិតប្រាដកមែន ដូចជាកិច្ចសន្យាមួយចំនួនដែលភាគីទាំងសងខាងបានព្រមព្រៀងគ្នា និងធ្វើនៅចំពោះមុខសារការីហើយសារការីជាសាក្សីនិងបញ្ជាក់ទៅលើកិច្ចសន្យានោះ ដើម្បីឲកិច្ចសន្យាមានសុពលភាពក្នុងការអនុវត្ត។ ម្យ៉ាងទៀតចំពោះការបរិច្ឆេទ លិខិតឯកជនដែលសារការី ឬក្រឡាបញ្ជីតុលាការចុះនិទ្ទេសអំពីកាលបរិច្ឆេទដែលខ្លួនត្រូវបានបង្ហាញលិខិតឯកជននេះ និងចុះហត្ថលេខាក្នុងករណីនេះ កាលបរិច្ឆេទស្ថាពរ[៣៤]។

### ២.១.៧. តម្កល់ និងរក្សាទុកច្បាប់ដើមនៃលិខិតស្នាមគ្រប់ប្រភេទ

យោងតាមតាត្រា៣ ចំណុច ខ នៃអនុក្រឹត្យលេខ ៥០៥ អនក្រ.តត. ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០១ ស្តីពីការផ្តល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវីនៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា គឺធ្វើការបញ្ជាក់លើការិយបរិច្ឆេទ ទទួលតម្កលទុកឯកសារ និងចេញឲ្យនូវសេចក្តីដើម ឬសេចក្តីចម្លងនៃលិខិត ឬកិច្ចសន្យាទាំងឡាយនោះតាមមុខការ និងយោងតាមមាត្រា៤ នៃអនុក្រឹត្យស្តីពីការបង្កើតមន្ទីរសារការីអង្គរ ក៏ដូចជាអនុក្រឹត្យស្តីពីការបង្កើតមន្ទីរសារការីផ្សេងៗទៀត បានចែងអំពីខមត្ថកិច្ចរបស់សារការីការតម្កល់ទុក និងរក្សាទុកឯកសារច្បាប់ដើមនៃលិខិតគតិយុត្ត និងកិច្ចសន្យាផ្សេងៗ[៣៥]។

---

[៣៤] មាត្រា៨ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី

[៣៥] មាត្រា៣ ចំណុចខ អនុក្រឹត្យលេខ ៥០៥ អនក្រ.តត.ស្តីពីការផ្តល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និង មាត្រា៤ ចំណុច៩ អនុក្រឹត្យលេខ៩៤២ អនក្រ.បក ស្តីពីការបង្កើតមន្ទីរសារការីអង្គរ

## ២.១.៨. ការចេញនូវរូបមន្តអនុវត្ត និងការអនុវត្តដោយបង្ខំ

ការអនុវត្តដោយបង្ខំ ជាទូទៅត្រូវបានធ្វើឡើងដោយស្ថាប័នអនុវត្ត តាមការស្នើសុំរបស់ ភាគីកាលណាដែលដល់ពេលវេលាកំណត់ពិប្រាកដ ចេញសាលក្រម សាលដីការ ឬសេចក្តីសម្រេចជាស្ថាពរពីតុលាការ ប៉ុន្តែដោយឡែកការអនុវត្តដោយបង្ខំ ដែលលើកយកមកបង្ហាញក្នុងពេលនេះសំដៅទៅលើលិខិតយថាភូតរបស់សារការី ដែលគូភាគីបានព្រមព្រៀងគ្នា និងយល់ព្រមអនុវត្តដោយបង្ខំនៅក្នុង ខ ចែកនៃកិច្ចសន្យាដែលសារការីបានតាក់តែង។ លិខិតយថាភូតដែលធ្វើ ដោយសារការីចំពោះការទាមទារដែលមានគោលបំណងឲ្យសងជាប្រាក់មានកំណត់។ ប៉ុន្តែមានកម្រិតតែលិខិតដែលបញ្ជាក់សេចក្តីថ្លែងការណ៍ថា កូនបំណុល នឹងទទួលការអនុវត្តដោយបង្ខំភ្លាមៗ[៣៦]។ ក្នុងន័យនេះសំដៅថាម្ចាស់បំណុល និងកូនបំណុល ត្រូវតែបានព្រមព្រៀងគ្នាក្នុងការធ្វើលិខិត ឬកិច្ចសន្យាទាន់ តែមានការអនុវត្តដោយបង្ខំភ្លាមៗនូវពេលដល់ពេលកំណត់ណាមួយ ហើយខ្លួនមិនមានលទ្ធភាពក្នុងការសងបំណុលទៅម្ចាស់បំណុល។ លិខិតយថាភូតដែលធ្វើឡើងដោយសារការី សម្រេចតាម ការព្រមព្រៀងរបស់គូភាគីតាំងពីដំបូងមកនៅក្នុងចំណោមលិខិតដែលមានអានុភាពនេះគូភាគី សច្ចាប្រណិធានថានឹងអនុវត្តតាមខ្លឹមសារនៃការព្រមព្រៀងគ្នា។ សំខាន់ជាងនេះទៅទៀតលិខិតយថាភូតមានតម្លៃស្មើ និងសាលក្រមតុលាការហើយអាចអនុវត្តបាន។ គួរបញ្ជាក់ផងដែរថាលិខិតយថាភូតដែរបានតាក់តែងឡើងដោយសារការីទាំងអស់ មិនមែនសុទ្ធតែអាចអនុវត្តដោយបង្ខំបាននោះទេ។ លុះត្រាតែលិខិតយថាភូតដែលសារការីបានតាក់តែងនោះ បានបំពេញនូវលក្ខខណ្ឌដូចដែរបានចែងនៅចំណុច ច ក្នុងមាត្រា៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ទើបលិខិតយថាភូតរបស់សារការីមានអានុភាពក្នុងការអនុវត្តដោយបង្ខំបាន។ ជាគោលការណ៍ការអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូត នៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត ហើយរូបមន្តនេះត្រូវផ្តល់ដោយសារការីដែលរក្សាទុកនូវ ច្បាប់ដើមនោះក្នុងករណីលិខិត អនុវត្តបានកំណត់នៅក្នុងចំណុច ច កថាខណ្ឌទី២នៃមាត្រា ៣៥០[៣៧]។ មិនតែប៉ុណ្ណោះការផ្តល់រូបមន្តអនុវត្ត ត្រូវធ្វើឡើងតាមវិធីសរសេរភ្ជាប់បន្ថែម នៅផ្នែកក្រោមនៃឯកសារចម្លងយថាភូតនូវចំណុចមួយចំនួនដូចជាបុគ្គលដែលអាចទាមទារឲ្យធ្វើការអនុវត្តដោយបង្ខំបាន ដោយលិខិតអនុវត្តនោះ និងភាគីម្ខាងទៀតការពិនិត្យទៅលើទំហំដែលអាចអនុវត្តដោយបង្ខំបាន បើបានផ្តល់រូបមន្តអនុវត្តតែមួយផ្នែកនៃសិទ្ធិទាមទារ ដែលត្រូវបានកំណត់ក្នុងលិខិតអនុវត្តរួមជាហេតុការផ្សេងៗ នៃការចេញរូបមន្តអនុវត្តច្រើនច្បាប់ និងរូមន្តអនុវត្តពិសេស ហើយក្រឡាបញ្ជី ឬសារការីត្រូវចុះហត្ថលេខាលើរូបមន្តអនុវត្ត ដោយ

---

[៣៦] មាត្រា៣៥០ កថាខណ្ឌ២ ចំណុច ច ក្រមនីតិវិធីរដ្ឋប្បវេណី

[៣៧] មាត្រា៣៥៤ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី

សរសេរថ្ងៃ ខែ ឆ្នាំនៃការផ្ដល់ផងដែរ[៣៨]។ គួរបញ្ជាក់ផងដែរថាការអនុវត្តដោយបង្ខំ អាចចាប់ផ្ដើមធ្វើបាន តែក្នុងករណីដែលឯកសារចម្លងយថាភូត ឬឯកសារចម្លង ដែលមានសេចក្ដីបញ្ជាក់នៃលិខិតអនុវត្ត ឬសេចក្ដីសម្រេចដែលនឹងក្លាយជាលិខិតអនុវត្ត នៅពេល ចូលជាស្ថាពរត្រូវបញ្ជូនទៅកូនបំណុលនៃការអនុវត្តជាមុន[៣៩]។

## ២.២. ភារកិច្ចរបស់សារការី

យើងបានរៀបរាប់រួចមកហើយអំពីសិទ្ធិអំណាចរបស់សារការី នៅក្នុងការអនុវត្តមុខងាររបស់ខ្លួន ដែលសិទ្ធិអំណាចទាំងនោះពិតជាមានសារៈសំខាន់ណាស់ ក្នុងការជួយសម្រួលដល់ការងារផ្នែកច្បាប់រួមទាំងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់នៅកម្ពុជា។ ទទឹមនឹងសិទ្ធិអំណាចរបស់សារការីដែលច្បាប់បានផ្ដល់ឲ្យ សារការីក៏មានកាតព្វកិច្ចដែលច្បាប់បានភ្ជាប់មកជាមួយនឹងសិទ្ធិរបស់ខ្លួនផងដែរ។

### ២.២.១. ប្រឹក្សាយោបល់ដល់គូភាគី

សារការី ជាការចាំបាច់ត្រូវតែជូនដំណឹងដល់គូភាគីទាំងអស់អំពីធាតុសំខាន់ៗមួយចំនួនដែលចាំបាច់ដែលនឹងត្រូវធ្វើនៅក្នុងលិខិត ឬកិច្ចសន្យាដែលគូភាគីមានបំណងនឹងធ្វើនោះ ចំពោះមុខខ្លួនជាសារការី។ ការប្រឹក្សារបស់សារការី គឺជាកាតព្វកិច្ចដែលត្រូវផ្ដល់ឲ្យគូភាគីនូវឱវាទ ឬជាការប្រឹក្សាដែលមានលក្ខណៈច្បាស់លាស់ ដោយគិតគូពីផលប្រយោជន៍ដែលមាន នឹងជូនគូភាគីទាំងអស់ដែលមាន។ យោងតាមបញ្ញត្តិនៃព្រះរាជក្រម លេខ៩១០ នស ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ បានចែងថា ករណីកិច្ចជាដើមរបស់សារការី គឺត្រូវបំភ្លឺ ឲ្យដំណឹងនឹងទូន្មានគូសញ្ញាអំពីលិខិតដែលអ្នកនេះបានធ្វើ ឬមានបំណងនឹងធ្វើ ហើយដោយខ្លួនជាមន្ត្រីសាធារណៈត្រូវពិនិត្យឲ្យដឹងថា សេចក្ដីកត់ចុះក្នុងលិខិតទាំងនោះត្រឹមត្រូវតាមការពិត្យ[៤០]។ យោងតាមការសង្កេតលើការអនុវត្តជាក់ស្ដែងបានបង្ហាញថា ក្នុងការតាក់តែងលិខិតគតិយុត្ត ឬលិខិតយថាភូតផ្សេងៗ សារការីត្រូវធ្វើការប្រឹក្សាយោបល់ដល់គូភាគីនៃទាំងសងខាង អំពីលិខិតស្នាមដែលគូភាគីស្នើសុំអោយធ្វើ សារការីមិនត្រឹមតែពន្យល់អំពីផលប្រយោជន៍ជូនដល់គូភាគីនោះទេ សារការីត្រូវពន្យល់អំពីផលប៉ះពាល់ រួមទាំងបញ្ហាផ្សេងៗដែលអាចទទួលបាន ឬកើតឡើងទៅថ្ងៃមុខ ក្នុងការធ្វើលិខិត ឬកិច្ចសន្យាយថាភូតនោះ។ ដើម្បីជៀសវាងការដែលមានបញ្ហាទៅពេលក្រោយ ដែលនឹងនាំអោយមានវិវាទ និងព្យសនកម្មផ្សេងៗដែលអាចកើតឡើងដោយការភាន់ច្រលំ ការធ្វេសប្រហែសផងដែរ។

[៣៨] មាត្រា៣៥៧ ក្រមនីតិវិធីរដ្ឋប្បវេណី

[៣៩] មាត្រា៣៥៧ ក្រមនីតិវិធីរដ្ឋប្បវេណី

[៤០] មាត្រា១ កថាខណ្ឌ២ ចំណុច២ ព្រះរាជក្រម លេខ៩១០ ន.ស

### ២.២.២. ការជូនដំណឹងដល់គូភាគីករណីមានកែប្រែ ឬបញ្ហាផ្សេងៗ

សារការី ជាអ្នកទទួលក្នុងការធ្វើការតាក់តែងលិខិត ឬកិច្ចសន្យាជាយថាភូត បែបនេះហើយ ការជូនដំណឹងដល់គូភាគី គឺជារឿងចាំបាច់បំផុតរបស់សារការី។ ការជូនដំណឹងដោយសារការីដល់គូភាគី ក្នុងករណីមានការកែប្រែត្រង់ចំណុចណាមួយនៃលក្ខន្តិកៈ ឬខ្លឹមសារនៃលិខិតយថាភូតមានបញ្ហាណាមួយមិនប្រក្រតី ឬក៏បញ្ហាច្បាប់ នឹងបញ្ហាផ្សេងៗ ដែលអាចនាំឲ្យមានផលប៉ះពាល់ដល់គូភាគីទាំងសងខាង ឬភាគីណាមួយនៃលិខិត ឬកិច្ចសន្យានោះ។ ករណីកិច្ចជាដើមរបស់សារការី គឺត្រូវបំភ្លឺ ឲ្យដំណឹងនឹងទូន្មានគូសញ្ញាអំពីលិខិត ដែលអ្នកនេះបានធ្វើ ឬមានបំណងនឹងធ្វើ ហើយដោយខ្លួនជាមន្ត្រីសាធារណៈត្រូវពិនិត្យឲ្យដឹងថា សេចក្ដីកត់ចុះក្នុងលិខិតទាំងនោះត្រឹមត្រូវតាមការពិត្យ[៥១]។ បើយើងសង្កេតឲ្យបានច្បាស់ការជូនដំណឹងទៅដល់គូភាគីនេះ ប្រៀបដូចទៅនឹងក្រមសីលធម៌នៃវិជ្ជាជីវៈសារការី ក៏ដូចជាវិជ្ជាជីវៈសេរីផ្សេងៗទៀតផងដែរ ដើម្បីជាផលប្រយោជន៍របស់គូភាគីរួមទាំងដំណើរការនៃលិខិតនោះមានភាពរលូនទៅមុខបានឆាប់រហ័ស គ្មានការជាប់គាំមិនតែប៉ុណ្ណោះ វាក៏ជាក្រមសីលធម៌ដ៏ល្អរបស់សារការី ឬវិជ្ជាជីវៈផ្សេងៗទៀតផងដែរ។

### ២.២.៣. ពិនិត្យ និងផ្ទៀងផ្ទាត់អត្តសញ្ញាណ

នៅក្នុងការតាក់តែង និងការបញ្ជាក់ផ្ដល់សុពលភាព ឬផ្ដល់យថាភូត លើលិខិតគតិយុត្ត ឬកិច្ចសន្យាផ្សេងៗ ជាការចាំចាប់បំផុតក្នុងការពិនិត្យ និងផ្ទៀងផ្ទាត់អត្តសញ្ញាណទាំងអស់ ដែលជាប់ពាក់ព័ន្ធនឹងលិខិតស្នាមដែលបានធ្វើណាមួយនោះ ដើម្បីជៀសវាងបញ្ហាផ្សេងៗដែលនាំឲ្យមានផលលំបាក់នៅក្នុងពេលដំណើរការឯកសារ និងនាពេលខាងមុខ។ យោងតាមបញ្ញត្តិនៃព្រះរាជក្រមលេខ៩១០ ន.ស មាត្រា១ កថាខណ្ឌ២ ចំណុច២ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ មានចំណុចមួយចំនួនបានចែងថា សារការី ត្រូវពិនិត្យឲ្យដឹងថា សេចក្ដីកត់ចុះក្នុងលិខិតទាំងនោះត្រឹមត្រូវតាមការពិត្យ។ សារការីចាំបាច់ នឹងខានពុំបានចំពោះការផ្ទៀងផ្ទាត់ទៅលើអត្តសញ្ញាណមួយចំនួនរបស់គូ-ភាគី សាក្សី ក៏ដូចជាពិនិត្យផ្លូវច្បាប់ ដែលមិនអាចធ្វេសប្រហែសបាននោះទេ ក្នុងការតាក់តែងលិខិត និងកិច្ចសន្យាទាំងឡាយដែលនឹងធ្វើ។

#### ក. អត្តសញ្ញាណគូភាគី

សារការី ត្រូវធ្វើការពិនិត្យលើអត្តសញ្ញាណគូភាគីនេះ ត្រូវពិនិត្យផ្ទៀងផ្ទាត់មើលទៅ លើឈ្មោះគូភាគីទាំងសងខាង ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត អាយុ មុខងារ ឬតួនាទី នឹងអាស័យដ្ឋានបច្ចុប្បន្នរបស់គូភាគីសងខាង ថាពិតជាមានភាពត្រឹមត្រូវច្បាស់លាស់ ការពិនិត្យភាគីច្រើនពិនិត្យ

[៥១] មាត្រា១ កថាខណ្ឌ២ ចំណុច២ ព្រះរាជក្រមលេខ៩១០ ន.ស

លើអត្តសញ្ញាណប័ណ្ណ សំបុត្រកំណើត សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬប័ណ្ណសម្គាល់ខ្លួនផ្សេងៗទៀត ដែលអាចធ្វើការកំណត់នៅអត្តសញ្ញាណនៃភាគីទាំងនោះ។

**ខ. អត្តសញ្ញាណនៃទ្រព្យ**

ការធ្វើការពិនិត្យអត្តសញ្ញាណទ្រព្យ គឺពិនិត្យទៅលើប្រភេទទ្រព្យ ថាជាទ្រព្យអវិភាគ ឬទ្រព្យរួម ឬជាទ្រព្យ ឯកបុគ្គល ឬម៉ាក ឬសេរី ទំហំ ទីតាំង កម្មសិទ្ធិស្របច្បាប់របស់គូភាគីទាំងសងខាងថាពិតប្រាកដដោយមិនមានជាប់ពាក់ព័ន្ធជាមួយនឹងទ្រព្យសម្បត្តិរបស់សាធារណៈ ឬបុគ្គលសាធារណៈ ឬពាក់ព័ន្ធនឹងកម្មសិទ្ធិរបស់បុគ្គល ឬនីតិបុគ្គលឯកជនណាមួយផ្សេងទៀតឡើយវាងធ្វើឲ្យមានទំនាស់ និងបញ្ហាផ្សេងៗទៀតផងដែរ។ ជាក់ស្តែងក្នុងករណីពិនិត្យទៅលើអត្តសញ្ញាណនៃទ្រព្យ សារការីធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់ទៅលើឯកសារដែលពាក់ព័ន្ធដូចជា ប្លង់ដី ប្លង់ផ្ទះជាដើម ដែលមានការបញ្ជាក់ភាពត្រឹមត្រូវពីស្ថាប័នមានសមត្ថកិច្ច។

**គ. ពិនិត្យ និងផ្ទៀងផ្ទាត់លើច្បាប់**

ជាធម្មតានៅក្នុងការតាក់តែងលិខិតគតិយុត្ត ទោះបីជាយើងបានផ្ទៀងផ្ទាត់ទៅលើអត្តសញ្ញាណគូភាគី អត្តសញ្ញាណទ្រព្យរបស់គូភាគីថាពិតជាត្រឹមត្រូវស្របតាមច្បាប់រួចហើយក៏ដោយ។ ការតាក់តែងលិខិតនេះមិនអាចភ្លេចក្នុងការពិនិត្យទៅលើកម្មវត្ថុរបស់លិខិតនោះបានទេ ពិនិត្យឲ្យបានច្បាស់ថាកម្មវត្ថុនៃលិខិតនោះត្រូវបានច្បាប់អនុញ្ញាតឲ្យ។ រួមជាមួគ្នានោះដែល គប្បីពិនិត្យផងដែរទៅលើលក្ខខណ្ឌដែលមានចែងក្នុងលិខិតថាអាចនឹងអនុវត្តទៅបានដោយគ្មានបញ្ហាអ្វី និងមិនប៉ះពាល់ទៅបញ្ញត្តិណាមួយដែលច្បាប់បានហាមឃាត់ ដែលនាំអោយខាតបង់ដល់គូភាគីទាំងសងខាង នឹងប៉ះពាល់ដល់សីលធម៌របស់សង្គមជាតិ ក៏ដូចជាការខូចខាតនូវទ្រព្យ សម្បត្តិសាធារណៈ។ ដូចនេះហើយ ការពិត្យលើអត្តសញ្ញាណទាំងអស់ដែលបានរៀបរាប់ខាងលើ វាជាការដែលមិនអាចខ្វះបាន នៅក្នុងការតាក់តែងលិខិតគតិយុត្ត និងកិច្ចសន្យាផ្សេងៗ ដែលត្រូវបានធ្វើឡើងដោយសារការី។

**២.២.៤. ការទទួលខុសត្រូវក្នុងការបំពេញមុខងារខ្លួន**

យើងបានដឹងតាមការរៀបរាប់ខាងលើថា សារការីជាអ្នកជំនាញផ្នែកច្បាប់ ដែលមានសិទ្ធិក្នុងការប្រឹក្សាយោបល់ ជាអ្នកតាក់តែង និងផ្តល់យថាភូត រួមទាំងការបញ្ជាក់លើលិខិត ឬកិច្ចសន្យាផ្សេងៗ ដែលបានស្នើសុំពីរូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ។ ភ្ជាប់ជាមួយនឹងសិទ្ធិដែលទទួលបានក្នុងការធ្វើកិច្ចការងារដែលបាន និយាយរៀបរាប់ខាងលើ ឬក៏ការរៀបរាប់ក្នុងផ្នែកផ្សេងៗខាងលើទាំងអស់នោះ សារការីបានត្រូវតម្រូវឲ្យមានកាតព្វកិច្ច ឬអាចនិយាយបានថាជាក្រមសីលធម៌មួយរបស់វិជ្ជាជីវៈសេរីមួយនេះផងដែរ ដែលត្រូវឲ្យមានជាចាំបាច់ ដែលមិនអាចខ្វះបាននោះគឺៈ

**ក. ការរក្សាការសម្ងាត់**

ការរក្សាការសម្ងាត់របស់គូភាគីទាំងសងខាងនៃលិខិតជាកត្តាសំខាន់មួយ ដែលសារការីមិនត្រូវបង្ហើបឲ្យព័ត៌មានសម្ងាត់របស់គូភាគីឲ្យលេចលឺដល់ជនទីបីនោះឡើយ[៤២]។ ការរក្សាការសម្ងាត់នេះ ជាទូទៅមានស្ទើតែគ្រប់ វិស័យទៅហើយដូចជា វិជ្ជាជីវគ្រូពេទ្យ មេធាវី ក្រឡាបញ្ជី ចៅក្រមព្រះរាជអាជ្ញា អ្នកច្បាប់ជាដើម។ ការសម្ងាត់នេះនឹងធ្វើឲ្យមានការប៉ះពាល់ទៅដល់កត្តិយស កេរ្តិ៍ឈ្មោះតួនាទីរបស់គូភាគីទាំងសងខាង ប្រសិនបើជាលិចលឺទៅខាងក្រៅពីភាគីពាក់ព័ន្ធនៃលិខិត ដូចនេះហើយសារការីចាំបាច់ត្រូវតែរក្សាការសម្ងាត់នេះឲ្យគូភាគីទាំងនោះ។

**ខ. ការផ្តល់សមភាព**

សមភាពបានផ្តោតទៅលើផ្នែកជាច្រើនដែលតម្រូវឲ្យមានដល់គូភាគី ដែលសារការីជាអ្នកដែលមានកាតព្វ កិច្ចក្នុងការផ្តល់ទៅឲ្យភាគីទាំងអស់ ដែលបានពឹងពាក់ខ្លួនឲ្យជួយក្នុងកិច្ចការងារអ្វីមួយ ដូចជាការតាក់តែងបណ្តាំ មតកសាសន៍ ឬកិច្ចសន្យាផ្សេងៗ។ ការផ្តល់សមភាពដែលសារការីត្រូវផ្តល់ឲ្យគូភាគីនៃលិខិតនោះ ជាភាពមិនលំអៀងទៅភាគីម្ខាងណាមួយ ត្រូវមានភាពស្មើគ្នាលើផ្នែកច្បាប់ មិនផ្តល់ផលប្រយោជន៍ឲ្យទៅភាគីតែម្ខាង គឺគូភាគីទាំងអស់ត្រូវទទួលបានផលប្រយោជន៍ កាតព្វកិច្ច និងផលដែលត្រូវបាត់បង់មានភាពស្មើៗគ្នា។ សារការី ត្រូវប្រាកដថាកិច្ចការងារដែលខ្លួនបានធ្វើនោះមានភាពច្បាស់លាស់ពិតប្រាកដត្រឹមត្រូវ និងផ្តល់ភាពស្មើៗគ្នាដល់គូភាគីដែលបានពឹងពាក់ខ្លួន។

**គ. ព្យសនកម្ម**

យោងតាមការឲ្យនិយមន័យនៃ ពាក្យព្យសនកម្មមានន័យថា ជាការខូចខាត ឬសេចក្តីវិនាសអន្តរាយ ដល់រូបរាងកាយក្តី ដល់សម្ភារៈក្តី ដល់ទឹកចិត្តក្តី ដែលបណ្តាលមកពីអំពើរបស់អ្នកដទៃ។ ដូចគ្នានេះផងដែរ ព្យសនកម្មដែលកើតឡើងដោយអំពើរបស់សារការី បណ្តាលមកពីការធ្វេសប្រហែសខ្វះការប្រុងប្រយ័ត្នក្នុងការបំពេញកិច្ចការងារនៃមុខងាររបស់ខ្លួនដែលធ្វើឲ្យខូចខាតដល់ផលប្រយោជន៍របស់រូបវន្ត ឬនីតិបុគ្គល ដែលបានពឹងពាក់ខ្លួនឲ្យជួយក្នុងកិច្ចការងារអ្វីមួយ។ ឧទាហរណ៍: សារការីបានថែងអំពីចំនួនទឹកប្រាក់ខុស នៅក្នុងកិច្ចសន្យាលក់ទិញផ្ទះមួយ ដែលខ្លួនបានតាក់តែង។ ជាក់ស្តែងការធ្វើឲ្យខូចខាតដល់ផលប្រយោជន៍របស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបណ្តាលមកពីការធ្វេសប្រហែសក្នុងការបំពេញមុនងាររបស់សារការី ជាកាតព្វកិច្ចសារការីត្រូវជុសជួលនូវព្យសនកម្មនោះជូនដល់ភាគីដែលទទួលរងព្យសនកម្ម។ ដោយយោងតាមមាត្រាមួយចំនួននៃអនុក្រឹត្យ ស្តីពីការបង្កើត

[៤២] មាត្រា១៣ ព្រះរាជក្រមលេខ៩១០

មន្ទីរសារការីផ្សេងៗ នៃព្រះរាជាណាចក្រកម្ពុជាបានចែងថាមន្ទីរសារការី ត្រូវតម្កល់ប្រាក់ចំនួន ៦០០.០០០.០០០ (ប្រាំមួយរយលាន) រៀល នៅធនាគាជាតិនៃកម្ពុជា សម្រាប់ធានាការទទួលខុសត្រូវក្នុងការបំពេញមុខងាររបស់ខ្លួន[៩៣]។

## ២.៣. ដែនសមត្ថកិច្ចរបស់សារការី

យើងបាននិយាយរៀបរាប់ពីសិទ្ធិរបស់សារការីរួចមកហើយនៅក្នុងចំណុចខាងលើ ទទឹមជាមួយនឹងសិទ្ធិកាតព្វកិច្ចរបស់សារការីដែលច្បាប់បានផ្តល់ឲ្យ ប៉ុន្តែច្បាប់ក៏បានចែងទាក់ទងនឹងដែនសមត្ថកិច្ចរបស់សារការី ក៏ដូចជាចែងអំពីការមិនអាចអនុវត្តបាននៃសិទ្ធិរបស់សារការីផងដែរ។ ជាក់ស្តែងយោងតាមមាត្រា១០ ផ្នែកទី៣ កាតព្វកិច្ច សិទ្ធិរបស់សារការី នៃព្រះរាជក្រម លេខ៩១០ ន.ស ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ និងមាត្រា១១៧២ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ដែលបានចែងទាក់ទងនឹងការមិនអាចអនុវត្តបាននៃសិទ្ធិរបស់សារការីផងដែរ។ តើការអនុវត្តសិទ្ធិ កាតព្វកិច្ចរបស់សារការី និងការមិនអាចអនុវត្តបាននៃសិទ្ធិរបស់សារការីមានការកំណត់យ៉ាងណា?

### ២.៣.១. ការអនុវត្តសិទ្ធិ កាតព្វកិច្ចសារការី

នៅចំណុចខាងលើបានរៀបរាប់អំពីសិទ្ធិរបស់សារការីរួចមកហើយ ថាសារការីមានសិទ្ធិក្នុងការប្រឹក្សាយោបល់ ជាពិសេសពាក់ព័ន្ធនឹងផ្នែកច្បាប់ហើយទទួលការតាក់តែង និងផ្តល់លិខិយថាភូតការបញ្ជាក់ ទៅលើរាល់លិខិត ឬកិច្ចសន្យាផ្សេងៗ រួមទាំងកិច្ចការផ្សេងទៀតដែលច្បាប់ផ្តល់ឲ្យ។ សារការីធ្វើការអនុវត្តសិទ្ធិរបស់ខ្លួនទៅតាមបញ្ញត្តិ នៃច្បាប់ដូចជា ព្រះរាជក្រមលេខ៩១០ ន.ស ចុះ ថ្ងៃទី ០៤ ខែវិច្ឆិកា គ.ស.១៩៥៤ ដែលពុំទាន់មានបញ្ញត្តិណាមួយមកជំនួសទាំងស្រុង ឬធ្វើការនិរាករណ៍លើកព្រះរាជក្រមនេះនៅឡើយទេ ប៉ុន្តែសព្វថ្ងៃមានបញ្ញត្តិច្បាប់មួយចំនួន បានចែងបន្ថែមទៅលើកសិទ្ធិ នឹងកាតព្វកិច្ចរបស់សារការី ក៏ដូចជាជំនួសទៅលើមាត្រាមួយចំនួននៃព្រះរាជក្រមលេខ៩១០ ន.ស ដូចជា ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី និងធ្វើការចាត់ចែង ផ្សេងៗទៀត ដែលកំណត់ក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌ រហូតដល់កាលបរិច្ឆេទ នៃការអនុវត្តច្បាប់ ស្តីពីលក្ខន្តិកៈសារការីចូលជាស្ថាពរ។

### ២.៣.២. ការមិនអាចអនុវត្តបាននៃសិទ្ធិរបស់សារការី

បើទោះបីជាមានបញ្ញត្តិច្បាប់ជាច្រើន បានផ្តល់នូវសិទ្ធិឲ្យសារការីជាអ្នកអនុវត្តទាក់ទងនឹងកិច្ចការងារផ្នែកច្បាប់ ដូចជាការតាក់តែង និងផ្តល់យថាភូតលើលិខិត ឬកិច្ចសន្យាផ្សេងៗ ដូចជា

[៩៣] មាត្រា៥ អនុក្រឹត្យលេខ៥២ អនក្រ.បក ស្តីពីការបង្កើតមន្ទីរសារការីអង្គរ

កិច្ចសន្យាលក់ទិញ កិច្ចសន្យាបង្កើតហ៊ីប៉ូតែក ក៏ដូចជាកិច្ចការផ្នែកច្បាប់ផ្សេងទៀតផងដែរ ។ បើទោះបីជាយ៉ាងណាក្តី ក៏នៅមានកិច្ចការមួយចំនួនទៀតរបស់សារការី មិនទាន់មានអានុភាពនៅឡើយ ដោយ សារបញ្ហាការផ្សព្វផ្សាយ និងបញ្ហាផ្នែកច្បាប់មួយចំនួនផងដែរ។

### ក. បញ្ហាការផ្សព្វផ្សាយ

សារការីជាវិជ្ជាជីវៈមួយ ដែលទើបកើតឡើងជាថ្មីម្តងទៀតដូចបានរៀបរាប់នៅក្នុងសេចក្តីផ្តើមរួចមកហើយ ទើបធ្វើប្រជាពលរដ្ឋមួយចំនួនពុំទាន់បានស្គាល់ នឹងយល់ដឹងអំពីវិជ្ជាជីវៈសារការីនេះ។ ពេលខ្លះកុំថាឡើយប្រជាពលរដ្ឋ សូម្បីតែមន្ត្រីរាជការមួយចំនួនក៏ពុំទាន់ដឹងថាសារការីជាអ្វីនៅឡើយទេ ដូចនេះហើយទើបធ្វើឲ្យលិខិតយថាភូតរបស់សារការីពុំទាន់មានការទទួលស្គាល់ និងអានុ-ភាពអនុវត្តចំពោះប្រជាពលរដ្ឋ និងមន្ត្រីរាជការទាំងអស់នោះ។

### ខ. ការបែងចែកមិនច្បាស់លាស់ក្នុងការអនុវត្ត

ការបែងចែកសមត្ថកិច្ចមិនបានច្បាស់លាស់រវាងសារការី និងមន្ត្រីផ្សេងទៀត គឺជាបញ្ហាប្រឈមមួយ ក្នុងការអនុវត្តសិទ្ធិរបស់សារការី ជាក់ស្តែងប្រកាសអន្តរក្រសួងលេខ១៥៩ ប្រក/ជនស./ម.ផ បានចែងថា មេឃុំ ចៅសង្កាត់ ជាអ្នកបញ្ជាក់លើលិខិតសញ្ញាផ្សេងៗដូចជា លិខិតលក់ផ្តាច់ អំណោយផ្តាច់ កិច្ចសន្យាបញ្ចាំ ដាក់ធានា ហ៊ីប៉ូតែក កិច្ចសន្យាជួលរយៈពេលវែង កិច្ចសន្យាបង្កើតសេវភាពផលុបភោគ អាស្រ័យលើការ ព្រមព្រៀងរបស់គូភាគី(ប្រការ៩)[៩៩]។ ដោយឡែកនៅក្នុងការមាត្រា៩ ចំណុច ក នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី បានចែងថា ចំពោះលិខិតយថាភូតដែលកំណត់ក្នុងមាត្រា៣៣៦(ការបង្កើតកិច្ចសន្យាដោយសំណើ និងស្ទីការ) និងមាត្រា៨៦២(អានុភាពនៃការចាត់ចែងហ៊ីប៉ូតែក)នៃក្រមរដ្ឋប្បវេណី លិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើយ ដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជី ក៏ជាលិខិតយថាភូតដែរ។ ប៉ុន្តែនៅក្នុងមាត្រាដដែលនេះ ក៏បានចែងថាលិខិតយថាភូតដែលកំណត់ក្នុងមាត្រា៣៣៦(ការបង្កើតកិច្ចសន្យាដោយសំណើ និងស្ទីការ) មាត្រា៥១៦(ការបង្កើតកិច្ចសន្យាលក់ទិញ) និងមាត្រា៨៦២(អានុភាពនៃការចាត់ចែងហ៊ីប៉ូតែក)នៃក្រមរដ្ឋប្បវេណី សំដៅលើលិខិតដែលត្រូវធ្វើឡើងដោយសារការី ឬលិខិតឯកជនដែលសារការីចុះនិទ្ទេសថា លិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់។ ម៉្យាងទៀតយោងតាមសទ្ធានុក្រមក្រមរដ្ឋប្បវេណី២០០៧ បានផ្តល់សមត្ថកិច្ចក្នុងការធ្វើលិខិតយថាភូតទៅឲ្យសារការីតែម្តង។ យោងតាមការអនុវត្តជាក់ស្តែង ការបញ្ជាក់លើកិច្ចសន្យាដាក់ បញ្ចាំលិខិតលក់ផ្តាច់ កិច្ចសន្យាមួយចំនួនទៀត ត្រូវបានធ្វើការបញ្ជាក់ដោយ មេភូមិ ចៅសង្កាត់ មិនតែប៉ុណ្ណោះលិខិត ឬកិច្ចសន្យាមួយចំនួនទៀតដែលសារការីធ្វើបញ្ជាក់ ចៅសង្កាត់ អភិបាលខណ្ឌ ក៏អាច

[៩៩] ប្រការ៩ ប្រកាសអន្តរក្រសួងលេខ ១៥៩ ប្រក/ជនស./ម.ផ

បញ្ជាក់បានដូចគ្នាផងដែរ។ ដូចនេះយើងអាចទាញបានថាសិទ្ធិក្នុងការអនុវត្តរបស់សារការី មានសមត្ថកិច្ចត្រួតស៊ីគ្នា ជាមួយសមត្ថកិច្ចក្នុងការអនុវត្តរបស់មន្ត្រីផ្សេងទៀត នេះហើយជាកត្តាមួយដែលជំរុញ ឲ្យសារការីមិនអាចអនុវត្តបាននូវសិទ្ធិរបស់ខ្លួន។

**គ. ការប្រមូលពន្ធ**

យោងតាមមាត្រា១១ ចំណុច៣ នៃច្បាប់ស្តីពីការអនុក្រម បានចែងថាបុគ្គលដែលប្រើប្រាស់សេវា របស់មន្ត្រីទទួលបន្ទុកកិច្ចការសារការីត្រូវបង់ពន្ធ។ ចំណូលនេះត្រូវបង្វែរចូលទៅថវិការដ្ឋ។ ក្នុងន័យនេះ សំដៅថាសារការីជាភ្នាក់ងារប្រមូលពន្ធមួយ ដែលមានសិទ្ធក្នុងការប្រមូលពន្ធជូនរដ្ឋ ប៉ុន្តែបើយើងងាកមកមើលការអនុវត្តជាក់ស្តែង សារការីមិនអាចអនុវត្តបាននូវមុខងារជាភ្នាក់ងារក្នុងការប្រមូលពន្ធជូនរដ្ឋនោះទេ ដោយសារការប្រមូលពន្ធត្រូវបានស្ថាប័នអគ្គនាយកដ្ឋានពន្ធដាជាអ្នកក្តោបក្តាប់នឹងមើលការខុសត្រូវ ដូចនេះហើយសារការីមិនអាចអនុវត្តសិទ្ធិក្នុងការប្រមូលពន្ធបានទេ។

**ឃ. ការកំណត់នៃច្បាប់**

មានបញ្ញត្តិច្បាប់មួយចំនួន បានចែងទាក់ទងនឹងសមត្ថកិច្ច របស់សារការីដែលត្រូវបានហាមឃាត់ ដោយសារការីមិនអាចតាក់តែង ឬផ្តល់យថាភូតទៅលើលិខិតរបស់ខ្លួនឯងផ្ទាល់ បងប្អូន ញាតិជួរត្រង់ ឬសាខាញាតិរហូតដល់ថ្នាក់ក្មួយបាននោះទេ។ នៅក្នុងករណីខាងលើនេះ សារការី ឬញាតិខាងលើ ត្រូវទៅពឹងពាក់សារការីផ្សេងទៀត ដើម្បីទទួលធ្វើនៅកិច្ចការដែលខ្លួនត្រូវធ្វើ។ បើយោងព្រះរាជក្រមលេខ ៩១០ ន.ស បានចែងថាសារការី គ្មានសមត្ថកិច្ចនឹងទទួលលិខិត ដែលខ្លួន បងប្អូនខ្លួន, ញាតិជួរត្រង់ ឬសាខាញាតិរហូតដល់ថ្នាក់មានក្មួយ គិតទាំងថ្នាក់នេះផង ត្រូវធ្វើជាគូសញ្ញា ឬលិខិតដែលមានបញ្ញត្តិ ថាត្រូវឲ្យផលប្រយោជន៍ដល់ខ្លួន ឬបងប្អូននេះទេ[៩៥]។ ជនដែលមានសំបែងនៅវគ្គខាងលើ ត្រូវចាងហ្វាង សាលាជំរះក្តី បើកអនុញ្ញាតឲ្យទៅពឹងរកសារៈការីឯទៀត ដែលគ្មានសមត្ថកិច្ចតាមនាទីទេ [៩៦]។

[៩៥] ប្រការ១០ កថាខណ្ឌ១ ព្រះរាជក្រមលេខ ៩១០ ន.ស

[៩៦] ប្រការ១០ កថាខណ្ឌ១ ព្រះរាជក្រមលេខ ៩១០ ន.ស

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ដូចដែលបានបង្ហាញនៅក្នុងការអត្ថាធិប្បាយខាងលើរួចមកហើយ អំពីការចាប់កំណើតជាថ្មីម្តងទៀតនៃវិជ្ជាជីវសារការីនៅក្នុងនីតិរដ្ឋថ្មីនេះ ហេតុនេះហើយសារការីមានចំនួនតិចតួចនៅឡើយ ហើយវិសាលភាពរបស់សារការីទៀតសោតនូវមិនទាន់មានភាពទូលំទូលាយនៅឡើយទេ រហូតមកដល់ពេលនេះមានប្រជាពលរដ្ឋប្រមាណមិនដល់៣០ភាគរយផងដែលបានស្គាល់ និងយល់ដឹងអំពីវិជ្ជាជីវៈសារការី ហើយស្របពេលដែលសារការីក៏មានចំនួនកើតឡើងជាបន្តបន្ទាប់ ហើយក៏មានការកកើតមន្ទីរសារការីជាច្រើនផងដែរ ប៉ុន្តែនៅតែមិនទាន់អាចឆ្លើយតបទៅនឹងតម្រូវការក្នុងពេលបច្ចុប្បន្ននេះនោះទេ។

សារការី ជាអ្នកជំនាញផ្នែកច្បាប់ដោយបុគ្គលដែលអាចក្លាយជាសារការី សុទ្ធសឹងតែជាបុគ្គលដែលមានចំណេះដឹងជ្រៅជ្រះ និងមានបទពិសោធន៍ក្នុងវិស័យច្បាប់យូរឆ្នាំ ពិសេសសារការីដែលបានឆ្លងកាត់ការបណ្តុះបណ្តាល យ៉ាងយកចិត្តទុកដាក់ពីសំណាក់សាលាភូមិន្ទ នៃរាជបណ្ឌិសភាពវិជ្ជាជីវៈតុលាការ។ បច្ចុប្បន្នសារការីបានដើរតួយ៉ាងសំខាន់នៅក្នុងវិស័យ ច្បាប់ ជាពិសេសក្នុងទំនាក់ទំនងផ្សេងៗរវាងរូបវន្តបុគ្គលក៏ដូចជានីតិបុគ្គល ដែលទាក់ទងនឹងកិច្ចគតិយុត្តក្នុងវិស័យអចលទ្រព្យ គ្រួសារ ក្រុមហ៊ុន ដែលទាមទារការចូលរួមជាចាំបាច់នៃវត្តមានរបស់សារការី។ សារការី ជាអ្នកធានាការពារផលប្រយោជន៍របស់គូភាគី ដែលបានពឹងពាក់ខ្លួនឲ្យជៀសផុតពីការកេងប្រវ័ញ្ច ការក្លែងបន្លំ ការឆបោក និងល្បិចកលទុច្ចរឹតគ្រប់បែបយ៉ាង និងតាមរូបភាពធ្វើជាលិខិតស្នាម ឬកិច្ចសន្យាផ្សេងៗ។ ដោយលិខិតយថាភូត ដែលសារការីបានចារឹកឡើងជូនទៅដល់គូភាគី ដូចជាកិច្ចសន្យាលក់ទិញ ជួល ហ៊ីប៉ូតែក មតកសាសន៍ គឺមានការផ្តល់ប្រឹក្សាយោបល់ពីសំណាក់សារការី ហើយលក្ខណៈច្បាស់លាស់ និងភាពទទួលខុសត្រូវខ្ពស់ក្នុងការតាក់តែងលិខិតរបស់ខ្លួន ដោយត្រូវបានពិនិត្យយ៉ាងម៉ត់ចត់ រួមទាំងមានការទុកដាក់នឹងរក្សាការសម្ងាត់យ៉ាងត្រឹមត្រូវបំផុត ដែលយើងអាចនិយាយបានថានេះជាកាតព្វកិច្ចរបស់សារការីផងដែរ។

ជាចុងក្រោយ យើងអាចសន្និដ្ឋានបានថាសារការីជាវិជ្ជាជីវៈមួយ ដែលសង្គមនៃការរស់នៅបច្ចុប្បន្នត្រូវការជាចាំបាច់មិនតែប៉ុណ្ណោះសិទ្ធិ និងកាតព្វកិច្ចរបស់សារការីបានដើរតួយ៉ាងសំខាន់បំផុតនៅក្នុងវិស័យច្បាប់ ដែលជួយជំរុញក្នុងការអភិវឌ្ឍនៃការអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវមានសមភាព តម្លាភាព យុត្តិធម៌ ភាពឆាប់រហ័ស និងផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការពឹងពាក់ផងដែរ។ តួយ៉ាងជាមួយសារៈសំខាន់នៃសិទ្ធិ និងកាតព្វកិច្ចរបស់សារការីនេះ មានបញ្ញត្តិមួយចំនួនដែលចែងមិនច្បាស់លាស់អំពីសមត្ថកិច្ចរបស់សារ-ការីនឹងធ្វើឲ្យសារការីមិនអាចអនុវត្តបាននូវសិទ្ធិរបស់ខ្លួនមួយចំនួនបានពេញលេញនៅឡើយទេ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានបញ្ចប់ការសិក្សាស្រាវជ្រាវ អំពីសិទ្ធិ និងកាតព្វកិច្ចសារការី ក្រុមខ្ញុំបាទ បានសង្កេតឃើញថាសិទ្ធិ និងកាតព្វកិច្ចសារការី ពិតជាសារៈសំខាន់ណាស់ក្នុងការជួយជំរុញ ការអនុវត្តច្បាប់ដោយកាន់តែប្រសើរឡើង។ ជាមួយគ្នានោះដែរ ក្រុមខ្ញុំបាទយល់ឃើញថាមានចំណុចមួយចំនួនដែលជួយជំរុញឲ្យដំណើរការក្នុងការអនុវត្តលើសិទ្ធិ និងកាតព្វរបស់សារការី មានភាពល្អប្រសើរជាងពេលបច្ចុប្បន្ននេះ ដែលមានការរៀបរាប់ដូចខាងក្រោមៈ

សារការីជាវិជ្ជាជីវៈមួយ ដែលប្រជាពលរដ្ឋភាគច្រើនពុំទាន់បានយល់ដឹងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់សារការីណាស់ ដោយសារវិជ្ជាជីវៈនេះទើបនឹងចាប់កំណើតជាថ្មីម្តងទៀត ក្នុងនីតិរដ្ឋថ្មីនេះ ដូចនេះស្ថាប័នរដ្ឋ ឬស្ថាប័នពាក់ព័ន្ធ គួរតែបង្កើនការផ្សព្វផ្សាយគ្រប់រូបភាពទាក់ទងនឹងអត្ថប្រយោជន៍ដែលទទួលបានពី ការទទួលសេវាកម្ម ការអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់សារការីទៅដល់ប្រជាពលរដ្ឋទាំងអស់។ ម្យ៉ាងទៀតទោះបីជាក្នុងពេលបច្ចុប្បន្ននេះ សារការីមានចំនួនកើនឡើងជាបន្តបន្ទាប់ក៏ពិតមែន ប៉ុន្តែមិនទាន់អាចឆ្លើយតបទៅនឹងតម្រូវការក្នុងពេលបច្ចុប្បន្ននោះទេ ហើយបើយើងទៅលើសារការីដែលបានឆ្លងកាត់ការបណ្តុះបណ្តាលចេញពីសាលាភូមិន្ទសារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ទើបតែបានមួយជំនាន់តែប៉ុណ្ណោះដោយមានចំនួន១៥នាក់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងពេលបច្ចុប្បន្ន ស្ថាប័នរដ្ឋគួរតែមានការបណ្តុះបណ្តាលសារការីបន្ថែមទៀត។ បន្ថែមពីលើការបណ្តុះបណ្តាលវិជ្ជាជីវៈសារការីនេះផងដែរ យើងការបានសង្កេតឃើញថាមានបញ្ញត្តិអំពីសមត្ថកិច្ចរបស់សារការីមួយចំនួនដែលបានចែង មានភាពត្រួតស៊ីគ្នាជាមួយសមត្ថកិច្ចរបស់ស្ថាប័នរដ្ឋមួយចំនួនដូចជាភូមិ សង្កាត់ ខណ្ឌ ដែលជារដ្ឋបាលថ្នាក់ក្រោមជាតិ។ មិនតែប៉ុណ្ណោះប្រទេសកម្ពុជាយើងពុំទាន់មាន បញ្ញត្តិច្បាប់ស្តីពីលក្ខន្តិកៈសារការីនោះទេ នេះជាកត្តាមួយដែលធ្វើឲ្យសារការីពិបាកក្នុងការអនុវត្តសមត្ថកិច្ចរបស់ខ្លួន នេះហេតុផលចម្បងមួយដែលស្ថាប័ននីតិបញ្ញត្តិ ក្រសួង ស្ថាប័នរដ្ឋ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតគួរធ្វើការគិតគូរ និងពិចារណាក្នុងការពន្លឿនការអនុម័ត សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈសារការី ដែលបច្ចុប្បន្ននៅតែជាសេចក្តីព្រាងច្បាប់នៅឡើយ ពីព្រោះច្បាប់នេះពិតជាមានសារៈសំខាន់ណាស់ក្នុងការកំណត់រចនាសម្ព័ន្ធ ការគ្រប់គ្រង ពិសេសការកំណត់នូវដែនសមត្ថកិច្ចនៃការអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់សារការីឲ្យបានច្បាស់លាស់និងកាន់តែមានភាពងាយស្រួលក្នុងការអនុវត្ត។

# ឯកសារយោង

# ឯកសារយោង

## ក. បទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- រាជក្រមលេខ ៩១០ ឆ្នាំ ១៩៥៤ ន.ស ឆ្នាំ១៩៥៤
- ក្រមរដ្ឋប្បវេណី ប្រកាសឲ្យប្រើនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណី ប្រកាសឲ្យប្រើនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦
- ច្បាប់ស្តីពីការអនុវត្តន៍ក្រមរដ្ឋប្បវេណី ដែលប្រកាសឲ្យប្រើ នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១
- អនុក្រឹត្យជាតិ
  - អនុក្រឹត្យ ៨២ អនក្រ.បក ស្តីពីការបង្កើតមន្ទីរសារការី អង្គរ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦
  - អនុក្រឹត្យ ១៨៤ អនក្រ.បក ស្តីពីការទទួលស្គាល់ មន្ទីសារការី អេច ប៊ី អេសនៃព្រះរាជាណា-ចក្រកម្ពុជា ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៨
  - អនុក្រឹត្យ ៥០៥ អនក្រ.តត ស្តីពីការផ្តល់សមត្ថកិច្ចបន្ថែមជាសារការី ដល់មេធាវីនៃគណៈ-មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០១
  - អនុក្រឹត្យលេខ១៧៧ អនក្រ បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨ ជាអនុក្រឹត្យបង្កើតសាលាភូមិន្ទសារការី
- ប្រកាស
  - ប្រកាស លេខ ៨៧ កយ.ប្រក/១២ ស្តីពីការតែងតាំងមន្ត្រីទទួបន្ទុកកិច្ចការសារការី ចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១២
  - ប្រកាស លេខ ៨១ កយ.ប្រក/១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចុះថ្ងៃទី ០៩ ខែសីហា ឆ្នាំ២០១២
  - ប្រកាសអន្តរក្រសួងលេខ ១៥៩ ប្រក/ជនស./ម.ផ ស្តីពីការកែសម្រួលប្រការ៩ នៃប្រកាសអន្តរក្រសួងលេខ២១៥ ប្រក/ជនស.មផ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត ក្នុងការចុះបញ្ជីដីធ្លី ចុះថ្ងៃ១៥ ខែមិថុនា ឆ្នាំ២០១៦

## ខ.សៀវភៅជាតិ និងអន្តរជាតិ

- សៀវភៅ មុខងារសារការីនៃព្រះរាជាណាចក្រកម្ពុជា របស់ លោក អាំង អេងថុង ឆ្នាំ២០១២
- សៀវភៅ ស្តីពីសន្និសិទស្តីពីមុខងារសារការីតាមបែបប្រទេសបារាំង ថ្ងៃទី ១៧-១៨ ខែកុម្ភៈ ឆ្នាំ ២០០៤

# ឧបសម្ព័ន្ធ

# ព្រះរាជក្រម

# អនុក្រឹត្យ

# ប្រកាស

# ឯកសារផ្សេងៗទាក់នឹងការផ្តល់យថាភូត

# អនុក្រឹត្យ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥០៥ អនក្រ.តត

## អនុក្រឹត្យ

ស្តីពី

## ការផ្តល់សមត្ថកិច្ចបន្ថែមជាសារគារីដល់មេធាវី នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

~~~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ ស្តីពីលក្ខន្តិកៈមេធាវី ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៥
- យោងតាមភាពចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

### មាត្រា ១

តែងតាំង លោក វ៉ែនស៊ុន សម័យ សមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជាមាន អត្តលេខ ៥៩ បន្ថែមលើមុខងារបច្ចុប្បន្នជា សារការី ដែលហៅថា "មេធាវីសារការី" ។
~~~~~

**មាត្រា ២.**

មេធាវីសារការីជាមន្ត្រីសាធារណៈ ទទួលបាននូវអំណាចសាធារណៈតាមការតែងតាំងដោយអនុក្រឹត្យនេះ ។

**មាត្រា ៣.**

មេធាវីសារការីមានសមត្ថកិច្ចការងារទូទៅក្នុងវិស័យផ្នែកគ្រួសារ, ចលនវត្ថុ និង អចលនវត្ថុ ជាអាទិមាន :

ក- ទទួល និង ធ្វើ ឬ ចារឹកបញ្ជាក់ និង ប្រថាប់ត្រា នូវលិខិតស្នាមគតិយុត្តិ ឬ កិច្ចសន្យាទាំងឡាយ ដើម្បីផ្ដល់ពេញលក្ខណៈតាមផ្លូវច្បាប់ ដែលតែងតែមានលិខិតរបស់រាជការអំណាចសាធារណៈ ។

ខ- ធ្វើការបញ្ជាក់លើកាលបរិច្ឆេទ, ទទួលតំកល់ទុកឯកសារ និងចេញអោយនូវសេចក្ដីដើម ឬសេចក្ដីចម្លង នៃលិខិត ឬ កិច្ចសន្យាទាំងឡាយនោះតាមមុខការ ។

គ- កិច្ចការនេះត្រូវពិនិត្យ, អានឱ្យអស់សេចក្ដី និង ចុះហត្ថលេខានៃគូភាគីនៅចំពោះមុខ ទើប មេធាវីសារការី ចុះហត្ថលេខា ប្រថាប់ត្រា ចារឹកនូវពេលនោះជាចុងក្រោយ ។

**មាត្រា ៤.**

មេធាវីសារការី ត្រូវតំកល់ប្រាក់ធានាចំនួន ៦00.000.000.00 ( ប្រាំមួយរយលានរៀល) នៅធានាគារជាតិនៃកម្ពុជា សំរាប់ទទួលខុសត្រូវក្នុងមុខការនេះ ។

**មាត្រា ៥:**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី, រដ្ឋមន្ត្រី, រដ្ឋលេខាធិការ និង ក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ២០០១

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**ចម្លងជូន:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតសាលាភូមិន្ទសាធារណៈ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១២៩៧ / ៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០១០៥ / ០១៩ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការបង្កើតរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៦៥៣ អនក្រ.តត ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៨ ខែ សីហា ឆ្នាំ២០០៨

# ស ម្រ េ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ត្រូវបានបង្កើត សាលាភូមិន្ទសារការី ស្ថិតនៅក្នុងរចនាសម្ព័ន្ធនៃការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

## ជំពូកទី ២
## តួនាទី និងភារកិច្ច

មាត្រា ២.-

សាលាភូមិន្ទសារការី មានតួនាទី និងភារកិច្ច ដូចតទៅ ៖

- ទទួលបន្ទុកការបណ្តុះបណ្តាលវិជ្ជាជីវៈដំបូង និងបណ្តុះបណ្តាលបន្ត សម្រាប់សារការី
- លើកយុទ្ធសាស្ត្រការងារ និងរៀបចំផែនការសកម្មភាពបណ្តុះបណ្តាលវិជ្ជាជីវៈសារការី
- រៀបចំតាក់តែងឯកសារគរុកោសល្យសម្រាប់បណ្តុះបណ្តាលវិជ្ជាជីវៈសារការី
- រៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូ សម្រាប់បណ្តុះបណ្តាលសារការី
- តាមដានត្រួតពិនិត្យការសិក្សា និង ការគោរពវិន័យរបស់សិស្សសារការី
- ត្រួតពិនិត្យការធ្វើកម្មសិក្សារបស់សិស្សសារការី
- ធ្វើរបាយការណ៍ប្រចាំឆ្នាំ លើស្ថានភាពសីលធម៌ និងគម្រោងការអភិវឌ្ឍន៍របស់សាលា ជូនប្រធានរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការមុននឹងបញ្ជូនទៅក្រុមប្រឹក្សាភិបាលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- ត្រួតពិនិត្យ និងចាត់ចែងលើការងារដឹកនាំរបស់ផ្នែកចំណុះ ។

ការបណ្តុះបណ្តាលសារការី ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ដោយការជិតស្និទ្ធជាមួយក្រសួងយុត្តិធម៌ ។

## ជំពូកទី ៣
## រចនាសម្ព័ន្ធ

**មាត្រា ៣.-**

សាលាភូមិន្ទសារការី មានផ្នែកចំណុះពីរគឺ ៖

- ផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈដំបូងសម្រាប់សារការី
- ផ្នែកបណ្តុះបណ្តាលបន្តសម្រាប់សារការី ។

ផ្នែកនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអាចមានអនុប្រធានមួយចំនួន តាមការចាំបាច់ ។
ប្រធានផ្នែកនីមួយៗ មានឋានៈស្មើប្រធាននាយកដ្ឋាន ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់សាលាភូមិន្ទសារការី ត្រូវកំណត់ក្នុងអនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

**មាត្រា ៤.-**

សាលាភូមិន្ទសារការី ដឹកនាំការងារបច្ចេកទេស ដោយនាយកមួយរូប ។

នាយកសាលាភូមិន្ទសារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

នាយកសាលាភូមិន្ទសារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវជ្រើសរើសក្នុងចំណោម ចៅក្រម ឬ កស្បរៈជនខ្មែរជាន់ខ្ពស់ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានសញ្ញាប័ត្រចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកនីតិសាស្ត្រ ឬផ្នែកគ្រប់គ្រង ឡើងទៅ ឬសញ្ញាប័ត្រវិជ្ជាជីវៈសារការី ។

នាយកសាលាភូមិន្ទសារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គឺជាសមាជិកអញ្ជើញរបស់ក្រុមប្រឹក្សាភិបាល នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

## ជំពូកទី ៤
## ការប្រឡងប្រជែងជ្រើសរើសសិស្សសារការី និង ការបណ្តុះបណ្តាល

**មាត្រា ៥.-**

ការប្រឡងប្រជែងជ្រើសរើសសិស្សសារការី ត្រូវកំណត់ដោយប្រកាសរបស់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវទទួលបន្ទុករៀបចំការប្រឡងប្រជែងជ្រើសរើសសិស្សសារការី ដោយមានការចូលរួមសហការពីក្រសួងយុត្តិធម៌ ។

មាត្រា ៦.-

បេក្ខជនដែលប្រឡងប្រជែងចូល សាលាភូមិន្ទសារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- បេក្ខជនទាំងពីរភេទត្រូវមានសញ្ជាតិខ្មែរ ។ ចំពោះបេក្ខជនជានិស្សិត ត្រូវមានអាយុមិនលើសពី ៣៥ឆ្នាំ រីឯបេក្ខជនជាមន្ត្រីរាជការ ត្រូវមានអាយុមិនលើសពី៤០ឆ្នាំ គិតមកត្រឹមថ្ងៃប្រឡង
- ត្រូវមានសញ្ញាប័ត្របរិញ្ញាបត្រនីតិសាស្ត្រ ឡើងទៅ
- ត្រូវមានលិខិតថ្កោលទោសបញ្ជាក់ថា មិនធ្លាប់ជាប់ទោសពីបទមជ្ឈិម ឬ បទឧក្រិដ្ឋ
- ត្រូវមានកាយសម្បទាគ្រប់គ្រាន់ ។

មាត្រា ៧.-

បេក្ខជនដែលបានប្រឡងប្រជែងជាប់ជាស្ថាពរនៅ សាលាភូមិន្ទសារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវតែងតាំងជាសិស្សសារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ។ ក្នុងរយៈពេលនៃការបណ្ដុះបណ្ដាល សិស្សសារការី ត្រូវទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែ តាមការកំណត់របស់រដ្ឋ ។

មាត្រា ៨.-

សិស្សសារការី ត្រូវទទួលការបណ្ដុះបណ្ដាលវិជ្ជាជីវៈដំបូងសម្រាប់សារការីឱ្យបានពេញលេញតាមកម្មវិធីសិក្សាដែលត្រូវកំណត់ដោយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

សិស្សសារការីដែលបានបញ្ចប់ការបណ្ដុះបណ្ដាលវិជ្ជាជីវៈដំបូងសម្រាប់សារការី ដោយជោគជ័យ ត្រូវទទួលបានវិញ្ញាបនប័ត្រវិជ្ជាជីវៈសារការី ដែលចេញដោយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

## ជំពូកទី ៥
## ធនធានហិរញ្ញវត្ថុ

មាត្រា ៩.-

សាលាភូមិន្ទសារការី មានថវិកា ដែលផ្គត់ផ្គង់ដោយរដ្ឋ សម្រាប់អនុវត្តការងាររបស់ខ្លួន ។
ថវិការបស់សាលាភូមិន្ទសារការី គឺស្ថិតនៅក្នុងកញ្ចប់ថវិការបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

មាត្រា ១០.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ១១.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រធានរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ខែ សីហា ឆ្នាំ ២០០៨

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

*កន្លែងទទួល:*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១១*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៥៦ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតមន្ទីរសារការី អេស ខេ ឆ៉ាយ នៃព្រះរាជាណាចក្រកម្ពុជា

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១**

ត្រូវបានបង្កើតមន្ទីរសារការីមួយ ដែលមានឈ្មោះថា **មន្ទីរសារការី អេស ខេ ឆ៉ាយ នៃព្រះរាជាណាចក្រកម្ពុជា** (S.K.) Notary Public of the Kingdom of Cambodia )។

**មាត្រា២ ..**

ត្រូវបានតែងតាំងជាសារការីនូវបុគ្គលដែលមានរាយនាមដូចខាងក្រោម ៖

១-លោកស្រី **អេង គីមស្រ៊ុំ** ដើម្បីបំពេញមុខងារជាប្រធាននៃមន្ទីរសារការី អេស ខេ វ៉ាយ

២-លោក **សែន សេងថៃ** ដើម្បីបំពេញមុខងារជាអនុប្រធាននៃមន្ទីរសារការី អេស ខេ វ៉ាយ

៣-លោក **អ៊ី ម៉ារ៉ះនា** ដើម្បីបំពេញមុខងារជាសមាជិកនៃមន្ទីរសារការី អេស ខេ វ៉ាយ។

ក្នុងករណីចាំបាច់ មន្ទីរសារការី អេស ខេ វ៉ាយ នៃព្រះរាជាណាចក្រកម្ពុជា អាចធ្វើការជ្រើសរើសសារការីដែលទទួលបានការតែងតាំងពីរាជរដ្ឋាភិបាល ឬបុគ្គលិកផ្សេងទៀត សម្រាប់ជួយបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបាន។

**មាត្រា៣ ..**

មន្ទីរសារការី អេស ខេ វ៉ាយ នៃព្រះរាជាណាចក្រកម្ពុជា មានទីស្នាក់ការនៅផ្ទះលេខ៣៧ អា ផ្លូវលេខ២៨៨ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ។

ក្នុងករណីមានការផ្លាស់ប្តូរទីស្នាក់ការ មន្ទីរសារការីត្រូវជូនដំណឹងមកក្រសួងយុត្តិធម៌។

**មាត្រា៤ ..**

មន្ទីរសារការី អេស ខេ វ៉ាយ នៃព្រះរាជាណាចក្រកម្ពុជា មានតួនាទី និងភារកិច្ចដូចតទៅ ៖

- ទទួលធ្វើកិច្ចសន្យា ឬលិខិតគតិយុត្តទាំងឡាយដែលរូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទត្រូវការ
- ផ្តល់ប្រឹក្សាយោបល់ចំពោះកិច្ចការពាណិជ្ជកម្ម វិនិយោគ កិច្ចការគ្រួសារ និងការគ្រប់គ្រងចាត់ចែងទ្រព្យសម្បត្តិ
- ផ្តល់ការបញ្ជាក់សុពលភាពចំពោះការបង្កើត ឬកែប្រែលក្ខន្តិកៈក្រុមហ៊ុន និងនីតិបុគ្គលគ្រប់ប្រភេទ
- ផ្តល់យថាភូតភាពដល់លិខិតគតិយុត្ត ឬកិច្ចសន្យា ឬឯកសារបកប្រែទាំងឡាយ តាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- ស្នើសុំឱ្យស្ថាប័នអនុវត្តធ្វើការអនុវត្តដោយបង្ខំនូវលិខិតគតិយុត្ត ឬកិច្ចសន្យាដែលទទួលបានយថាភូតភាពពីសារការី
- ទទួលបញ្ជាក់ការចម្លងត្រឹមត្រូវតាមច្បាប់ដើមនូវរាល់លិខិតគតិយុត្ត ឬកិច្ចសន្យានានាតាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- បញ្ជាក់ជានាហត្ថលេខា និងកាលបរិច្ឆេទនៃលិខិតគតិយុត្ត ឬកិច្ចសន្យានានា
- ធ្វើសំណើចុះបញ្ជី ឬចុះលេខាធិការទៅស្ថាប័នមានសមត្ថកិច្ច
- ទទួលតម្កល់ និងរក្សាទុកច្បាប់ដើមនៃកិច្ចសន្យា លិខិតឯកគោភាគីផ្សេងៗ មតកសាសន៍ និងលិខិតស្នាមគ្រប់ប្រភេទ
- ចេញច្បាប់ចម្លងនៃលិខិតយថាភូត
- និងទទួលធ្វើកិច្ចការផ្សេងៗទៀត ដែលអនុញ្ញាតដោយច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៥.-**

នៅពេលចាប់ផ្តើមប្រតិបត្តិការសកម្មភាពរបស់ខ្លួន មន្ទីរសាកោរី អេស ខេ វ៉ាយ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវតម្កល់ប្រាក់ចំនួន ៦០០.០០០.០០០ (ប្រាំមួយរយលាន) រៀល នៅធនាគារជាតិនៃកម្ពុជា សម្រាប់ធានាការទទួលខុសត្រូវក្នុងការបំពេញមុខងាររបស់ខ្លួន។

ក្នុងករណីដែលច្បាប់តម្រូវឱ្យមានការរំលាយមន្ទីរសាកោរី អេស ខេ វ៉ាយ នៃព្រះរាជាណាចក្រកម្ពុជា ប្រាក់តម្កល់ខាងលើនេះ ត្រូវបង្វិលជូនស្ថាបនិក និងសហកាតាដែលមានសិទ្ធិក្នុងការទទួល បន្ទាប់ពីបានកាត់កងទូទាត់បំណុល និងកាតព្វកិច្ចទាំងអស់ ដោយរាប់បញ្ចូលទាំងប្រាក់សោហ៊ុយនានា ដែលចាំបាច់សម្រាប់ធានានិរន្តរភាពនៃការការពារផលប្រយោជន៍របស់អតិថិជនខ្លួន អនុលោមតាមបែបបទ និងនីតិវិធីជាធរមាន។

ទំនាក់ទំនងគតិយុត្តរវាងស្ថាបនិក និងសហកាតា ត្រូវកំណត់ដោយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ដែលត្រូវអនុម័តដោយមន្ទីរសាកោរី អេស ខេ វ៉ាយ នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ មន្ទីរសាកោរី អេស ខេ វ៉ាយ នៃព្រះរាជាណាចក្រកម្ពុជា និងសាមីខ្លួនដូចចែងក្នុងមាត្រា ២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមករា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៧
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា　　　　ជាតិ　សាសនា　ព្រះមហាក្សត្រ

លេខៈ...៤៧...អនក្រ.បក

## អនុក្រឹត្យ
## ស្ដីពី
## ការបង្កើតមន្ទីរសារការី អង្គរ នៃព្រះរាជាណាចក្រកម្ពុជា

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១ ..**

ត្រូវបានបង្កើតមន្ទីរសារការីមួយ ដែលមានឈ្មោះថា **មន្ទីរសារការី អង្គរ នៃព្រះរាជាណាចក្រកម្ពុជា** (**ANGKOR Notary Public of the Kingdom of Cambodia**) សរសេរកាត់ជាភាសាអង់គ្លេស "A.N.C."។

**មាត្រា២.-**

ត្រូវបានតែងតាំងជាសារការីនូវបុគ្គលដែលមានរាយនាមដូចខាងក្រោម៖

| | | |
|---|---|---|
| ១-លោក | **សាំង ខណ្ឌៈ** | ដើម្បីបំពេញមុខងារជាប្រធាននៃមន្ទីរសារការីអង្គរ |
| ២-លោក | **ប៉ា ចន្ទគា** | ដើម្បីបំពេញមុខងារជាអនុប្រធាននៃមន្ទីរសារការីអង្គរ |
| ៣-លោក | **រិតិច សុវត្ថិសែន** | ដើម្បីបំពេញមុខងារជាសមាជិកនៃមន្ទីរសារការីអង្គរ |
| ៤-លោក | **សេង សុខឃីម** | ដើម្បីបំពេញមុខងារជាសមាជិកនៃមន្ទីរសារការីអង្គរ |
| ៥-លោក | **ជា ហុងវី** | ដើម្បីបំពេញមុខងារជាសមាជិកនៃមន្ទីរសារការីអង្គរ |
| ៦-លោក | **ហ៊ី ផុនា** | ដើម្បីបំពេញមុខងារជាសមាជិកនៃមន្ទីរសារការីអង្គរ។ |

ក្នុងករណីចាំបាច់ មន្ទីរសារការី អង្គរ នៃព្រះរាជាណាចក្រកម្ពុជា អាចធ្វើការជ្រើសរើសសារការីដែលទទួលបានការតែងតាំងពីរាជរដ្ឋាភិបាល ឬបុគ្គលិកផ្សេងទៀត សម្រាប់ជួយបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបាន។

**មាត្រា៣.-**

មន្ទីរសារការី អង្គរ នៃព្រះរាជាណាចក្រកម្ពុជា មានទីស្នាក់ការស្ថិតនៅអគារលេខ ១០បេ២ ផ្លូវលេខ ២១១ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

ក្នុងករណីមានការផ្លាស់ប្តូរទីស្នាក់ការ មន្ទីរសារការីត្រូវជូនដំណឹងមកក្រសួងយុត្តិធម៌។

**មាត្រា៤.-**

មន្ទីរសារការី អង្គរ នៃព្រះរាជាណាចក្រកម្ពុជា មានតួនាទី និងភារកិច្ចដូចតទៅ ៖

- ទទួលធ្វើកិច្ចសន្យា ឬលិខិតគតិយុត្តទាំងឡាយដែលរូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទត្រូវការ
- ផ្តល់ប្រឹក្សាយោបល់ចំពោះកិច្ចការពាណិជ្ជកម្ម វិនិយោគ កិច្ចការគ្រួសារ និងការគ្រប់គ្រងចាត់ចែងទ្រព្យសម្បត្តិ
- ផ្តល់ការបញ្ជាក់សុពលភាពចំពោះការបង្កើត ឬកែប្រែលក្ខន្តិកៈក្រុមហ៊ុន និងនីតិបុគ្គលគ្រប់ប្រភេទ
- ផ្តល់យថាភូតភាពដល់លិខិតគតិយុត្ត ឬកិច្ចសន្យា ឬឯកសារបកប្រែទាំងឡាយ តាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- ស្នើសុំឱ្យស្ថាប័នអនុវត្តធ្វើការអនុវត្តដោយបង្ខំនូវលិខិតគតិយុត្ត ឬកិច្ចសន្យាដែលទទួលបានយថាភូតភាពពីសារការី
- ទទួលបញ្ជាក់ការចម្លងត្រឹមត្រូវតាមច្បាប់ដើមនូវរាល់លិខិតគតិយុត្ត ឬកិច្ចសន្យានានាតាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- បញ្ជាក់ជានាហត្ថលេខា និងកាលបរិច្ឆេទនៃលិខិតគតិយុត្ត ឬកិច្ចសន្យានានា
- ធ្វើសំណើចុះបញ្ជី ឬចុះលេខាចារឹកទៅស្ថាប័នមានសមត្ថកិច្ច
- ទទួលតម្កល់ និងរក្សាទុកច្បាប់ដើមនៃកិច្ចសន្យា លិខិតឯកជនតោកាគីផ្សេងៗ មតកសាសន៍ និងលិខិតស្នាមគ្រប់ប្រភេទ

- ចេញច្បាប់ចម្លងនៃលិខិតយថាភូត
- និងទទួលធ្វើកិច្ចការផ្សេងៗទៀត ដែលអនុញ្ញាតដោយច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៥ ..**

នៅពេលចាប់ផ្តើមប្រតិបត្តិការសកម្មភាពរបស់ខ្លួន មន្ទីរសារការី អង្គរ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវតម្កល់ប្រាក់ចំនួន ៦០០.០០០.០០០ (ប្រាំមួយរយលាន) រៀល នៅធនាគារជាតិនៃកម្ពុជា សម្រាប់ធានាការទទួលខុសត្រូវក្នុងការបំពេញមុខងាររបស់ខ្លួន។

ក្នុងករណីដែលច្បាប់តម្រូវឱ្យមានការរំលាយមន្ទីរសារការី អង្គរ នៃព្រះរាជាណាចក្រកម្ពុជា ប្រាក់តម្កល់ខាងលើនេះត្រូវបង្វិលជូនស្ថាបនិក និងសហភាគាដែលមានសិទ្ធិក្នុងការទទួល បន្ទាប់ពីបានកាត់កងទូទាត់បំណុល និងកាតព្វកិច្ចទាំងអស់ ដោយរាប់បញ្ចូលទាំងប្រាក់សោហ៊ុយនានា ដែលចាំបាច់សម្រាប់ធានានិរន្តរភាពនៃការការពារផលប្រយោជន៍របស់អតិថិជនខ្លួន អនុលោមតាមបែបបទ និងនីតិវិធីជាធរមាន។

ទំនាក់ទំនងគតិយុត្តរវាងស្ថាបនិក និងសហភាគា ត្រូវកំណត់ដោយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ដែលត្រូវអនុម័តដោយមន្ទីរសារការី អង្គរ នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៦ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៧ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ មន្ទីរសារការី អង្គរ នៃព្រះរាជាណាចក្រកម្ពុជា និងសាមីខ្លួនដូចចែងក្នុងមាត្រា២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមីនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៧
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧០៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតមន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១ .-**

ត្រូវបានបង្កើតមន្ទីរសារការីមួយ ដែលមានឈ្មោះថា **មន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា** (MEKONG Notary Public of the Kingdom of Cambodia) សរសេរកាត់ជាភាសាខ្មែរ "ម.ស.ម." និងសរសេរកាត់ជាភាសាអង់គ្លេស "M.N.P."។

**មាត្រា២ ..**

ត្រូវបានតែងតាំងជាសារការីនូវបុគ្គលដែលមានរាយនាមដូចខាងក្រោម ៖

១-លោកស្រី **ចាន់ ស្រីពៅ** ដើម្បីបំពេញមុខងារជាប្រធាននៃមន្ទីរសារការីមេគង្គ

២-លោក **សៅ ធឿន** ដើម្បីបំពេញមុខងារជាអនុប្រធាននៃមន្ទីរសារការីមេគង្គ

៣-លោក **ប៉ាង់ ចាសនា** ដើម្បីបំពេញមុខងារជាសមាជិកនៃមន្ទីរសារការីមេគង្គ

៤-លោក **ផង់ និមិត្រ** ដើម្បីបំពេញមុខងារជាសមាជិកនៃមន្ទីរសារការីមេគង្គ។

ក្នុងករណីចាំបាច់ មន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា អាចធ្វើការជ្រើសរើសសារការី ដែលទទួលបានការតែងតាំងពីរាជរដ្ឋាភិបាល ឬបុគ្គលិកផ្សេងទៀត សម្រាប់ជួយបំពេញតួនាទី និងភារកិច្ច របស់ខ្លួនបាន។

**មាត្រា៣ ..**

មន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា មានទីស្នាក់ការនៅផ្ទះលេខ ២២ ផ្លូវលេខ ២៨១ ភូមិទី១៨ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

ក្នុងករណីមានការផ្លាស់ប្តូរទីស្នាក់ការ មន្ទីរសារការីត្រូវជូនដំណឹងមកក្រសួងយុត្តិធម៌។

**មាត្រា៤ ..**

មន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា មានតួនាទី និងភារកិច្ចដូចតទៅ ៖

- ទទួលធ្វើកិច្ចសន្យា ឬលិខិតគតិយុត្តទាំងឡាយដែលរូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទត្រូវការ
- ផ្តល់ប្រឹក្សាយោបល់ចំពោះកិច្ចការពាណិជ្ជកម្ម វិនិយោគ កិច្ចការគ្រួសារ និងការគ្រប់គ្រងចាត់ចែងទ្រព្យសម្បត្តិ
- ផ្តល់ការបញ្ជាក់សុពលភាពចំពោះការបង្កើត ឬកែប្រែលក្ខន្តិកៈក្រុមហ៊ុន និងនីតិបុគ្គលគ្រប់ប្រភេទ
- ផ្តល់យថាភូតភាពដល់លិខិតគតិយុត្ត ឬកិច្ចសន្យា ឬឯកសារបកប្រែទាំងឡាយ តាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- ស្នើសុំឱ្យស្ថាប័នអនុវត្តធ្វើការអនុវត្តដោយបង្ខំនូវលិខិតគតិយុត្ត ឬកិច្ចសន្យាដែលទទួលបានយថាភូតភាពពីសារការី
- ទទួលបញ្ជាក់ការចម្លងត្រឹមត្រូវតាមច្បាប់ដើមនូវរាល់លិខិតគតិយុត្ត ឬកិច្ចសន្យានានាតាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- បញ្ជាក់ជានាហត្ថលេខា និងកាលបរិច្ឆេទនៃលិខិតគតិយុត្ត ឬកិច្ចសន្យានានា
- ធ្វើសំណើចុះបញ្ជី ឬចុះលេខាធិការទៅស្ថាប័នមានសមត្ថកិច្ច
- ទទួលតម្កល់ និងរក្សាទុកច្បាប់ដើមនៃកិច្ចសន្យា លិខិតឯកជនគោកាតីផ្សេងៗ មតកសាសន៍ និងលិខិតស្នាមគ្រប់ប្រភេទ
- ចេញច្បាប់ចម្លងនៃលិខិតយថាភូត
- និងទទួលធ្វើកិច្ចការផ្សេងៗទៀត ដែលអនុញ្ញាតដោយច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៥ ..**

នៅពេលចាប់ផ្តើមប្រតិបត្តិការសកម្មភាពរបស់ខ្លួន មន្ទីរសោភារីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវតម្កល់ប្រាក់ចំនួន ៦០០.០០០.០០០ (ប្រាំមួយរយលាន) រៀល នៅធនាគារជាតិនៃកម្ពុជា សម្រាប់ធានាការទទួលខុសត្រូវក្នុងការបំពេញមុខងាររបស់ខ្លួន។

ក្នុងករណីដែលច្បាប់តម្រូវឱ្យមានការរំលាយមន្ទីរសោភារីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា ប្រាក់តម្កល់ខាងលើនេះត្រូវបង្វិលជូនស្ថាបនិក និងសហភាគីដែលមានសិទ្ធិក្នុងការទទួល បន្ទាប់ពីបានកាត់កងទូទាត់បំណុល និងកាតព្វកិច្ចទាំងអស់ ដោយរាប់បញ្ចូលទាំងប្រាក់សោហ៊ុយនានា ដែលចាំបាច់សម្រាប់ធានានិរន្តរភាពនៃការការពារផលប្រយោជន៍របស់អតិថិជនខ្លួន អនុលោមតាមបែបបទ និងនីតិវិធីជាធរមាន។

ទំនាក់ទំនងគតិយុត្តរវាងស្ថាបនិក និងសហភាគី ត្រូវកំណត់ដោយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ដែលត្រូវអនុម័តដោយ មន្ទីរសោភារីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៦ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៧ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ មន្ទីរសោភារីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា និងសាមីខ្លួនដូចចែងក្នុងមាត្រា២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៦

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:១៣៧៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតមន្ទីរសារការីភ្នំពេញ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

### សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើតមន្ទីរសារការីមួយ ដែលមានឈ្មោះថា **មន្ទីរសារការីភ្នំពេញ (Phnom Penh Notary Public)** នៃព្រះរាជាណាចក្រកម្ពុជា សរសេរកាត់ជាភាសាខ្មែរ "ម.ស.ភ.ព." និងសរសេរកាត់ជាភាសាអង់គ្លេស "P.P.N.P."។

## មាត្រា២ ._

ត្រូវបានតែងតាំងជាសារការីនូវបុគ្គលដែលមានរាយនាមដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-លោក | ហោខ | ឆាយ | ដើម្បីបំពេញមុខងារជាសហប្រធាននៃមន្ទីរសារការីភ្នំពេញ |
| ២-លោក | ស៊ិន | តុលា | ដើម្បីបំពេញមុខងារជាសហប្រធាននៃមន្ទីរសារការីភ្នំពេញ |
| ៣-លោក | ភាន់ | សុខុមម៉ូលីន | ដើម្បីបំពេញមុខងារជាអនុប្រធាននៃមន្ទីរសារការីភ្នំពេញ |
| ៤-លោក | ម៉ុក | ច័ន្ទសុធា | ដើម្បីបំពេញមុខងារជាអនុប្រធាននៃមន្ទីរសារការីភ្នំពេញ |
| ៥-លោកស្រី | មិនស៊ុំ | សូលីដា | ដើម្បីបំពេញមុខងារក្នុងមន្ទីរសារការីភ្នំពេញ |
| ៦-លោក | ស៊ិន | ដានី | ដើម្បីបំពេញមុខងារក្នុងមន្ទីរសារការីភ្នំពេញ |
| ៧-លោកស្រី | តាន់ | ទេពីភាណ្ឌរិទ្ធិភា | ដើម្បីបំពេញមុខងារក្នុងមន្ទីរសារការីភ្នំពេញ |
| ៨-លោក | ម៉ៃល | សក្តិអភ្លី | ដើម្បីបំពេញមុខងារក្នុងមន្ទីរសារការីភ្នំពេញ។ |

ក្នុងករណីចាំបាច់ មន្ទីរសារការីភ្នំពេញ អាចធ្វើការជ្រើសរើសសារការីដែលទទួលបានការតែងតាំងពីរាជរដ្ឋាភិបាល ឬបុគ្គលិកផ្សេងទៀត សម្រាប់ជួយបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបាន។

## មាត្រា៣ ._

មន្ទីរសារការីភ្នំពេញ មានទីស្នាក់ការនៅអគារកាណាឌីយ៉ា លេខ៣១៥ ផ្លូវព្រះអង្គឌួង (ផ្លូវលេខ ១១០) កែងមហាវិថីព្រះមុនីវង្ស (ផ្លូវលេខ៩៣) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

ក្នុងករណីមានការផ្លាស់ប្តូរទីស្នាក់ការ មន្ទីរសារការីត្រូវជូនដំណឹងមកក្រសួងយុត្តិធម៌។

## មាត្រា៤ ._

មន្ទីរសារការីភ្នំពេញ មានតួនាទី និងភារកិច្ចដូចតទៅ ៖

- ទទួលធ្វើកិច្ចសន្យា ឬលិខិតគតិយុត្តទាំងឡាយដែលរូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទត្រូវការ
- ផ្តល់ប្រឹក្សាយោបល់ចំពោះកិច្ចការពាណិជ្ជកម្ម វិនិយោគ កិច្ចការគ្រួសារ និងការគ្រប់គ្រងចាត់ចែងទ្រព្យសម្បត្តិ
- ផ្តល់ការបញ្ជាក់សុពលភាពចំពោះការបង្កើត ឬកែប្រែលក្ខន្តិកៈក្រុមហ៊ុន និងនីតិបុគ្គលគ្រប់ប្រភេទ
- ផ្តល់យថាភូតភាពដល់លិខិតគតិយុត្ត ឬកិច្ចសន្យា ឬឯកសារបកប្រែទាំងឡាយ តាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- ស្នើសុំឱ្យស្ថាប័នអនុវត្តធ្វើការអនុវត្តដោយបង្ខំនូវលិខិតគតិយុត្ត ឬកិច្ចសន្យាដែលទទួលបានយថាភូតភាពពីសារការី
- ទទួលបញ្ជាក់ការចម្លងត្រឹមត្រូវតាមច្បាប់ដើមនូវរាល់លិខិតគតិយុត្ត ឬកិច្ចសន្យានានាតាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- បញ្ជាក់ជានាហត្ថលេខា និងកាលបរិច្ឆេទនៃលិខិតគតិយុត្ត ឬកិច្ចសន្យានានា
- ធ្វើសំណើចុះបញ្ជី ឬចុះលេខាចារឹកទៅស្ថាប័នមានសមត្ថកិច្ច
- ទទួលតម្កល់ និងរក្សាទុកច្បាប់ដើមនៃកិច្ចសន្យា លិខិតឯកតោភាគីផ្សេងៗ មតកសាសន៍ និងលិខិតស្នាមគ្រប់ប្រភេទ
- ចេញច្បាប់ចម្លងនៃលិខិតយថាភូត
- និងទទួលធ្វើកិច្ចការផ្សេងៗទៀត ដែលអនុញ្ញាតដោយច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន។



www.pheakdeylaw.com

**មាត្រា៥ ..**

នៅពេលចាប់ផ្ដើមប្រតិបត្តិការសកម្មភាពរបស់ខ្លួន មន្ទីរសារការីភ្នំពេញ ត្រូវតម្កល់ប្រាក់ចំនួន ៦០០.០០០.០០០ (ប្រាំមួយរយលាន) រៀល នៅធនាគារជាតិនៃកម្ពុជា សម្រាប់ធានាការទទួលខុសត្រូវក្នុងការបំពេញមុខងាររបស់ខ្លួន។

ក្នុងករណីដែលច្បាប់តម្រូវឱ្យមានការរំលាយមន្ទីរសារការីភ្នំពេញ ប្រាក់តម្កល់ខាងលើនេះ ត្រូវបង្វិលជូនស្ថាបនិក និងសហកាតាដែលមានសិទ្ធិក្នុងការទទួល បន្ទាប់ពីបានកាត់កងទូទាត់បំណុល និងកាតព្វកិច្ចទាំងអស់ ដោយរាប់បញ្ចូលទាំងប្រាក់សោហ៊ុយនានា ដែលចាំបាច់សម្រាប់ធានានិរន្តរភាពនៃការការពារផលប្រយោជន៍របស់អតិថិជនខ្លួន អនុលោមតាមបែបបទ និងនីតិវិធីជាធរមាន។

ទំនាក់ទំនងគតិយុត្តរវាងស្ថាបនិក និងសហកាតា ត្រូវកំណត់ដោយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងដែលត្រូវអនុម័តដោយមន្ទីរសារការីភ្នំពេញ។

**មាត្រា៦ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៧ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ មន្ទីរសារការីភ្នំពេញ និងសាមីខ្លួនដូចចែងក្នុងមាត្រា ២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០១៥

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតមន្ទីរសារការី សុក ស៊ីផាន់ណា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើតមន្ទីរសារការីមួយ ដែលមានឈ្មោះថា **មន្ទីរសារការី សុក ស៊ីផាន់ណា** (SOK SIPHANA Notary Public) នៃព្រះរាជាណាចក្រកម្ពុជា។

ត្រូវបានតែងតាំង លោក សុក ស៊ីផាន់ណា ជាសារការី ដើម្បីដឹកនាំមន្ទីរសារការី សុក ស៊ីផាន់ណា នេះ។

ក្នុងករណីចាំបាច់ មន្ទីរសារការី សុក ស៊ីផាន់ណា អាចធ្វើការជ្រើសរើសសារការីដែលទទួលបានការតែងតាំងពីរាជរដ្ឋាភិបាល ឬបុគ្គលិកផ្សេងទៀតសម្រាប់ជួយបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបាន។

**មាត្រា ២.-**

មន្ទីរសារការី សុក ស៊ីផាន់ណា មានទីស្នាក់ការនៅអគារលេខ ៤៥អ៊ី១ ផ្លូវលេខ ៣៥៥ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

ក្នុងករណីមានការផ្លាស់ប្តូរទីស្នាក់ការ មន្ទីរសារការីត្រូវជូនដំណឹងមកក្រសួងយុត្តិធម៌។

**មាត្រា ៣.-**

មន្ទីរសារការី សុក ស៊ីផាន់ណា មានតួនាទី និងភារកិច្ចដូចតទៅ ៖

- ទទួលធ្វើកិច្ចសន្យា ឬលិខិតគតិយុត្តទាំងឡាយដែលរូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទត្រូវការ
- ផ្តល់ប្រឹក្សាយោបល់ចំពោះកិច្ចការពាណិជ្ជកម្ម វិនិយោគ កិច្ចការគ្រួសារ និងការគ្រប់គ្រងចាត់ចែងទ្រព្យសម្បត្តិ
- ផ្តល់ការបញ្ជាក់សុពលភាពចំពោះការបង្កើត ឬកែប្រែលក្ខន្តិកៈក្រុមហ៊ុន និងនីតិបុគ្គលគ្រប់ប្រភេទ
- ផ្តល់យថាភូតភាពដល់លិខិតគតិយុត្ត ឬកិច្ចសន្យា ឬឯកសារបកប្រែទាំងឡាយ តាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- ស្នើសុំឱ្យស្ថាប័នអនុវត្តធ្វើការអនុវត្តដោយបង្ខំនូវលិខិតគតិយុត្ត ឬកិច្ចសន្យាដែលទទួលបានយថាភូតភាពពីសារការី
- ទទួលបញ្ជាក់ការចម្លងត្រឹមត្រូវតាមច្បាប់ដើមនូវរាល់លិខិតគតិយុត្ត ឬកិច្ចសន្យានានាតាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- បញ្ជាក់ជានាហត្ថលេខា និងកាលបរិច្ឆេទនៃលិខិតគតិយុត្ត ឬកិច្ចសន្យានានា
- ធ្វើសំណើចុះបញ្ជី ឬចុះលេខាធិការទៅស្ថាប័នមានសមត្ថកិច្ច
- ទទួលតម្កល់ និងរក្សាទុកច្បាប់ដើមនៃកិច្ចសន្យា លិខិតឯកត្តោភាគីផ្សេងៗ មតកសាសន៍ និងលិខិតស្នាមគ្រប់ប្រភេទ
- ចេញច្បាប់ចម្លងនៃលិខិតយថាភូត
- និងទទួលធ្វើកិច្ចការផ្សេងៗទៀត ដែលអនុញ្ញាតដោយច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ៤.-**

នៅពេលចាប់ផ្តើមប្រតិបត្តិការសកម្មភាពរបស់ខ្លួន មន្ទីរសារការី សុក ស៊ីផាន់ណា ត្រូវតម្កល់ប្រាក់ចំនួន ២០០.០០០.០០០ (ប្រាំមួយរយលាន) រៀល នៅធនាគារជាតិនៃកម្ពុជា សម្រាប់ធានាការទទួលខុសត្រូវក្នុងការបំពេញមុខងាររបស់ខ្លួន។

ក្នុងករណីដែលច្បាប់តម្រូវឱ្យមានការរំលាយមន្ទីរសោភាគី សុក ស៊ីផាន់ណា ប្រាក់តម្កល់ខាងលើនេះ ត្រូវបង្វិលជូនស្ថាបនិក បន្ទាប់ពីបានកាត់កងទូទាត់បំណុល និងកាតព្វកិច្ចទាំងអស់ ដោយរាប់បញ្ចូលទាំងប្រាក់សោហ៊ុយនានា ដែលចាំបាច់សម្រាប់ធានានិរន្តរភាពនៃការការពារផលប្រយោជន៍របស់អតិថិជនខ្លួន អនុលោមតាមបែបបទ និងនីតិវិធីជាធរមាន។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ មន្ទីរសោភាគី សុក ស៊ីផាន់ណា និងសាមីខ្លួនដូចចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០១៥

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល ៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៦
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៣ អនក្រ.បក

## អនុក្រឹត្យ

ស្តីពី

## ការបង្កើតមន្ទីរសារការី នីតិនិរន្តរ៍

---

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

### សម្រេច

**មាត្រា ១ .-**

ត្រូវបានបង្កើតមន្ទីរសារការីមួយ ដែលមានឈ្មោះថា **មន្ទីរសារការី នីតិនិរន្តរ៍** (Nitel Niron Notary Public) នៃព្រះរាជាណាចក្រកម្ពុជា សរសេរកាត់ជាភាសាខ្មែរ « **ម.ស.ន.ន** » និងសរសេរកាត់ជាភាសាអង់គ្លេស « N&N Notary Public » ។

**មាត្រា ២ .-**

មន្ទីរសារការី នីតិនិវន្តន៍ នៃព្រះរាជាណាចក្រកម្ពុជា មានទីស្នាក់ការនៅផ្ទះលេខ ៩អា ផ្លូវ១៨៣ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

**មាត្រា ៣ .-**

មន្ទីរសារការី នីតិនិវន្តន៍ មានតួនាទី និងភារកិច្ចដូចតទៅ ៖

- តាក់តែងកិច្ចសន្យា កិច្ចព្រមព្រៀងនានា លិខិតស្នាមគតិយុត្តផ្សេងៗ និងធ្វើការប្រថាប់ត្រាបញ្ជាក់ពីហត្ថលេខា និងស្នាមមេដៃរបស់គូភាគី ដើម្បីបំពេញបន្ទាល់លក្ខណៈតាមផ្លូវច្បាប់
- ពិគ្រោះប្រឹក្សាយោបល់នូវចំណោទច្បាប់ទាំងឡាយដែលពាក់ព័ន្ធនឹងវិស័យគ្រួសារ ចលនវត្ថុ អចលនវត្ថុ ពាណិជ្ជកម្ម និងវិនិយោគ
- ធ្វើការបញ្ជាក់នូវភាពពិតប្រាកដនូវឯកសារថតចម្លងផ្សេងៗ
- ធ្វើការតាក់តែងនូវមតកសាសន៍ និងលិខិតយថាភូតទាំងឡាយ ត្រឹមត្រូវតាមទម្រង់នៃក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ព្រមទាំងក្រម ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា
- និងកិច្ចការផ្សេងៗទៀតដែលស្ថិតនៅក្នុងវិសាលភាពនៃការប្រកបវិជ្ជាជីវៈសារការី ស្របទៅតាមក្រម ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៤ .-**

នៅពេលចាប់ផ្តើមប្រតិបត្តិការសកម្មភាព មន្ទីរសារការី នីតិនិវន្តន៍ ត្រូវតម្កល់ប្រាក់ចំនួន ៦០០.០០០.០០០ (ប្រាំមួយរយលាន) រៀល នៅធនាគារជាតិនៃកម្ពុជា សម្រាប់ការធានាទទួលខុសត្រូវក្នុងការបំពេញមុខងាររបស់ខ្លួន។

ក្នុងករណីដែលច្បាប់តម្រូវឱ្យមានការរំលាយ មន្ទីរសារការី នីតិនិវន្តន៍ ប្រាក់តម្កល់ខាងលើនេះត្រូវបង្វិលជូនស្ថាបនិក និងសហភាគា ដែលមានសិទ្ធិស្របច្បាប់ក្នុងការទទួលយក បន្ទាប់ពីបានកាត់កងទូទាត់បំណុល និងកាតព្វកិច្ចទាំងអស់ ដោយរាប់បញ្ចូលទាំងសោហ៊ុយនានាដែលចាំបាច់សម្រាប់ធានានិរន្តរភាពនៃការការពារផលប្រយោជន៍របស់អតិថិជនខ្លួន អនុលោមតាមបែបបទ និងនីតិវិធីជាធរមាន។

ទំនាក់ទំនងគតិយុត្តិរវាងស្ថាបនិក និងសហភាគា ត្រូវកំណត់ដោយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងដែលត្រូវអនុម័តដោយសារការីដែលទទួលបានការតែងតាំងតាមអនុក្រឹត្យនេះ។

**មាត្រា ៥ .-**

ត្រូវបានតែងតាំងជាសារការី នូវបុគ្គលដែលមានរាយនាមដូចខាងក្រោម ៖

១. **លោក ស៊ុន សំណាង** ដើម្បីបំពេញមុខងារជាប្រធានមន្ទីរសារការី នីតិនិវន្តន៍
២. **លោកស្រី គួន លីនណា** ដើម្បីបំពេញមុខងារជាអនុប្រធានមន្ទីរសារការី នីតិនិវន្តន៍
៣. **លោក ផូ សុធាផល** ដើម្បីបំពេញមុខងារជាសមាជិកមន្ទីរសារការី នីតិនិវន្តន៍

ក្នុងករណីចាំបាច់ មន្ទីរសារការី នីតិនិវន្តន៍ អាចធ្វើការជ្រើសរើសសារការី ដែលទទួលបានការតែងតាំងពីរាជរដ្ឋាភិបាល ឬបុគ្គលិកផ្សេងទៀតសម្រាប់ជួយបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបាន។

www.clbs.asia


**មាត្រា ៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**អន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៣៧ អនក្រ.បក**

# អនុក្រឹត្យ

**ស្តីពី**

## ការបង្កើតមន្ទីរសារការី ខេមរា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបង្កើតមន្ទីរសារការីមួយ ដែលមានឈ្មោះថា **មន្ទីរសារការី ខេមរា** (KHEMARA Notary Public) នៃព្រះរាជាណាចក្រកម្ពុជា ។

www.clbs.asia



**មាត្រា ២ .-**

មន្ទីរសារការី ខេមរា មានទីស្នាក់ការនៅអគារលេខ ១៤២ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**មាត្រា ៣ .-**

មន្ទីរសារការី ខេមរា មានតួនាទី និងភារកិច្ចដូចតទៅ ៖

- ទទួលធ្វើកិច្ចសន្យា ឬលិខិតគតិយុត្តទាំងឡាយដែលរូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទត្រូវការ
- ផ្តល់ប្រឹក្សាយោបល់ចំពោះកិច្ចការពាណិជ្ជកម្ម វិនិយោគ កិច្ចការគ្រួសារ និងការគ្រប់គ្រងចាត់ចែងទ្រព្យសម្បត្តិ
- ផ្តល់ការបញ្ជាក់សុពលភាពចំពោះការបង្កើត ឬកែប្រែលក្ខន្តិកៈក្រុមហ៊ុន និងនីតិបុគ្គលគ្រប់ប្រភេទ
- ផ្តល់យថាភូតភាពដល់លិខិតគតិយុត្ត ឬកិច្ចសន្យា ឬឯកសារបកប្រែទាំងឡាយ តាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- ស្នើសុំឱ្យស្ថាប័នអនុវត្តធ្វើការអនុវត្តដោយបង្ខំនូវលិខិតគតិយុត្ត ឬកិច្ចសន្យាដែលទទួលបានយថាភូតភាពពីសារការី
- ទទួលបញ្ជាក់ការចម្លងត្រឹមត្រូវតាមច្បាប់ដើមនូវរាល់លិខិតគតិយុត្ត ឬកិច្ចសន្យានានាតាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- បញ្ជាក់ជានាហត្ថលេខា និងកាលបរិច្ឆេទនៃលិខិតគតិយុត្ត ឬកិច្ចសន្យានានា
- ធ្វើសំណើចុះបញ្ជី ឬលុះលេខាធិការទៅស្ថាប័នមានសមត្ថកិច្ច
- ទទួលតម្កល់ និងរក្សាទុកច្បាប់ដើមនៃកិច្ចសន្យា លិខិតឯកតោភាគីផ្សេងៗ មតកសាសន៍ និងលិខិតស្នាមគ្រប់ប្រភេទ
- ចេញច្បាប់ចម្លងនៃលិខិតយថាភូត និង
- ទទួលធ្វើកិច្ចការផ្សេងៗទៀតដែលអនុញ្ញាតដោយច្បាប់ និងបទប្បញ្ញត្តិគតិយុត្តជាធរមាន។

**មាត្រា ៤ .-**

នៅពេលចាប់ផ្តើមប្រតិបត្តិការសកម្មភាព មន្ទីរសារការី ខេមរា ត្រូវតម្កល់ប្រាក់ចំនួន ៦០០.០០០.០០០ (ប្រាំមួយរយលាន) រៀល នៅធនាគារជាតិនៃកម្ពុជា សម្រាប់ការធានាទទួលខុសត្រូវក្នុងការបំពេញមុខងាររបស់ខ្លួន។

ក្នុងករណីដែលច្បាប់តម្រូវឱ្យមានការរំលាយ មន្ទីរសារការី ខេមរា ប្រាក់តម្កល់ខាងលើនេះត្រូវបង្វិលជូនស្ថាបនិក និងសហកាតា ដែលមានសិទ្ធិស្របច្បាប់ក្នុងការទទួលយក បន្ទាប់ពីបានកាត់កងទូទាត់បំណុល និងកាតព្វកិច្ចទាំងអស់ ដោយរាប់បញ្ចូលទាំងសោហ៊ុយនានាដែលចាំបាច់សម្រាប់ធានានិរន្តរភាពនៃការការពារផលប្រយោជន៍របស់អតិថិជនខ្លួន អនុលោមតាមបែបបទ និងនីតិវិធីជាធរមាន។

ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា មន្ទីរសារការី ខេមរា អាចបង្កើតនូវយន្តការហិរញ្ញប្បទាន ឬយន្តការធានាផ្សេងទៀតដែលខ្លួនយល់ថាសមស្រប សម្រាប់បង្កើនទំនុកចិត្តរបស់ពលរដ្ឋ វិនិយោគិនជាតិ និងអន្តរជាតិ ចំពោះសេវារបស់ខ្លួន។

ទំនាក់ទំនងគតិយុត្តិរវាងស្ថាបនិក និងសហកាតា ត្រូវកំណត់ដោយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងដែលត្រូវអនុម័តដោយសារការីដែលទទួលបានការតែងតាំងតាមអនុក្រឹត្យនេះ។

**មាត្រា ៥ .-**

ត្រូវបានតែងតាំងជាសារការី នូវបុគ្គលដែលមានរាយនាមដូចខាងក្រោម ៖

១. **លោក ហួត ហាក់** ដើម្បីបំពេញមុខងារជាសហប្រធានមន្ទីរសារការី ខេមរា

២. **លោក ផូច សំអី** ដើម្បីបំពេញមុខងារជាសហប្រធានមន្ទីរសារការី ខេមរា

៣. **លោក សេង សត្យា** ដើម្បីបំពេញមុខងារជាសមាជិកមន្ទីរសារការី ខេមរា

ក្នុងករណីចាំបាច់ មន្ទីរសារការី ខេមរា អាចធ្វើការជ្រើសរើសសារការី ដែលទទួលបានការតែងតាំងពីរាជរដ្ឋាភិបាល ឬបុគ្គលិកផ្សេងទៀតសម្រាប់ជួយបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបាន។

**មាត្រា ៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧២១ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើតមន្ទីរសារការី សេដ្ឋាវិទូ នៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើតមន្ទីរសារការីមួយ ដែលមានឈ្មោះថា **មន្ទីរសារការី សេដ្ឋាវិទូ នៃព្រះរាជាណាចក្រកម្ពុជា** (SETHAVITOU Notary Public of the Kingdom of Cambodia)

សរសេរកាត់ជាភាសាខ្មែរ "ម.ស.ស" និងសរសេរកាត់ជាភាសាអង់គ្លេស "S.H Notary Public" ។

**មាត្រា ២.-**

មន្ទីរសារការី សេង្ហាវិទូ នៃព្រះរាជាណាចក្រកម្ពុជា មានទីស្នាក់ការនៅអគារលេខ ៧៣ ផ្លូវលេខ ១២៦ សង្កាត់ផ្សារថ្មីទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

**មាត្រា ៣.-**

មន្ទីរសារការី សេង្ហាវិទូ នៃព្រះរាជាណាចក្រកម្ពុជា មានតួនាទី និងភារកិច្ចដូចតទៅ ៖

- ទទួលធ្វើកិច្ចសន្យា ឬលិខិតគតិយុត្តទាំងឡាយដែលរូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទត្រូវការ
- ផ្តល់ប្រឹក្សាយោបល់ចំពោះកិច្ចការពាណិជ្ជកម្ម វិនិយោគ កិច្ចការគ្រួសារ និងការគ្រប់គ្រងចាត់ចែងទ្រព្យសម្បត្តិ
- ផ្តល់ការបញ្ជាក់សុពលភាពចំពោះការបង្កើត ឬកែប្រែលក្ខន្តិកៈក្រុមហ៊ុន និងនីតិបុគ្គលគ្រប់ប្រភេទ
- ផ្តល់យថាភូតភាពដល់លិខិតគតិយុត្ត ឬកិច្ចសន្យា ឬឯកសារបកប្រែទាំងឡាយ តាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- ស្នើសុំឱ្យស្ថាប័នអនុវត្តធ្វើការអនុវត្តដោយបង្ខំនូវលិខិតគតិយុត្ត ឬកិច្ចសន្យាដែលទទួលបានយថាភូតភាពពីសារការី
- ទទួលបញ្ជាក់ការចម្លងត្រឹមត្រូវតាមច្បាប់ដើមនូវរាល់លិខិតគតិយុត្ត ឬកិច្ចសន្យានានាតាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- បញ្ជាក់ជានាហត្ថលេខា និងកាលបរិច្ឆេទនៃលិខិតគតិយុត្ត ឬកិច្ចសន្យានានា
- ផ្ញើសំណើចុះបញ្ជី ឬចុះលេខាធិការទៅស្ថាប័នមានសមត្ថកិច្ច
- ទទួលតម្កល់ និងរក្សាទុកច្បាប់ដើមនៃកិច្ចសន្យា លិខិតឯកតោភាគីផ្សេងៗ មតកសាសន៍ និងលិខិតស្នាមគ្រប់ប្រភេទ
- ចេញច្បាប់ចម្លងនៃលិខិតយថាភូត
- និងទទួលធ្វើកិច្ចការផ្សេងៗទៀត ដែលអនុញ្ញាតដោយច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ៤.-**

នៅពេលចាប់ផ្តើមប្រតិបត្តិការសកម្មភាពរបស់ខ្លួន មន្ទីរសារការី សេដ្ឋាវិទូ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវតម្កល់ប្រាក់ចំនួន ៦០០.០០០.០០០ (ប្រាំមួយរយលាន) រៀល នៅធនាគារជាតិនៃកម្ពុជា សម្រាប់ធានាការទទួលខុសត្រូវក្នុងការបំពេញមុខងាររបស់ខ្លួន។

ក្នុងករណីដែលច្បាប់តម្រូវឱ្យមានការលោយមន្ទីរសារការី សេដ្ឋាវិទូ នៃព្រះរាជាណាចក្រកម្ពុជា ប្រាក់តម្កល់ខាងលើនេះ ត្រូវបង្វិលជូនស្ថាបនិក និងសហកាតា ដែលមានសិទ្ធិស្របច្បាប់ក្នុងការទទួលយក បន្ទាប់ពីបានកាត់កងទូទាត់បំណុល និងកាតព្វកិច្ចទាំងអស់ ដោយរាប់បញ្ចូលទាំងប្រាក់សោហ៊ុយនានាដែលចាំបាច់សម្រាប់ធានានិរន្តរភាពនៃការការពារផលប្រយោជន៍របស់អតិថិជនខ្លួន អនុលោមតាមបែបបទ និងនីតិវិធីជាធរមាន។

ដោយអនុលោមតាមច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា មន្ទីរសារការី សេដ្ឋាវិទូ នៃព្រះរាជាណាចក្រកម្ពុជា អាចបង្កើតបន្ថែមនូវយន្តការហិរញ្ញប្បទាន ឬយន្តការធានាផ្សេងទៀតដែលខ្លួនយល់ថាសមស្របសម្រាប់បង្កើនទំនុកចិត្តរបស់ពលរដ្ឋ វិនិយោគិនជាតិ និងអន្តរជាតិ ចំពោះសេវារបស់ខ្លួន។

ទំនាក់ទំនងគតិយុត្តរវាងស្ថាបនិក និងសហកាតា ត្រូវកំណត់ដោយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ដែលត្រូវអនុម័តដោយសារការីដែលទទួលបានការតែងតាំងតាមមាត្រា ៥ នៃអនុក្រឹត្យនេះ។

**មាត្រា ៥.-**

ត្រូវបានតែងតាំងជាសារការី នូវបុគ្គលដែលមានរាយនាមដូចខាងក្រោម ៖

១-លោក **នាក់ សើរីរ៉ែន** ដើម្បីបំពេញមុខងារជាប្រធានមន្ទីរសារការី សេដ្ឋាវិទូ

២-លោក **ដាច អានសាន** ដើម្បីបំពេញមុខងារជាអនុប្រធានមន្ទីរសារការី សេដ្ឋាវិទូ

៣-លោក **មួន សារៈមុនី** ដើម្បីបំពេញមុខងារជាអនុប្រធានមន្ទីរសារការី សេដ្ឋាវិទូ

៤-លោក **ទី ហ្សានិត** ដើម្បីបំពេញមុខងារជាសមាជិកមន្ទីរសារការី សេដ្ឋាវិទូ។

ក្នុងករណីចាំបាច់ មន្ទីរសារការី សេដ្ឋាវិទូ នៃព្រះរាជាណាចក្រកម្ពុជា អាចធ្វើការជ្រើសរើសសារការីដែលទទួលបានការតែងតាំងពីរាជរដ្ឋាភិបាល ឬបុគ្គលិកផ្សេងទៀតសម្រាប់ជួយបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបាន។

**មាត្រា ៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី  រដ្ឋមន្ត្រីក្រសួងយុត្តិធម៌  រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ មន្ទីរសារការី សេដ្ឋាកិច្ច នៃព្រះរាជាណាចក្រកម្ពុជា និងសាមីខ្លួនដូចចែងក្នុងមាត្រា ៥ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៧
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧២៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតមន្ទីរសារការី ទាណិជ្ជ និងសហការី នៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើតមន្ទីរសារការីមួយ ដែលមានឈ្មោះថា មន្ទីរសារការី ទាណិជ្ជនិងសហការី នៃព្រះរាជាណាចក្រកម្ពុជា (Vinick and Associates Notary Public of the Kingdom of Cambodia) សរសេរកាត់ជាភាសាខ្មែរ “ម.ស.ទ.” និងសរសេរកាត់ជាភាសាអង់គ្លេស “V&A Notary”។

www.clbs.asia


មាត្រា ២.-

មន្ទីរសារការី វាណិជ្ជ និងសហភាគា នៃព្រះរាជាណាចក្រកម្ពុជាមានទីស្នាក់ការនៅផ្ទះលេខ ០៣ ផ្លូវ ២៨៦ សង្កាត់ទួលស្វាយព្រៃទី ២ ខណ្ឌចំការមន រាជធានីភ្នំពេញ។

មាត្រា ៣.-

មន្ទីរសារការី វាណិជ្ជ និងសហភាគា នៃព្រះរាជាណាចក្រកម្ពុជា មានតួនាទី និងភារកិច្ចដូចតទៅ÷

- ទទួលធ្វើកិច្ចសន្យា ឬលិខិតគតិយុត្តទាំងឡាយដែលរូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទត្រូវការ
- ផ្តល់ប្រឹក្សាយោបល់ចំពោះកិច្ចការពាណិជ្ជកម្ម វិនិយោគ កិច្ចការគ្រួសារ និងការគ្រប់គ្រងចាត់ចែងទ្រព្យសម្បត្តិ
- ផ្តល់ការបញ្ជាក់សុពលភាពចំពោះការបង្កើត ឬកែប្រែលក្ខន្តិកៈក្រុមហ៊ុន និងនីតិបុគ្គលគ្រប់ប្រភេទ
- ផ្តល់យថាភូតភាពដល់លិខិតគតិយុត្ត ឬកិច្ចសន្យា ឬឯកសារបកប្រែទាំងឡាយ តាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- ស្នើសុំឱ្យស្ថាប័នអនុវត្តធ្វើការអនុវត្តដោយបង្ខំនូវលិខិតគតិយុត្ត ឬកិច្ចសន្យាដែលទទួលបានយថាភូតភាពពីសារការី
- ទទួលបញ្ជាក់ការចម្លងត្រឹមត្រូវតាមច្បាប់ដើមនូវរាល់លិខិតគតិយុត្ត ឬកិច្ចសន្យានានាតាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- បញ្ជាក់ធានាហត្ថលេខា និងកាលបរិច្ឆេទនៃលិខិតគតិយុត្ត ឬកិច្ចសន្យានានា
- ធ្វើសំណើចុះបញ្ជី ឬចុះលេខាធារីកទៅស្ថាប័នមានសមត្ថកិច្ច
- ទទួលតម្កល់ និងរក្សាទុកច្បាប់ដើមនៃកិច្ចសន្យា លិខិតឯកតោភាគីផ្សេងៗមតកសាសន៍ និងលិខិតស្នាមគ្រប់ប្រភេទ
- ចេញច្បាប់ចម្លងនៃលិខិតយថាភូត
- និងទទួលធ្វើកិច្ចការផ្សេងៗទៀតដែលអនុញ្ញាតដោយច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា ៤.-

នៅពេលចាប់ផ្តើមប្រតិបត្តិការសកម្មភាពរបស់ខ្លួន មន្ទីរសារការី វាណិជ្ជ និងសហភាគា នៃព្រះរាជាណាចក្រកម្ពុជាត្រូវតម្កល់ប្រាក់ចំនួន ៦០០.០០០.០០០ (ប្រាំមួយរយលាន) រៀល នៅធនាគារជាតិនៃកម្ពុជា សម្រាប់ធានាការទទួលខុសត្រូវក្នុងការបំពេញមុខងាររបស់ខ្លួន។

ក្នុងករណីដែលច្បាប់តម្រូវឱ្យមានការរំលាយមន្ទីរសារការី វាណិជ្ជ និងសហភាគា ប្រាក់តម្កល់ខាងលើនេះ ត្រូវបង្វិលជូនស្ថាបនិក និងសហភាគា ដែលមានសិទ្ធិស្របច្បាប់ក្នុងការទទួលយក បន្ទាប់ពីបានកាត់កងទូទាត់បំណុល និងកាតព្វកិច្ចទាំងអស់ ដោយរាប់បញ្ចូលទាំងប្រាក់សោហ៊ុយនានាដែលចាំបាច់សម្រាប់ធានានិរន្តរភាពនៃការការពារផលប្រយោជន៍របស់អតិថិជនខ្លួន អនុលោមតាមបែបបទ និងនីតិវិធីជាធរមាន។

ដោយអនុលោមតាមច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា មន្ទីរសារការី វាណិជ្ជ និងសហភាគា នៃព្រះរាជាណាចក្រកម្ពុជា អាចបង្កើតបន្ថែមនូវយន្តការហិរញ្ញប្បទាន ឬយន្តការធានាផ្សេងទៀតដែលខ្លួនយល់ថា សមស្របសម្រាប់បង្កើនទំនុកចិត្តរបស់ពលរដ្ឋ វិនិយោគិនជាតិ និងអន្តរជាតិ ចំពោះសេវារបស់ខ្លួន។

ទំនាក់ទំនងគតិយុត្តរវាងស្ថាបនិក និងសហភាគា ត្រូវកំណត់ដោយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ដែលត្រូវអនុម័តដោយសារការីដែលទទួលបានការតែងតាំងតាមមាត្រា ៥ នៃអនុក្រឹត្យនេះ។

**មាត្រា ៥.-**

ត្រូវបានតែងតាំងជាសារការីនូវបុគ្គលដែលមានរាយនាមដូចខាងក្រោម៖

១. ឯកឧត្តម **ឈន ព្រាលីខ** ដើម្បីបំពេញមុខងារជាប្រធានមន្ទីរសារការី វាណិជ្ជ និងសហភាគា

២. ឯកឧត្តម **ឈោទ ចិន្តា** ដើម្បីបំពេញមុខងារជាអនុប្រធានមន្ទីរសារការី វាណិជ្ជ និងសហភាគា

៣. លោកស្រី **នៅ សុជាតា** ដើម្បីបំពេញមុខងារផ្សេងៗតាមតម្រូវការរបស់មន្ទីរសារការី វាណិជ្ជ និងសហភាគា។

ក្នុងករណីចាំបាច់ មន្ទីរសារការី វាណិជ្ជ និងសហភាគា អាចធ្វើការជ្រើសរើសសារការីដែលទទួលបានការតែងតាំងពីរាជរដ្ឋាភិបាល ឬបុគ្គលិកផ្សេងទៀតសម្រាប់ជួយបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបាន។

**មាត្រា ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ មន្ទីរសារការី វាណិជ្ជ និងសហភាគា នៃព្រះរាជាណាចក្រកម្ពុជា និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ៥ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

*កន្លែងទទួល:*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៧*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៤៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់មន្ទីរសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា ១.-**

ត្រូវបានទទួលស្គាល់ការបង្កើតមន្ទីរសារការីមួយ ដែលមានឈ្មោះថា **មន្ទីរសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា** (H.B.S Notary Public of the Kingdom of Cambodia) សរសេរកាត់ជាភាសាខ្មែរ "**អ.ប.អ.ស**" និងសរសេរកាត់ជាភាសាអង់គ្លេស "H.B.S.N"។

**មាត្រា ២.-**

មន្ទីរសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា មានទីតាំងដើមស្ថិតនៅអគារពាណិជ្ជកម្មសូម៉ា ផ្លូវលេខ ១២០ សង្កាត់ ផ្សារថ្មីទី ១ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ។

**មាត្រា ៣.-**

មន្ទីរសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា មានតួនាទី និងភារកិច្ចដូចតទៅ :

- ទទួលធ្វើរាល់លិខិតស្នាមគតិយុត្ត ឬកិច្ចសន្យាទាំងឡាយ ដែលរូបវន្តបុគ្គល ឬនីតិបុគ្គលនៃនីតិឯកជន ឬនីតិបុគ្គលនៃនីតិសាធារណៈមានកាតព្វកិច្ចផ្តល់យថាភូតភាពតាមច្បាប់កំណត់ ឬមានបំណងផ្តល់យថាភូតភាពដោយខ្លួនឯង
- ទទួលបញ្ជាក់រាល់លិខិតស្នាមគតិយុត្ត ឬកិច្ចសន្យាទាំងឡាយ ដែលរូបវន្តបុគ្គល ឬនីតិបុគ្គលនៃនីតិឯកជន ឬនីតិបុគ្គលនៃនីតិសាធារណៈមានកាតព្វកិច្ចតាមច្បាប់កំណត់ ឬឆន្ទៈខ្លួនឯង
- បញ្ជាក់ធានាហត្ថលេខា និងកាលបរិច្ឆេទ នៃលិខិតស្នាមគតិយុត្ត ឬកិច្ចសន្យា
- ផ្តល់យថាភូតភាពលើឯកសារបកប្រែពីភាសាបរទេសមកភាសាខ្មែរ និងពីភាសាខ្មែរទៅភាសាបរទេស
- ធ្វើសំណើចុះបញ្ជី និងលេខាចារឹកទៅស្ថាប័នមានសមត្ថកិច្ច
- ធ្វើការរក្សាទុកច្បាប់ដើមនៃលិខិតស្នាមគតិយុត្ត និងកិច្ចសន្យា
- ធ្វើការរក្សាទុកច្បាប់ដើមនៃមតកសាសន៍
- ចេញច្បាប់ចម្លងនៃលិខិតយថាភូត និង
- ទទួលធ្វើ និងបញ្ជាក់រាល់លិខិតស្នាមគតិយុត្តផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់ ។

**មាត្រា ៤.-**

មន្ទីរសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា ត្រូវគ្រប់គ្រងដោយសារការី **ឈី ឆៃសេង** ជាប្រធាន និងសារការី **តាន់ហ៊ាង ជាទំនួ** ។

**មាត្រា ៥.-**

មន្ទីរសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា ត្រូវតំកល់ប្រាក់ធានាចំនួន ៦០០,០០០,០០០.០០ (ប្រាំមួយរយលានរៀល) នៅធនាគារជាតិ នៃកម្ពុជា សម្រាប់ធានាការទទួលខុសត្រូវក្នុងការបំពេញមុខងាររបស់ខ្លួន ។

**មាត្រា ៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងមន្ទីរសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៨

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៧*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ* ✓

# ប្រកាស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ស្ដីការក្រសួងយុត្តិធម៌

លេខៈ [illegible]/១២

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១២

# ប្រកាស

## ស្ដីពី

## ការកំណត់មន្ត្រីទទួលបន្ទុកកិច្ចការសារការី

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- យោងតាមការចាំបាច់

## ស ម្រេ ច



ផ្លូវសម្ដេចសុធារស, ខ័ណ្ឌដូនពេញ, ក្រុងភ្នំពេញ ទូរស័ព្ទ : 023 216 322 , 023 215 638

ប្រការ ១:

ត្រូវបានកំណត់ជាមន្ត្រីទទួលបន្ទុកកិច្ចការសារការី នៅតាមដែនសមត្ថកិច្ចនៃសាលាដំបូង សាមីខ្លួនដូចមានរាយនាមខាងក្រោម:

**ក.រាជធានីភ្នំពេញ**

១-ឯកឧត្តម **ហួត ហាក់**

២-ឯកឧត្តម **ជួច សំភី**

**ខ.ខេត្តកណ្ដាល**

១- ឯកឧត្តម **កើត រិទ្ធ**

២- លោក **ទេព្យ ប៊ុនទិសុទ្ធ**

**គ-ខេត្តកំពង់ឆ្នាំង**

១-ឯកឧត្តម **ហ៊ើល ចំរើន**

២-លោក **គុល គំពូល**

**ឃ.ខេត្តកំពង់ស្ពឺ**

១. ឯកឧត្តម **ស៊ូ សុជាតិ**

២. លោក **ខួន ណារ៉ា**

**ង.ខេត្តកំពត**

១. ឯកឧត្តម **ការ៉ន ចំនួមេត្តា**

២. លោក **អ៊ុច គ្រាយ**

**ច.ខេត្តព្រះសីហនុ**

១.ឯកឧត្តម **ឡាំ ជា**

២.លោក **វឿម ចំនួម្នី**

**ឆ.ខេត្តកោះកុង**

១.លោក **គុប ឈុនហេង**

២.លោក **ហុង សុគុណវឌ្ឍនា**

**ជ.ខេត្តតាកែវ**

១.លោក **មាស សុភក្តិ**

២.ឯកឧត្តម **អ៊ុង សេរីវិសុទ្ធ**

**ឈ.ខេត្តស្វាយរៀង**

១.ឯកឧត្តម **គីម សន្តិភាព**

២.លោក **យក់ ប៊ុនណា**

**ញ.ខេត្តព្រៃវែង**

១-លោក **សាយ ណារ៉ា**

២-លោក **សម ប៊ុនថុន**

**ព.ខេត្តកំពង់ចាម**

១-លោក ផាន់ សុភក្រ្ត

២-លោក ប៊ុន យ៉េណារិន

**ផ.កំពង់ធំ**

១.លោក អ៊ិត សុធា

២. លោក សារឿន កោសល្យមុនី

**ម.ខេត្តក្រចេះ**

១. លោកស្រី ចាត សុរស្មី

២. ឯកឧត្តម សំ រិទ្ធី

**យ.ខេត្តពោធិ៍សាត់**

១-លោក ម៉ិច ចាន់សុយុទ្ធារា

២-លោក សឿង ធីរិទ្ធ

**រ.ខេត្តបាត់ដំបង**

១-លោក ហ៊ីង ប៊ុនថន

២-លោក ផាន់ តីរម្យ

**ល.ខេត្តប៉ៃលិន**

១.លោក ជុំ សែនសទ្ធា

២.លោក អ៊ី សាវិញ

**វ.ខេត្តបន្ទាយមានជ័យ**

១-លោក ផាន់ វណ្ណារ័ត្ន

២-លោក គី ម៉ានៅ៉

**ឝ. ខេត្តសៀមរាប**

១-លោក កើត វណ្ណារ៉េត

២-លោក ស្រ៊ា រតនៈ

**ឞ. ខេត្តឧត្តរមានជ័យ**

១. លោក គួយ កាន់យ៉ា

២. ឯកឧត្តម ប្ញូន សុមុនី

**ស.ខេត្តព្រះវិហារ**

១.លោក ជុំ ស

២.ឯកឧត្តម កៅ ថាច

**ហ.ខេត្តរតនៈគីរី**

១.លោក លាង ស្រេង

ប្រការ ២:

មន្ត្រីទទួលបន្ទុកកិច្ចការសារការី ដូចមានរាយនាមខាងលើ ត្រូវអនុវត្តកិច្ចការសារការី ក្នុងអំឡុងពេលរហូតដល់កាលបរិច្ឆេទ នៃការអនុវត្តច្បាប់ស្តីពីលក្ខន្តិកៈនៃសារការី។

មន្ត្រីទទួលបន្ទុកកិច្ចការសារការី ត្រូវធ្វើកិច្ចការរបស់សារការីដែលមានកំណត់ក្នុងក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី និងធ្វើការចាត់ចែងផ្សេងទៀត ដែលមានកំណត់ក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌។

ប្រការ ៣:

ប្រកាសលេខ ៤៧ កយ.ប្រក/១២ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២ របស់ក្រសួងយុត្តិធម៌ ត្រូវទុកជានិរាករណ៍។

ប្រការ ៤:

សាមីខ្លួនដូចមានរាយនាមក្នុងប្រការ១ ខាងលើ និងស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធិភាព តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អង្គ វង្សវឌ្ឍនា

**ចម្លងជូន :**

- ខុទ្ទកាល័យ សម្តេចតេជោ នាយករដ្ឋមន្ត្រី
- សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់
- អយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ: [illegible]

# ប្រកាស
# ស្តីពី
# ការតែងតាំងសិស្សសារការី ជំនាន់ទី ១ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
## និងជាប្រធានក្រុមប្រឹក្សាភិបាល នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ / ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០១០៥ / ០១៩ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការបង្កើតរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.តត ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៩ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- បានឃើញអនុក្រឹត្យលេខ ១១៧ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៨ ស្តីពីការបង្កើតសាលាភូមិន្ទសារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- បានឃើញលទ្ធផលស្ពាពរនៃការប្រឡងប្រជែងជ្រើសរើសសិស្សសារការី ជំនាន់ទី ១ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២

## សាលាភូមិន្ទសារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

សារការីជាមន្ត្រីសាធារណៈដែលទទួលអំណាចសាធារណៈពីរដ្ឋដើម្បីផ្ដល់យថាភូតភាព[1] ដល់រាល់លិខិតគតិយុត្ត ប៉ុន្តែសារការីជាអ្នកប្រកបវិជ្ជាជីវៈសេរីដោយអនុវត្តសកម្មភាពរបស់ខ្លួនក្នុងក្របខ័ណ្ឌមន្ទីរសារការី ។ សេវាកម្មមួយចំនួនរបស់សារការីរួមមានដូចជា៖ ផ្ដល់យថាភូតភាព និងធ្វើការបញ្ជាក់ (ហត្ថលេខា ឬស្នាមមេដៃ សេចក្ដីចម្លងតាមច្បាប់ដើម) លើឯកសារគតិយុត្ត និងកិច្ចសន្យាធានា ផ្ដល់យថាភូតភាពលើកិច្ចសន្យាផ្ទេរសិទ្ធិកម្មសិទ្ធិ ផ្ដល់យថាភូតភាពលើឯកសារកម្ចី និងឯកសារប្រាតិភោគលើអចលនវត្ថុ អាពាហ៍ពិពាហ៍ជាមួយជនបរទេស សុំកូនកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិប្ដីប្រពន្ធ ប្រទានកម្ម និងមតកសាសន៍ (បណ្ដាំមតក) ព្រមទាំងរក្សាទុកច្បាប់ដើមនៃបណ្ដាំមតក ការជម្រះបញ្ជីរបែងចែកទ្រព្យនៅពេលលែងលះ និងពេលចាប់ផ្ដើមសន្តតិកម្ម (មរណភាព) ការចុះបញ្ជីក្រុមហ៊ុន និងនីតិបុគ្គលផ្សេងទៀត ការបកប្រែភាសាពីភាសាបរទេសមកភាសាខ្មែរ និងពីភាសាខ្មែរទៅភាសាបរទេសដែលមានបញ្ជាក់ដោយសារការី និងចេញច្បាប់ចម្លងនៃលិខិតយថាភូត ។ល។ រាល់លិខិតដែលធ្វើឡើងដោយសារការី គឺជាលិខិតផ្លូវការដូចលិខិតដែលធ្វើឡើងដោយមន្ត្រីសាធារណៈផ្សេងទៀត ហើយក្លាយជាភស្តុតាងដ៏រឹងមាំសម្រាប់ប្រើប្រាស់ ។

ព្រះរាជាណាចក្រកម្ពុជាយើង ទើបតែនឹងបង្កើតឱ្យមានការបណ្ដុះបណ្ដាលវិជ្ជាជីវៈសារការីនេះឡើងដើម្បីរួមចំណែកក្នុងការពង្រឹងវិស័យយុត្តិធម៌ តាមរយៈវត្តមាននៃក្រុមសិស្សសារការីជំនាន់ទី១ ដូចមានរាយនាមក្នុងប្រកាសរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី លេខ១៧ ប្រក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ ស្ដីពីការតែងតាំងសិស្សសារការីជំនាន់ទី១ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ រួមមាន៖

| ល.រ | គោត្តនាម និងនាម | អក្សរឡាតាំង | ភេទ | អ៊ីម៉ែល &លេខទូរស័ព្ទ |
|---|---|---|---|---|
| ១. | ប្អូន សារៈមុនី | BUON SARAKMONY | ប្រុស | buonsarakmony@gmail.com<br>Tel: 015 838 338 |
| ២. | ស៊ិន សុពុទ្ធិ | SIN SOPUTHI | ប្រុស | soputhi@yahoo.com<br>Tel: 012 487 973 |
| ៣. | លី រ៉ានាថ | LY RANEATH | ស្រី | lyraneath@yahoo.com<br>Tel: 078 777 073 |
| ៤. | សែន សេងថៃ | SEN SENGTHAI | ប្រុស | s_sengthai@yahoo.com<br>Tel: 012 309 115 |
| ៥. | អេង គីមសួរ | ENG KIMSOUR | ស្រី | kimsour.eng@gmail.com<br>Tel: 012 927 072 |
| ៦. | ផង់ វិចិត្រ | PHANG VICHET | ប្រុស | phangvichet@gmail.com<br>Tel: 012 734 475 |
| ៧. | កាំង ផេង | KAING PHENG | ប្រុស | phengkaing@gmail.com<br>Tel: 012 203 944 |
| ៨. | កាន់ សុទ្ធប៉ូលីន | KAN SOTHPOLIN | ប្រុស | kansothpolin@yahoo.com<br>Tel: 011 648 272 |
| ៩. | យន់ សុវណ្ណារ៉ា | YUN SOVANNARA | ប្រុស | sovannarayun@yahoo.com<br>Tel: 012 543 251 |
| ១០. | ជឹង ស្រីតូច | CHING SREYTOUCH | ស្រី | chingsreytouch@yahoo.com<br>Tel: 089 866 6923/096 6071 714 |
| ១១. | ចាំង ស្រីពៅ | CHAING SREYPEOU | ស្រី | sreypeou@cspalawfirm.com<br>Tel: 088 521 2222 |
| ១២. | ប៉ាន់ វាសនា | PANN VEASNA | ប្រុស | pnnveasna@yahoo.com<br>Tel: 097 2000 689 |
| ១៣. | សៀង ធារី | SIENG THEARY | ស្រី | sieng.theary@yahoo.com<br>Tel: 012 792 924 |
| ១៤. | ហ៊ី ធុនា | HY THONA | ប្រុស | thonahy20@gmail.com<br>Tel: 077 614 224 |
| ១៥. | សៅ នឿន | SAO NOEUN | ប្រុស | saonoeun@gmail.com<br>Tel: 012 576 736 |

លិខិតយថាភូត៖ លិខិតធ្វើឡើងតាមរូបមន្តច្បាប់ ដោយមន្ត្រីសាធារណៈដែលត្រូវបានអនុញ្ញាតឱ្យប្រតិបត្តិមុខងារនេះ។ តាមន័យចង្អៀតគឺជា លិខិតរៀបចំឡើងដោយសារការី (សទ្ទានុក្រមផ្នែករដ្ឋប្បវេណីនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ទំព័រទី១៥) ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ÷...១៥៩.....ប្រក/ដនស./មផ

ប្រកាសអន្តរក្រសួង
ស្តីពី
ការកែសម្រួលប្រការ ៩ នៃប្រកាសអន្តរក្រសួងលេខ ២០៥ ប្រក/ដនស.មផ ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៥
ស្តីពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ ក្នុងការចុះបញ្ជីដីធ្លី

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ
- យោងតាមការចាំបាច់របស់ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**ប្រការមួយ .**

ប្រការ ៩ នៃប្រកាសអន្តរក្រសួងលេខ ២១៥ ប្រក/ដនស.មផ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ ២០០៥ ស្ដីពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ ក្នុងការចុះបញ្ជីដីធ្លី ត្រូវបានកែសម្រួលដូចតទៅ÷

**ប្រការ ៩ . ថ្មី**

មេឃុំ ចៅសង្កាត់ ជាអ្នកបញ្ជាក់លើលិខិតសញ្ញាផ្សេងៗ ដូចជា លិខិតលក់ផ្ដាច់ អំណោយផ្ដាច់ កិច្ចសន្យាបញ្ចាំ ដាក់ធានា ហ៊ីប៉ូតែក កិច្ចសន្យាជួលរយៈពេលវែង កិច្ចសន្យាបង្កើតសេវភាព ផលុបភោគ អាស្រ័យលើការព្រមព្រៀងរបស់គូភាគី ។ ក្នុងការបញ្ជាក់ មេឃុំ ចៅសង្កាត់ត្រូវយកចិត្តទុកដាក់ និងទទួលខុសត្រូវលើ ÷

- អត្តសញ្ញាណអចលនវត្ថុ ដែលជាកម្មវត្ថុនៃលិខិតកិច្ចសន្យា និង
- អត្តសញ្ញាណគូភាគីនៃកិច្ចសន្យា ។

**ប្រការពីរ .**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការបី .**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល គ្រប់ប្រធានអង្គភាពក្រោមនិវាទក្រសួងមហាផ្ទៃ នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន គ្រប់ប្រធានអង្គភាពក្រោមនិវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គ្រប់អភិបាលរាជធានី ខេត្ត គ្រប់ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត គ្រប់អភិបាលក្រុង ស្រុក ខណ្ឌ គ្រប់ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ គ្រប់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែមិថុនា គ.ស. ២០១៦

| | |
|---|---|
| ឧបនាយករដ្ឋមន្ត្រី | ទេសរដ្ឋមន្ត្រី |
| រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| សម្តេចក្រឡាហោម ស ខេង | ជា សុផារ៉ា |

**កន្លែងទទួល÷**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ដូចប្រការបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឯកសារផ្សេងៗទាក់នឹងការផ្ដល់យថាភូត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

--------

# កិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក

១. **ឈ្មោះនិងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា៖**

(១) <u>កូនបំណុលឈ្មោះ</u>

**លោក** កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី (ហៅថា "**កូនបំណុល**" ឬ**ភាគី "ក"**)

(២) <u>ម្ចាស់បំណុលឈ្មោះ</u>

**ធនាគារ សហពាណិជ្ជ ក.អ សាខាក្បាលថ្នល់** មានទីស្នាក់ការចុះបញ្ជីនៅអាគារលេខ 518ABC មហាវិថីព្រះមុនីវង្ស ភូមិ12 សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ដែលតំណាងដោយ **លោក គង់ វឌ្ឍនា** មុខងារជា **នាយកសាខា** (ហៅថា "**ម្ចាស់បំណុល**" ឬ **ភាគី "ខ"**)។

(៣) <u>អ្នកបង្កើតហ៊ីប៉ូតែកឈ្មោះ</u>

**លោក** កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី (ហៅថា "**អ្នកបង្កើតហ៊ីប៉ូតែក**" ឬ **ភាគី "គ"**)។

២. **កិច្ចសន្យាខ្ចីបរិភោគ (សិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក)៖**

<u>កូនបំណុលឈ្មោះ</u>

**លោក** - កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី (ហៅថា "**កូនបំណុល**" ឬ**ភាគី "ក"**)

(១) ចំនួនប្រាក់ដើម៖ USD 100,000.00 (**មួយរយពាន់ដុល្លារអាមេរិកគត់**)។

(៣) **អត្រាការប្រាក់៖ 7.5%** ភាគរយ និងស្របតាមសិទ្ធិកែប្រែដោយធនាគារ។

(៤) សំណងការខូចខាត៖ **24ភាគរយ** និងស្របតាមសិទ្ធិកែប្រែដោយធនាគារ ។

(៥) លក្ខខណ្ឌភ្ជាប់ ៖ ដូចមានភ្ជាប់ក្នុងកិច្ចសន្យាខ្ចីបរិភោគ។

**ភាគី "ក"** និង **ភាគី "ខ"** បានព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាខ្ចីបរិភោគដែលមានចែងនៅក្នុងចំនុចខាងលើ។

**ភាគី "ខ"** និង **ភាគី"គ"** បានព្រមព្រៀងគ្នាបង្កើតហ៊ីប៉ូតែកដើម្បីធានាសិទ្ធិលើបំណុលដែលមានចែងនៅក្នុងចំណុចទី២ ខាងលើ។

៣. **អត្តសញ្ញាណអចលនវត្ថុ ឬ សិទ្ធិដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក៖**

- **ទីតាំងអចលនវត្ថុ** ៖ ផ្ទះលេខ ផ្លូវលេខP06 ដី ផាក លែន សែនសុខ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។
- **ដីឡូត៍** ៖ លេខ
- **បណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ** ៖ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលវត្ថុលេខ ចុះថ្ងៃទី ខែឧសភា ឆ្នាំ 2016 ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ។

៤. **កិច្ចសន្យាផ្សេងទៀត**

- ឧបសម្ព័ន្ធ “**ក**” នៃកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី07 ខែមេសា ឆ្នាំ2017 ។
- ឧបសម្ព័ន្ធ “**ខ**” នៃកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី07 ខែមេសា ឆ្នាំ2017 ។

**កិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក** នេះត្រូវបានធ្វើឡើងជា05 ច្បាប់ នៅថ្ងៃទី **នៅចំពោះមុខសារការី**។

**ម្ចាស់បំណុល**

**ធនាគារ សហពាណិជ្ជ ក.អ**

*ត្រាធនាគារ*

UNION COMMERCIAL BANK PLC BRANCH

ឈ្មោះ៖ **គង់ វឌ្ឍនា**

**កូនបំណុល**

*ស្នាមមេដៃស្តាំ*

ឈ្មោះ៖ **លោក**

**អ្នកបង្កើតហ៊ីប៉ូតែក**

*ស្នាមមេដៃស្តាំ*

ឈ្មោះ៖ **លោក**

**លេខបញ្ជាក់.០.១១៣៤.ស.អ.-៥១៧**

**មន្ទីរសារការីរដ្ឋ**

**ហត្ថលេខា និងត្រា**



សារការី.ហ៊ឺ ថុនា

.2011



ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
Nation – Religion – King

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
Khmer Identity Card

ក្នុងករណីបាត់ ខូច ឬអ្នកសយដ្ឋានត្រូវយកការណ៍ជូនសមត្ថកិច្ច
អ្នកក្លែងអត្តសញ្ញាណប័ណ្ណនឹងត្រូវផ្តន្ទាទោសតាមច្បាប់



IDKHM0111170296<<<<<<<<<<<<<<
7605035M2601157KHM<<<<<<<<<<<
KHENG<<KHUNNY<<<<<<<<<<<<<<<<



លេខបញ្ជាក់ ៧២០១៩ ស.ក.២០១៧
មន្ទីរសារការីអង្គរ
ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។
ភ្នំពេញ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧
ហត្ថលេខា និងត្រា

ព្រះរាជាណាចក្រកម្ពុជា * មន្ទីរសារការីអង្គរ ANGKOR NOTARY PUBLIC * KINGDOM OF CAMBODIA

សារការី ហ៊ឺ ប៊ុនណា

មន្ទីរសារការី អង្គរ
ANGKOR NOTARY PUBLIC

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

*Notarial Deed N°* 01301.ANF17

*ANGKOR NOTARY PUBLIC OF THE KINGDOM OF CAMBODIA*

Recognized by Royal Government of the Kingdom of Cambodia by **Sub-Decree No. 42 dated March 10, 2016**, having address at Building No. 1F, Street 99, Sangkat Boeung Trabek, Khan Chamkar Mon, Phnom Penh certify that ***This English version of the attached Birth Certificate*** is duly conformed to Khmer version attached with.

Phnom Penh, April 28, 2017

**Signature and Seal**

ព្រះរាជាណាចក្រកម្ពុជា * មន្ទីរសារការីអង្គរ ANGKOR NOTARY PUBLIC * KINGDOM OF CAMBODIA

HY THONA
Notary Public

អគារលេខ ១អេហ្វ ផ្លូវលេខ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ, Email: info@angkornotary.com.kh , Website : www.angkornotary.com.kh
Building No. 1F, Street 99, Sangkat Beoung Trabek, Khan Chamkarmorn, Phnom Penh, Cambodia, Tel : 023 901 206

[*national coat of arms*]

KINGDOM OF CAMBODIA
Nation Religion King

Province/City: Phnom Penh Capital
District/*Khan*: Po Senchey
Commune/*Sangkat*: Kakap

No. 142
Birth Record No. 03/2012
Year 2012

# BIRTH CERTIFICATE

| | | | |
|---|---|---|---|
| Family name | | REINSCH | Sex: Male |
| Given name of infant | | RATIBOR | |
| In Latin letters | Family name | REINSCH | |
| | Given name of infant | RATIBOR | |
| Nationality | | Khmer | |
| Date of birth | | Saturday, 26 May 2012 | |
| Place of birth: village, commune/*Sangkat*, district/*Khan*, province/city, country | | Chamkar Euvloeuk village, *Sangkat* Kakap, *Khan* Po Senchey, Phnom Penh capital, Cambodia | |

| Parents of infant | Father | Mother |
|---|---|---|
| Family and given names | **REINSCH ANDREAS** | **UM MOLLIKA** |
| In Latin letters | REINSCH ANDREAS | UM MOLLIKA |
| Nationality | German | Khmer |
| Date of birth | 24 January 1966 | 13 November 1984 |
| Place of birth: village, commune/*Sangkat*, district/*Khan*, province/city, country | Germany | *Sangkat* No. 2, Phnom Penh city, Cambodia |
| Residence at the time of infant's birth | Chamkar Euvloeuk village, *Sangkat* Kakap, *Khan* Po Senchey, Phnom Penh capital | |

Made in Kakap, 26 June 2012
**Registrar of Civil Status**
[*signature and stamp*]

**SOK EL**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង រាជធានីភ្នំពេញ
ស្រុក ខណ្ឌ ពោធិ៍សែនជ័យ
ឃុំ សង្កាត់ កាកាប

លេខ ១៤៦
សៀវភៅកំណើតលេខ ០៣/២០១២
ឆ្នាំ ២០១២

# សំបុត្រកំណើត

| | | | |
|---|---|---|---|
| នាមត្រកូល | | រ៉េន | ភេទ |
| នាមខ្លួនទារក | | រ៉ាធីបរ | ប្រុស |
| ជាអក្សរឡាតាំង | នាមត្រកូល | REINSCH | |
| | នាមខ្លួនទារក | RATIBOR | |
| សញ្ជាតិ | | ខ្មែរ | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | ថ្ងៃ សៅរ៍ ទី ២៦ ខែ ឧសភា ឆ្នាំ ២០១២ | |
| ទីកន្លែងកំណើត<br>ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | | ភូមិចំការឪឡឹក សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ<br>ប្រទេសកម្ពុជា | |

| ឪពុក ម្តាយទារក | ឪពុក | ម្តាយ |
|---|---|---|
| នាមត្រកូល និង នាមខ្លួន | រ៉េន អាន់ដ្រៀស | អ៊ុំ មល្លិកា |
| ជាអក្សរឡាតាំង | REINSCH ANDREAS | UM MOLLIKA |
| សញ្ជាតិ | អាល្លឺម៉ង់ | ខ្មែរ |
| ថ្ងៃ ខែ ឆ្នាំកំណើត | ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៦៦ | ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៨៤ |
| ទីកន្លែងកំណើត<br>ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | ប្រទេសអាល្លឺម៉ង់ | សង្កាត់លេខ២ ក្រុងភ្នំពេញ<br>ប្រទេសកម្ពុជា |
| ទីលំនៅពេលទារកកើត | ភូមិចំការឪឡឹក សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ | |

ធ្វើនៅ កាកាប ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១២

មន្ត្រីអត្រានុកូលដ្ឋាន

ស៊ុខ អើល

មន្ទីរសារការី អង្គរ
ANGKOR NOTARY PUBLIC

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

លេខបញ្ជាក់៖ ០១០៦០.ស.អ.៩.១៧

## ការបញ្ជាក់ស្នាមមេដៃ

### មន្ទីរសារការី អង្គរ នៃព្រះរាជាណាចក្រកម្ពុជា

ទទួលស្គាល់ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា តាមអនុក្រឹត្យលេខ៤២ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ មានទីស្នាក់ការនៅអគារលេខ ១អេហ្វ ផ្លូវលេខ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ បញ្ជាក់ថា ឈ្មោះ **កៅ យ៉ាត (ស្រី) កាន់លិខិតឆ្លងដែនលេខ N000៣៧១៨៧ ចុះនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៤** ពិតជាបានផ្តិតស្នាមមេដៃ លើសេចក្តីថ្លែងការណ៍យល់ព្រម ដែលភ្ជាប់មកជាមួយនេះ នៅចំពោះមុខយើងជាសារការីពិតប្រាកដមែន។

ការបញ្ជាក់នេះ ត្រូវបានធ្វើឡើង ០៣ (បី) ច្បាប់ដើម។

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៧

ហត្ថលេខា និងត្រា

មន្ទីរសារការីអង្គរ
ANGKOR NOTARY PUBLIC
KINGDOM OF CAMBODIA

សារការី. ហ៊ី ថុនា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## សេចក្តីថ្លែងការណ៍យល់ព្រម

នាងខ្ញុំឈ្មោះ ភេទស្រី កើតឆ្នាំ ១៩៩១ កាន់លិខិតឆ្លងដែនលេខ , ចុះនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៤ បច្ចុប្បន្នស្នាក់នៅ ភូមិខ្នារ ឃុំខ្នារ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ជាម្តាយរបស់កូនឈ្មោះ ភេទស្រី កើតថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៧ សូមអះអាង និងបញ្ជាក់ថា នាងខ្ញុំយល់ព្រមប្រគល់សិទ្ធិអំណាចមេបាលើកូនឈ្មោះ ឱ្យទៅឪពុកឈ្មោះ កើតឆ្នាំ ១៩៨៣ ជនជាតិចិន កាន់លិខិតឆ្លងដែនលេខ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១២។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមអាជ្ញាធរ ឬស្ថាប័នមានសមត្ថកិច្ចទាំងឡាយ មេត្តាទទួលស្គាល់នូវ សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សររបស់នាងខ្ញុំ តាមការកំណត់ច្បាប់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៧

មន្ទីរសារការីអង្គរ
ANGKOR NOTARY PUBLIC
KINGDOM OF CAMBODIA

ស្នាមមេដៃស្តាំ



ភៅ យ៉ាត

ឈ្មោះជាភាសាខ្មែរ
Name in Khmer

មុខរបរ
Profession EMPLOYEE

កំពស់
Height 159 CM

ស្លាកស្នាមពិសេស
Distinguishing marks BEAUTY SPOT BELOW THE RIGHT BASE OF EYE

លិខិតឆ្លងដែននេះអាចប្រើប្រាស់បានក្នុងការធ្វើដំណើរទៅគ្រប់ប្រទេស
This passport is valid for all countries

ក្នុងករណីមានអាសន្ន សូមទាក់ទងឈ្មោះ:
In case of emergencies contact

ហត្ថលេខារបស់អ្នកកាន់លិខិតឆ្លងដែន
Signature of bearer

អាសយដ្ឋាន
Address PH.KHNA/KH.KHNA SAR
SREY SANTHO/KOMPONG CHAM

ព្រះរាជាណាចក្រកម្ពុជា KINGDOM OF CAMBODIA

លិខិតឆ្លងដែន / PASSPORT

ប្រភេទ/Type PN
លេខកូដប្រទេស/Country Code KHM
លេខលិខិតឆ្លងដែន/Passport No
នាមត្រកូល/Surname
នាមខ្លួន/Given names



សញ្ជាតិ/Nationality CAMBODIAN
ថ្ងៃខែឆ្នាំកំណើត/Date of birth 22 Apr 1991
ភេទ/Sex F
ថ្ងៃចេញ/Date of issue 01 Sep 2014
ផុតកំណត់នៅថ្ងៃ/Date of expiry **01 Sep 2024**

ទីកន្លែងកំណើត/Place of birth KOMPONG CHAM
អាជ្ញាធរ/Authority MIN PHNOM PENH

ANGKOR NOTARY PUBLIC
KINGDOM OF CAMBODIA

PNKHMKAO<<YAT<<<<<<<<<<<<<<<<<<<<<<<<<<<<<<<<<
[illegible]KHM9104222F2409010N0000011502<<<28



# 出生医学证明

## MEDICAL CERTIFICATE OF BIRTH

新生儿姓名 Neonatal Name [illegible] 性别 Gender 女 出生时间 Time of Birth 2017 年 Year 03 月 Month 18 日 Day 10 时 Hour 20 分 Minute

出生孕周 Gestational Age 39 周 Week 出生体重 Birth Weight 3000 克 g 出生身长 Birth Length 49 厘米 cm

出生地点 Birth Place [illegible] 省 Province 广州 市 City 白云 县(区) County 医疗机构名称 Medical Institutions 广州玛莱[illegible]

母亲姓名 Mother's Name [illegible] 年龄 Age 25 国籍 Nationality [illegible] 民族 Ethnic Group 外国人 住址 Address 外国

有效身份证件类别 Valid Identification 居民身份证 Identity Card ☐ √护照 Passport ☐ 其他 Others 有效身份证件号码 Valid Identification No. N00037187

父亲姓名 Father's Name 于景仰 年龄 Age 33 国籍 Nationality 中华人民共和国 民族 Ethnic Group 汉族 住址 Address 山东省烟台市芝罘区幸芝里129号内11号

有效身份证件类别 Valid Identification 居民身份证 Identity Card ☑ 护照 Passport ☐ 其他 Others 有效身份证件号码 Valid Identification No. 370602198311031812

Q440595417

签发机构(盖专用章) Issued Authority (Stamp) 广州玛莱妇产医院

签发日期 Date Issued 2017 年 Year 3 月 Month 23 日 Day

编号 No. Q440595417

---

### 出生医学证明副页

新生儿姓名 [illegible] 性别 女 出生时间 2017 年 03 月 18 日 10 时 20 分

出生孕周 39 周 出生体重 3000 克 出生身长 49 厘米

出生地点 [illegible] 省 [illegible] 市 白云 县(区) 医疗机构名称 广州玛莱妇产医院

母亲姓名 KAO YAT 年龄 25 国籍 [illegible] 民族 外国人 住址 外国

有效身份证件类别 居民身份证 ☐ √护照 ☐ 其他 有效身份证件号码 [illegible]

父亲姓名 [illegible] 年龄 33 国籍 中华人民共和国 民族 [illegible] 住址 山东省烟台市芝罘区幸芝里129号内11号

有效身份证件类别 居民身份证 ☑ 护照 ☐ 其他 有效身份证件号码 370602198311031812

签发机构(盖专用章) 广州玛莱妇产医院

签发日期 2017 年 3 月 23 日

Q440595417

编号 Q440595417

此副页由户口登记机关裁切保存

ANGKOR NOTARY PUBLIC KINGDOM OF CAMBODIA

中华人民共和国外交部请各国军政机关对持照人予以通行的便利和必要的协助。

*The Ministry of Foreign Affairs of the People's Republic of China requests all civil and military authorities of foreign countries to allow the bearer of this passport to pass freely and afford assistance in case of need.*

ANGKOR NOTARY PUBLIC

中华人民共和国 PEOPLE'S REPUBLIC OF CHINA

护照 PASSPORT

类型/Type P

国家码/Country Code CHN

护照号码/Passport No. [illegible]



姓名/Name
于景仰

性别/Sex 男/M

国籍/Nationality 中国/CHINESE

出生日期/Date of birth 03 NOV 1983

出生地点/Place of birth 山东/SHANDONG

签发日期/Date of issue 17 10月/OCT 2012

签发地点/Place of issue 山东/SHANDONG

有效期至/Date of expiry 16 10月/OCT 2022

签发机关/Authority 公安部出入境管理局 MPS Exit & Entry Administration

持照人签名/Bearer's signature

POCHNYU<<JINGYANG<<<<<<<<<<<<<<<<<<<<<<<<<<<<<

[illegible]CHN83[illegible]1036M2210160NDNKLOLANBPGA950